ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Court Suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Apr-2011, 09:22
CMS/CFO: Uch Arun

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>ជំនុំជម្រះក្តីលើ "បណ្តឹងសាទុក្ខ", កាំង ហ្គេកអ៊ាវ ហៅ ឌុច</u>
# <u>សាធារណៈ</u>

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក

**ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១**

**ម៉ោង ០៨: ៥៩ នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រីម ជាប្រធាន

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម ម៉ូតូ ណូហ្គូជិ
*(Judge Motoo NOGUCHI)*

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម អាកនីស្កា ក្លូណូមីវីកកា មីឡាត
*(Judge Agnieszka KLONOWIECKA-MILART)*

ចៅក្រម យ៉ា ណារិន

ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហ៍
*(Judge Chandra Nilhal JAYASINGHE)*

ចៅក្រម ម៉ុង មន្នីចរិយា (បម្រុង)

ចៅក្រម ផ្លូរិន ម៉ុមបា (បម្រុង)
*(Judge Florence Mumba)*

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ

លោក គ្រីស្តូហ្វឺ ម៉ាក រីយ៉ាន
*(Mr. Christopher Mark Ryan)*

លោក ផន ធឿន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក ពេជ សម្បត្តិ

លោក សេង ប៊ុនឃាង

**មេធាវីការពារជនត្រូវចោទ កាំង ហ្គេកអ៊ាវ:**

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Ms. Martine Jacquing)*

លោក ហ្វីលីព កាណុន

*(Mr. Philippe Canonne)*

លោកស្រី អេលីហ្សាបេ៊ត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elisabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម គង់ ស្រ៊ីម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ម៉ូតូ ណូហ្គូជិ | អង់គ្លេស |
| ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡូត | អង់គ្លេស |
| ចៅក្រម ស៊ិន រិទ្ធ | ខ្មែរ |
| លោកស្រី ជា លាង | ខ្មែរ |
| លោក អាន់ឌ្រូ ខេលី | អង់គ្លេស |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក កង ឫទ្ធារី | ខ្មែរ |
| លោក ស៊ា ម៉ៅ | ខ្មែរ |
| លោក ផន ធឿន (ក្រឡាបញ្ជី) | ខ្មែរ |
| | |
| | |
| | |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:២០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះតុលាការកំពូលប្រកាសបន្តសវនាការ។

លោកក្រឡាបញ្ជី តើភាគីនិងមេធាវីចូលគ្រប់ចំនួនហើយឬនៅ?

**លោក ស៊ា ម៉ៅ៖**

ជម្រាបប្រសាសន៍ឯកឧត្តមប្រធាន, នៅថ្ងៃនេះគឺភាគីចូលគ្រប់ចំនួន។ ក៏ប៉ុន្តែ អវត្តមានខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺមានលោក ខារីម ខាន អវត្តមាន។ លោកស្រី ម៉ុច សុវណ្ណារី អវត្តមាន និងលោកមេធាវី គឹម ម៉េងឃី អវត្តមាន។

[០៩:០១:០៣]

**ប្រធានអង្គជំនុំ៖**

មុននឹងចាប់ផ្តើមចូលដល់វគ្គទីពីរនេះ គឺខ្ញុំសូមជម្រាបទៅដល់ភាគីនិងមេធាវីឲ្យបានជ្រាបថា ការថ្លែងរបស់អស់លោកគឺសូមឲ្យយឺតៗ ដើម្បីសម្រួលដល់កិច្ចការបកប្រែរបស់អ្នកបកប្រែផង។

ជាបន្តទៅនេះ ខ្ញុំសូមអញ្ជើញចៅក្រមរបាយការណ៍អានរបាយការណ៍ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ សូមអញ្ជើញ!

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណលោកប្រធាន មូលដ្ឋានទីពីរគឺថា សាលាដំបូងមានកំហុសក្នុងច្បាប់នៅពេលដែលដាក់ចូលនៅក្នុងបទប្រឆាំងមនុស្សជាតិ។ សហព្រះរាជអាជ្ញាត្រូវបានកាត់ទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានរកឃើញថាគាត់ទទួលខុសត្រូវ។ យើងសូមរំឭកថា សាលក្រមរបស់សាលាដំបូងរកឃើញជនជាប់ចោទទទួលខុសត្រូវចំពោះបទល្មើសដូចខាងក្រោម គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មនុស្សឃាត ការដាក់ជាទាសករ ការឃុំឃាំង ការធ្វើទារុណកម្ម ហើយនិងការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយឈរលើមូលដ្ឋាននយោបាយ និងអំពើអមនុស្សធម៌។

[០៩:០២:៤៣]

សាលាដំបូងធ្វើការកាត់ទោសជនជាប់ចោទដោយសារមូលហេតុនយោបាយ ហើយបានបញ្ចូលនៅក្នុងការកាត់ទោសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ និយាយជារួម ដូចដែលទឡ្ហីករណ៍បានតវ៉ានៅចំពោះមុខយើង យើងរកឃើញថាសហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះមានកំហុសដោយឈរទៅលើមូលដ្ឋាននយោបាយ ហើយរកឃើញថាជនជាប់ចោទទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

[០៩:០៣:១៧]

សហព្រះរាជអាជ្ញាតវ៉ាថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនីមួយៗដែលជនជាប់ចោទទទួលខុសត្រូវវាមានលក្ខណៈខុស ហើយមិនរកឃើញ-- មិនមានឃើញនៅក្នុងធាតុផ្សំដទៃៗទៀត។ សាលាដំបូងខកខានមិនបានចោទប្រកាន់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃៗទៀត ដែលវាពាក់ព័ន្ធទៅនឹងការកាត់ទោសត្រួត។ ដូច្នេះហើយវាមិនបានឆ្លុះបញ្ចាំងពីការទទួលខុសត្រូវរបស់ជនជាប់ចោទ និងការពាក់ព័ន្ធរបស់គាត់នៅក្នុងឧក្រិដ្ឋកម្ម។ សហព្រះរាជាអាជ្ញាបានលើកឡើងទៀតថា នៅពេលដែលមិនមានកាត់ទោសត្រួតនេះ ដោយអនុលោមទៅតាមយុត្តិសាស្ត្រអន្តរជាតិមិនគួរយកមកអនុវត្តនៅក្នុងនេះទេ។ ជាពិសេសសហព្រះរាជអាជ្ញារកឃើញថា ជនជាប់ចោទមិនទទួលបានការអត់ឱនទោសទេ ហើយជនជាប់ចោទគួរតែទទួលការកាត់ចំពោះបទល្មើសដទៃៗទៀត។

[០៩:០៤:១៩]

សាលាដំបូងមិនបានគិតអំពីផលប្រយោជន៍ដូចដែលមានរៀបរាប់នៅក្នុងហ្នឹង ហើយអំពីព្រហ្មទណ្ឌរបស់ជនជាប់ចោទត្រូវតែគិតអំពីបញ្ហាប្រវត្តិសាស្ត្រផងដែរ។ សហព្រះរាជអាជ្ញាបានលើកឡើងទៀតថា សាលាដំបូងមានកំហុសអង្គច្បាប់ដោយសារតែយកបញ្ចូលឧក្រិដ្ឋកម្មរំលោភយកមកដាក់នៅក្នុងការធ្វើទារុណកម្ម ហើយគិតថាការរំលោភសេពសន្ថវៈនោះគឺជាប្រភេទនៃការធ្វើទារុណកម្ម។

សហព្រះរាជអាជ្ញាសុំឲ្យកាត់ជនជាប់ចោទចំពោះបទរំលោភនៅក្នុងឧក្រិដ្ឋប្រឆាំងមនុស្សជាតិ។ មិនមានសេចក្តីសន្និដ្ឋានតបដាក់ជូនចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានោះទេ។ ចំពោះបណ្តឹងសាទុក្ខនេះ តុលាការកំពូលសូមលើកឡើងអំពីការកាត់ទោសជាច្រើនបទចោទ ជាពិសេសការលើកឡើងរបស់សហព្រះរាជអាជ្ញាដោយផ្អែកទៅលើនិយមន័យនៃច្បាប់ព្រហ្មទណ្ឌ។ ដូច្នេះហើយ បណ្តឹងសាទុក្ខនេះវាពាក់ព័ន្ធទៅនឹងការកាត់ទោស ហើយអង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើការពិនិត្យទៅលើស្ថានភាព

ទាំងអស់នេះ ហើយនិងធ្វើការពិនិត្យទៅលើនិយមន័យដែលពាក់ព័ន្ធនឹងយុត្តាធិការរបស់តុលាការនេះ ហើយជាពិសេសនឹងគិតថា តុលាការកំពូលនឹងពិចារណាទៅលើការដាក់ទោស។

[០៩:០៥:៥៥]

ដោយសារហេតុនេះហើយ អង្គជំនុំជម្រះផ្តល់ទៅដល់ភាគីឲ្យលើកអំពីសញ្ញាណអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការធ្វើទុក្ខបុកម្នេញ ការដាក់ជាទាសករ និងការរំលោភសេពសន្ថវៈ។

ទឡ្ហីករណ៍ទីបីនៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងផ្នែកច្បាប់ ដោយកំណត់និយមន័យពុំបានត្រឹមត្រូវលើពាក្យ “ការធ្វើឲ្យទៅជាទាសករ” ហើយជាលទ្ធផលអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានផ្តន្ទាទោសជនជាប់ចោទពីបទធ្វើឲ្យទៅជាទាសករនៃអ្នកទោសទាំងអស់នៅមន្ទីរស-២១ ឡើយ។

[០៩:០៦:៣៧]

ពាក់ព័ន្ធទៅនឹងបទចោទប្រកាន់ស្តីពីការដែលធ្វើឲ្យទៅជាទាសករក្នុងសំណុំរឿងលេខ០០១ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថាតាមដីកាដំណោះស្រាយ ការធ្វើឲ្យទៅជាទាសករមានអត្ថន័យដូចខាងក្រោម៖

អ្នកទោសមួយចំនួននៃមន្ទីរស-២១ និងមន្ទីរស-២៤ ត្រូវបានគេបង្ខំឲ្យធ្វើការ។ គ្រប់ទិដ្ឋភាពនៃការរស់នៅរបស់ពួកគេត្រូវបានឃាមកាមយ៉ាងតឹងរ៉ឹងតាមរយៈការកម្រិតលើការដើរហើរ និងកន្លែងរស់នៅ ការចាត់វិធានការទប់ស្កាត់និងរារាំងក្នុងការរត់គេចខ្លួន និងធ្វើឲ្យពួកគេទទួលបាននូវការធ្វើបាបនិងការបំពានយ៉ាងឃោរឃៅ។ ដោយសារអំពើទាំងនេះ អ្នកទោសត្រូវបានគេដកហូតនូវសិទ្ធិសេរីភាព។

[០៩:០៧:២០]

អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សនិងការធ្វើឲ្យទៅជាទាសករត្រូវបានកំណត់ចរិតលក្ខណៈតាមរយៈនៃការប្រើអំណាចនេះមួយ ឬទាំងអស់ចារីក្នុងនាមជាម្ចាស់កម្មសិទ្ធិលើបុគ្គលណាម្នាក់។ អង្គជំនុំជម្រះសាលាដំបូងរាប់បញ្ចូលការធ្វើពលកម្មដោយបង្ខំជាសញ្ញាមួយនៃការធ្វើឲ្យទៅជាទាសករ ហើយក៏បានបញ្ជាក់ផងដែរថា ការធ្វើពលកម្មដោយបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្តអាចបង្កើតជាធាតុផ្សំនៃការធ្វើឲ្យទៅជាទាសករ។

អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បុគ្គលិកមន្ទីរស-២១ បានអនុវត្តអំណាចដោយចេតនានិងគ្រប់គ្រងទាំងស្រុងលើអ្នកទោសនៅស-២៤ និងអ្នកទោសមួយចំនួនតូចនៅក្នុងមន្ទីរស-២១ ដែល

ត្រូវបានចាត់តាំងឲ្យធ្វើការក្នុងបរិវេណមន្ទីរស-២១ នោះ។

អ្នកទោសទាំងនេះមិនមានសិទ្ធិសេរីភាពបដិសេធមិនធ្វើការងារ ដែលគេចាត់តាំងឲ្យពួកគេនោះឡើយ ហើយមិនបានយល់ព្រមជាមួយនឹងលក្ខខណ្ឌនៃការឃុំខ្លួនរបស់ពួកគេដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការធ្វើពលកម្មដោយបង្ខំ ឬដោយគ្មានការស្ម័គ្រ ដោយបូករួមជាមួយនឹងការឃុំខ្លួនរបស់ពួកគេបង្កើតបានជាទោជាទាសករ។

[០៩:០៨:៣៥]

សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងផ្នែកច្បាប់ ដោយកំណត់ធ្វើពលកម្មដោយបង្ខំ ឬការគ្មានការស្ម័គ្រចិត្តជាធាតុផ្សំចាំបាច់នៃការធ្វើឲ្យទៅជាទាសករជាជាងសញ្ញានៃការធ្វើឲ្យទៅជាទាសករ។

សហព្រះរាជអាជ្ញាលើកឡើងថា ដោយសារតែការកំណត់និយមន័យនៃពាក្យ "ធ្វើឲ្យទៅជាទាសករ" មិនបានត្រឹមត្រូវ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានផ្តន្ទាទោសជនជាប់ចោទស្តីពីការធ្វើឲ្យទៅជាទាសករនូវក្រុមអ្នកទោសដ៏ធំ គឺអ្នកទោសទាំងអស់នៅក្នុងមន្ទីរស-២១ ដោយគ្មានគិតដល់ពួកគាត់ត្រូវបានទទួលរងការធ្វើពលកម្មដោយបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្តនោះឡើយ។

[០៩:០៩:១៨]

យោងតាមសហព្រះរាជអាជ្ញាសាលក្រមសាលាដំបូងបង្ហាញនូវសំអាងហេតុយ៉ាងគ្រប់គ្រាន់ថា អំណាចនានាដែលភ្ជាប់ទៅនឹងសិទ្ធិនៃកម្មសិទ្ធិត្រូវបានអនុវត្តនៅក្នុងមន្ទីរស-២១ ដែលបំពេញនូវលក្ខខណ្ឌ និងនិយមន័យនៃពាក្យ "ការធ្វើឲ្យទៅជាទាសករ" ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

បន្ថែមលើនេះ អំពើទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយចេតនា និងក្នុងគោលបំណងអនុវត្តនូវកម្មសិទ្ធិលើអ្នកទោស។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលផ្តន្ទាទោសជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃការធ្វើឲ្យទៅជាទាសករពាក់ព័ន្ធទៅនឹងអ្នកទោសទាំងអស់នៅក្នុងមន្ទីរស-២១ ដោយពុំចាំបាច់ពិចារណាថា ពួកគាត់ត្រូវបានទទួលរងការបង្ខំដោយពលកម្ម ឬដោយគ្មានការស្ម័គ្រចិត្តនោះឡើយ។ គ្មានចម្លើយតបជាលាយលក្ខណ៍អក្សរត្រូវបានធ្វើឡើងតបទៅនឹងបណ្តឹងសាទុក្ខរបស់ព្រះរាជអាជ្ញាឡើយ។

សូមអរគុណ។

[០៩:១០:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្តីថ្លែងទាក់ទងសារណាបណ្តឹងសាទុក្ខ។

**លោក អាន់ឌ្រូ ខេលី៖**

សូមអនុញ្ញាត សូមគោរពលោកប្រធាន អស់លោក លោកស្រី ចៅក្រម និងភាគី មេធាវី សហព្រះរាជអាជ្ញាទាំងអស់។ នៅក្នុងរយៈពេល៤៥នាទីនេះ ខ្ញុំនឹងព្យាយាមលើកឡើងអំពីចំណុចទាំងឡាយដែលបានបញ្ជាក់អម្បាញ់មិញ។ វាជាបញ្ហាយ៉ាងសំខាន់ ហើយខ្ញុំនឹងបញ្ជាក់ទៅលើចំណុចនេះ ហើយដើម្បីបញ្ជាក់ស៊ីជម្រៅទៅលើបញ្ហាទាំងឡាយដែលលើកឡើងដោយចៅក្រមរបាយការណ៍។

[០៩:១១:០៨]

ចំណុចទីមួយដែលខ្ញុំសូមលើកឡើង គឺពាក់ព័ន្ធទៅនឹងការកាត់ទោសត្រួតចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ចំពោះចំណុចនេះ ដែលបានសួរមកកាន់សហព្រះរាជអាជ្ញា ខ្ញុំនឹងមិនលើកឡើងលើកថាខណ្ឌ១៣៤ និង១៩១ នៃសារណារបស់យើងនោះទេ ប៉ុន្តែយើងខ្ញុំសូមឲ្យចៅក្រមធ្វើការពិចារណាលើកថាខណ្ឌទាំងពីរនេះ។

[០៩:១១:៣៨]

អ្វីដែលខ្ញុំព្យាយាមនៅពេលនេះ សូមលើកឡើងអំពីមូលដ្ឋានផ្លូវច្បាប់ចំពោះការកាត់ទោសត្រួត ហើយបន្ទាប់មក ខ្ញុំនឹងពិភាក្សាលើកឡើងដោយសង្ខេបទៅលើការដាក់ទោស។ ទឡ្ហីករណ៍របស់យើងខ្ញុំគឺលើកឡើងដោយសង្ខេបនិងសាមញ្ញ។ ការបកស្រាយរបស់សាលាដំបូងនៅក្នុងសាលក្រមជាពិសេសពាក់ព័ន្ធទៅនឹងការកាត់ទោសត្រួតនោះ គឺមានកំហុស។ ការបកស្រាយច្បាប់នេះគឺវាអាចឃើញនៅក្នុងកថាខណ្ឌ៥៦១ នៃសាលក្រមសាលាដំបូង។ ជាពិសេស សាលាដំបូងបានសម្រេចដោយមិនយកចិត្តទុកដាក់អំពីសេចក្តីសម្រេចនៅក្នុងឆ្នាំ២០០៤ លើករណី ខូឌីកស៍។ ជាពិសេសនៅក្នុងឯកសាររបស់យើងលេខ៧១ នៃបណ្តឹងសាទុក្ខ។ ហេតុអ្វីបានជាសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញនេះមិនមានកាតព្វកិច្ចគោរពតាមយុត្តិសាស្ត្រ។

[០៩:១២:៤៦]

យើងឃើញសេចក្តីសម្រេចនៅក្នុងករណីទាំងអស់នោះ វាបានបង្ហាញទៅលើបញ្ហានៃការកាត់ទោសត្រួតនេះ។ ដោយភាពស៊ីសង្វាក់គ្នាទៅលើចំណុចនេះ ជាពិសេសទៅលើនិត្យានុកូលភាព ខ្ញុំសូមអនុញ្ញាតលើកឡើងថា សាលាដំបូងគួរតែអនុវត្តតាមសេចក្តីសម្រេចភាគច្រើនក្នុងករណីទាំងអស់ដូច

ដែលខ្ញុំបានបញ្ជាក់។ តុលាការនេះ គឺជាតុលាការក្នុងស្រុកវាមានលក្ខណៈជាអន្តរជាតិផងដែរ។

តុលាការនេះនឹងធ្វើការស្តាប់ទៅលើរឿងក្តីមួយចំនួន ហើយនិងអ្នកស្រាវជ្រាវច្បាប់និងតុលាការព្រហ្មទណ្ឌដទៃៗទៀត យើងគួរតែពិចារណាថា យើងនឹងយល់ថាគេនឹងយកតុលាការទាំងអស់ដោយផ្អែកទៅលើមូលដ្ឋានផ្លូវច្បាប់ លើច្បាប់ព្រហ្មទណ្ឌអន្តរជាតិផងដែរ។ ដូច្នេះហើយ ខ្ញុំសូមបញ្ជាក់ថាយើងមានកាតព្វកិច្ច យើងគួរតែធ្វើការបង្កើតវិធាន សំណុំនៃវិធានឲ្យស្របគ្នាទៅនឹងអន្តរជាតិ។

[០៩:១៣:៤៧]

មុនពេលដែលយើងពិចារណាទៅលើ ខូឌីកស៍ ខ្ញុំសូមលើកឡើងដោយសង្ខេបថា តើអ្វីទៅគឺជាការកាត់ទោសត្រួត? វាមានន័យថា ដូចដែលចៅក្រម មីឡាត លើកឡើង ការចោទប្រកាន់ទៅលើបុគ្គលមួយរូបទៅលើអំពើជាច្រើន។ ហេតុអ្វីបានជាជនជាប់ចោទធ្វើការកាត់ទោសត្រួតទៅលើអំពើរបស់ខ្លួន? ដូចដែលលោកចៅក្រម មីឡាត លើកឡើង "ការចោទប្រកាន់ច្រើននោះគឺយើងទទួលស្គាល់អំពីផលប្រយោជន៍ជាច្រើន" ហើយចំណុចដែលសំខាន់នោះតុលាការនេះ យើងឃើញថា វាជាតុលាការដែលយើងត្រូវការកត់ជាលក្ខណៈប្រវត្តិសាស្ត្រទៅលើការកាត់ទោសអំពីការទទួលខុសត្រូវ។

[០៩:១៤:៤៥]

បញ្ហាទាំងពីរនេះ គឺជាបញ្ហាច្បាប់ ហើយយើងខ្ញុំលើកឡើងនៅក្នុងសារណារបស់យើងខ្ញុំ ហើយក៏ឃើញមាននៅក្នុងយុត្តិសាស្ត្រអន្តរជាតិ។ ខ្ញុំនឹងមិនលើកយុត្តិសាស្ត្រទាំងអស់ទេ ប៉ុន្តែយើងឃើញមានគោលការណ៍មួយចំនួនដែលលើកឡើងនៅក្នុងកថាខណ្ឌ៣៤៧ ក្នុងករណី ម៉ូស៊ីម៉ា ដែលមាននៅក្នុងតារាងឯកសាររបស់យើងលេខ៩០ រួមទាំងករណី អាយ៉េស្សា អាកាយ៉េស៊ុ នៅក្នុងឯកសាររបស់យើងលេខ៨៤ ដែល លើកឡើងនៅក្នុងកថាខណ្ឌ៤៦៨ នៃរឿងក្តី *អាកាយ៉េស៊ុ* នោះ។

[០៩:១៥:៣៤]

ខ្ញុំសូមបញ្ជាក់ត្រង់ចំណុចនេះថា តុលាការយូហ្គោស្លាវី មានការចោទប្រកាន់ជនជាប់ចោទ ១៦០នាក់ នៅពេលដែលវាពាក់ព័ន្ធទៅនឹងអំពើអ្នកទាំងអស់នោះ។ ដូច្នេះ តុលាការនោះគឺបានបង្ហាញអំពីប្រវត្តិសាស្ត្រ ការកត់ត្រាប្រវត្តិសាស្ត្រមួយដ៏ត្រឹមត្រូវដែលគេចោទប្រកាន់ទៅលើបទល្មើសទាំងអស់នោះ មិនថាបទល្មើសនោះត្រូវបានកាត់ទោស ឬក៏កាត់ឲ្យជាប់ទោស ឬកាត់ឲ្យរួចខ្លួននោះទេ។

យើងឃើញឧក្រិដ្ឋកម្មនៅក្នុងយូហ្គោស្លាវី ត្រូវបានគេទទួលស្គាល់ក្នុងការចោទប្រកាន់ទៅលើជនជាប់ចោទ។ ខ្ញុំសូមលើកឡើងនៅក្នុងករណីនេះ។ សាលក្រមរបស់សាលាដំបូងបានរកឃើញថាជន

ជាប់ចោទរូបនេះ ដែលគាត់ជាអ្នកធ្វើការប្រព្រឹត្តទៅលើកូនក្មេងនិងមនុស្សនានានោះ មានការរើតប់ ការចាក់សម្លាប់ និងការបូមឈាម និងការដាក់ប្រជាជនឲ្យទៅជាទាសករ ការឃុំខ្លួន។

ដូច្នេះហើយ យើងឃើញមានការឈឺចាប់ មនុស្សទាំងឡាយត្រូវបានដកហូតនូវការទទួលការកាត់ទោស ហើយយើងឃើញថាការសម្លាប់នោះវាមានការធ្វើឡើងចំពោះមនុស្សជាង១២.០០០នាក់ ដូចដែលយើងនៅទីនេះ ក្នុងថ្ងៃនេះ យើងឃើញថាមានការកាត់ទោស ដាក់ទោសតែចំនួនជារួមមួយតែប៉ុណ្ណោះទៅលើជនជាប់ចោទរូបនេះ។ ដូច្នេះហើយ វាមិនទទួលស្គាល់ទៅផលប្រយោជន៍ទាំងឡាយដែលជននេះបានធ្វើឡើងចំពោះប្រជាជននោះឡើយ។ ហើយយើងដឹងហើយថា យើងត្រូវគិតអំពីការផ្សះផ្សាជាតិ ប៉ុន្តែយើងត្រូវបង្ហាញទៅលើមនុស្សជំនាន់ក្រោយយ៉ាងម៉េច ចំពោះការប្រព្រឹត្ត របស់ជនរូបនេះទៅលើប្រជាពលរដ្ឋ?

ដូច្នេះ ខ្ញុំស្នើសុំតុលាការកំពូលឲ្យពិចារណាទៅលើចំណុចទាំងអស់នេះ នៅពេលដែលសម្រេចទៅលើទោស។

[០៩:១៧:៤៥]

នៅពេលនេះ ខ្ញុំសូមលើកឡើងអំពីលក្ខខណ្ឌផ្លូវច្បាប់។ លក្ខខណ្ឌផ្លូវច្បាប់ឃើញមានលើកឡើងនៅក្នុងសេចក្ដីសម្រេច ឆាលីប៊ីហ្ស៊ី ដែលលើកឡើងរវាងសហព្រះរាជអាជ្ញា និងតុលាការយូហ្គោស្លាវី វាមានលេខឯកសារ៨៣ នៅក្នុងតារាងឯកសាររបស់យើង។

ការកាត់ទោសទៅលើបទចោទជាច្រើន គឺយើងឃើញមានលើកឡើងនៅក្នុងបទប្បញ្ញត្តិ ប៉ុន្តែក៏គេផ្អែកទៅលើទង្វើរួម ហើយគេអាចឲ្យធ្វើទៅបាន ប្រសិនបើបទប្បញ្ញត្តិទាំងអស់នោះវាមានលក្ខណៈនិងធាតុដូចៗគ្នា និងធាតុផ្សេងៗគ្នា។

[០៩:១៨:២៨]

ធាតុខុសៗគ្នានេះ គឺវាតម្រូវឲ្យមានការបង្ហាញទៅលើអង្គហេតុដែលវាមិនតម្រូវឲ្យមានការបង្ហាញទៅលើចំណុចដទៃៗទៀត។ ខ្ញុំគិតថា អ្វីដែលខ្ញុំលើកឡើងនឹងបង្ហាញអំពីលក្ខខណ្ឌផ្លូវច្បាប់នេះ ហើយលក្ខខណ្ឌនឹងបង្ហាញនៅក្នុងកថាខណ្ឌ៤១២ នៃសេចក្ដីសម្រេច។ ដូច្នេះ យើងគួរតែលើកឡើងថានៅក្នុងរយៈពេលដែលគេធ្វើការជំនុំជម្រះនៅក្នុងយូហ្គោស្លាវី គេមានការលើកឡើងខុសៗគ្នារវាងលក្ខខណ្ឌផ្លូវច្បាប់នេះ។ ប៉ុន្តែអ្វីដែលយើងអាចលើកឡើងបាននោះ អ្វីដែលខ្ញុំលើកឡើងនៅក្នុងសារណា ច្បាប់គេមានចែងនៅក្នុងសេចក្ដីសម្រេចឆ្នាំ២០០៤ របស់តុលាការយូហ្គោស្លាវី ដែលខ្ញុំលើកឡើងអំពីករណី

ខូឌីកស៍ នោះឯង។

[០៩:១៩:២២]

តុលាការកំពូលនៅទីនោះបានលើកឡើងករណីនេះថា អ្វីដែលជាលក្ខខណ្ឌទាមទារ គឺត្រូវពិនិត្យទៅលើបញ្ហាអង្គច្បាប់ និងធាតុនៃបទល្មើសនីមួយៗនៅក្នុងលក្ខន្តិកៈដែលវាពាក់ព័ន្ធទៅនឹងទង្វើរបស់ជនជាប់ចោទ ដែលត្រូវបានគេកាត់ទោស។

ដូច្នេះ យើងត្រូវយកមកពិចារណាថា តើបទល្មើសចោទប្រកាន់នីមួយៗ វាមានធាតុសត្យានុម័តិខុសគ្នាដែរឬទេ ដែលមិនមាននៅក្នុងបទល្មើសមួយៗទៀត។ ដូច្នេះហើយ តើធាតុនោះវាមានតម្រូវ ធាតុផ្សំនោះវាតម្រូវឲ្យធ្វើការបង្ហាញ ដែលវាមិនជាលក្ខខណ្ឌទាមទារនៅក្នុងបទល្មើសដទៃៗទៀតដែរឬទេ? វាមានលើកឡើងចំណុចនេះនៅក្នុងកថាខណ្ឌ១៤០០ នៃសេចក្ដីសម្រេច។

[០៩:២០:១៤]

កថាខណ្ឌ១៤០១ --១០៤១ ដែលក្នុងនោះលើកឡើងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញ និងការធ្វើមនុស្សឃាត។ ចៅក្រមនៅទីនោះបានលើកឡើងថា ការទុក្ខបុកម្នេញមានធាតុចំនួនពីរ។ ទីមួយ ត្រូវការបង្ហាញអំពីអំពើ ឬការខកខានទៅលើការប្រព្រឹត្ត។ ទីពីរ អំពើ និងការខកខាន ដែលក្នុងនោះចេតនាក្នុងការរើសអើង។ ធាតុផ្សំទាំងពីរនៃបទធ្វើទុក្ខបុកម្នេញនេះវាមានលក្ខណៈខុសគ្នា។

[០៩:២០:៤៤]

ចៅក្រមនៅទីនោះ គាត់បានលើកឡើងអំពីធាតុនៃមនុស្សឃាត។ ធាតុនៃមនុស្សឃាត គឺវាមានធាតុដែលខុសគ្នាពីធាតុនៃការធ្វើទុក្ខបុកម្នេញ។ ធាតុនៃមនុស្សឃាតនោះ គឺពាក់ព័ន្ធទៅនឹងជនជាប់ចោទដែលធ្វើឲ្យមនុស្សទាំងឡាយស្លាប់ ហើយដែលវាមានធាតុមួយខុសពីការធ្វើទុក្ខបុកម្នេញ។

ចៅក្រមនៅក្នុងរឿងក្ដីនោះ បានពិចារណាទៅលើធាតុផ្សំទាំងឡាយដែលមាននៅក្នុងបទល្មើស ហើយរកឃើញថា អំពើទាំងពីរនោះ វាមានធាតុសត្យានុម័តិខុសគ្នា។ លក្ខខណ្ឌនេះ ត្រូវបានគេយកមកអនុវត្តថ្មីៗនេះ កាលពីឆ្នាំមុននៅក្នុងករណី *ឆ្លូបធីប៊ីចស៍* ជាពិសេសសេសសេចក្ដីសម្រេចរបស់តុលាការយូហ្គោស្លាវី លោក លោកស្រីចៅក្រមនឹងរកឃើញនៅក្នុងឯកសារលេខ៧៨ នៃតារាងរបស់យើង។

នៅក្នុងសេចក្ដីសម្រេចនោះ គឺបានបង្ហាញថា បទល្មើសទាំងពីរ អំពើទាំងពីរនេះ គឺមិនអាចមានធាតុដូចគ្នានោះឡើយ។ ការសម្លាប់រង្គាល និងការធ្វើមនុស្សឃាត យើងឃើញថាវាមានធាតុផ្សំខុសគ្នា។

ឃាតកម្ម គួរតែបញ្ចូលនៅក្នុងធាតុនៃការសម្លាប់រង្គាល។ យើងឃើញមាននៅក្នុងសេចក្តីសម្រេចដែលខ្ញុំបានលើកឡើងករណី *ផ្លបធីប៊ិចស៍* ។ ការកាត់ទោស សហព្រះរាជអាជ្ញា ត្រូវបានចោទសួរឲ្យបង្ហាញអំពីករណីនេះពាក់ព័ន្ធទៅនឹងការដាក់ទោស។ ករណី *ឆេឡឺប៊ីហ្សុី* ដែលខ្ញុំបានលើកឡើងនោះ វាជាបទដ្ឋានមួយណែនាំ ពាក់ព័ន្ធទៅនឹងការដាក់ទោស។

[០៩:២២:៣៩]

យុត្តិសាស្ត្រនេះ គឺវាបានលើកឡើងអំពីសេចក្តីសង្ខេបនៃការអនុវត្តមួយចំនួននៅតាមតុលាការនានា ហើយនៅក្នុងនុំងគេបានពិចារណាទៅលើច្បាប់ទៅលើច្បាប់ខំមិនឡ និងច្បាប់ស៊ីវិលឡ ហើយគេបានទាញការសន្និដ្ឋានថា ការដាក់ទោសចំពោះការកាត់ទោសខ្លួននោះ គឺធ្វើឡើងជាលក្ខណៈសាកលហើយគេធ្វើឡើងចំពោះបទល្មើសមួយចំនួន ហើយទោសនោះគឺវាអាច គេអាចធ្វើក្នុងករណីធ្វើជាទោសស្រប ឬក៏ទោសត្រួតបាន។

ដូចដែលលោក លោកស្រីចៅក្រមយល់ហើយនៅក្នុងករណីនោះ គេបានធ្វើការដាក់ទោសជាលក្ខណៈសាកលមួយទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការរំលោភបំពានធ្ងន់ធ្ងរ។ បញ្ហាមួយដែលខ្ញុំលើកឡើងក្នុងសារណារបស់ខ្ញុំនោះ គឺមិនមែនជាកត្តាមួយដែលវាអាចជាអានុភាពទៅលើករណីរឿងក្តីរបស់យើងទេ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការធ្វើទុក្ខបុកម្នេញ វាទាមទារឲ្យមានធាតុចេតនារើសអើង។

[០៩:២៣:៥៤]

អំពើនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃៗទៀតនោះ ដែលយើងបានដាក់បញ្ចូល ហើយយើងរកឃើញការទទួលខុសត្រូវរបស់ជនជាប់ចោទរូបនេះ គឺយើងមិនតម្រូវឲ្យមានការបង្ហាញធាតុផ្សំនៃចេតនារើសអើងនោះទេ។

អង្គជំនុំជម្រះសាលាដំបូងទីពីរនៅទីនោះ គេបានលើកឡើងថា ការធ្វើទុក្ខបុកម្នេញ ប្រសិនបើមានធាតុផ្សំនោះ វាជាស្ថានទម្ងន់មួយចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

[០៩:២៤:២៤]

តុលាការកំពូលក៏បានចោទសួរយើងខ្ញុំឲ្យលើកឡើងអំពីការកាត់ទោសត្រួត។ ជំហររបស់យើងខ្ញុំគឺយើងខ្ញុំចង់បង្ហាញថា ក្នុងករណីណាក៏ដោយក៏វាមិនពាក់ព័ន្ធទៅនឹងករណីជនជាប់ចោទនេះ។

ដូច្នេះហើយយើងខ្ញុំគិតថា យើងមិនអាចឲ្យជននេះរួចខ្លួនបានឡើយ។ តុលាការកំពូលត្រូវការ

អនុវត្តទោស និងការកំណត់ទោសចំពោះករណីនេះ។ នៅក្នុងតុលាការដទៃៗទៀត នៅពេលដែលគេអនុវត្តទោសចំពោះការកាត់ទោសត្រួតដូចដែលបានកំណត់ដោយតុលាការរបស់គេ យើងឃើញថា ការកាត់ទោសត្រួតនោះស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការទាំងអស់នោះ ហើយវាមានអានុភាពប៉ះពាល់ទៅដល់ជនជាប់ចោទរូបនេះ។

[០៩:២៥:៣៩]

ដូច្នេះ ចៅក្រមចំនួនពីររូបនៅក្នុងតុលាការយូហ្គោស្លាវី បានបង្ហាញអំពីច្បាប់ទៅលើបទល្មើស ហើយយើងឃើញមានការព្រួយបារម្ភយ៉ាងមានសុពលភាពទៅលើជនជាប់ចោទទាំងអស់នោះ នៅពេលដែលជនជាប់ចោទត្រូវបានកាត់ទោស អំពីទោសជាច្រើននោះ គេត្រូវអនុវត្ត ហើយគេមានទោសទណ្ឌមួយជាក់លាក់ចំពោះការកាត់ទោសលើបទល្មើសជាច្រើនបទល្មើសនេះ។

ដូច្នេះ ច្បាប់ទាំងអស់នោះ គឺយើងឃើញគេអនុវត្តនៅក្នុងតុលាការ រវ៉ាន់ដា និងយូហ្គោស្លាវី ដើម្បីអនុញ្ញាតឲ្យជនជាប់ចោទគាត់អាចអនុវត្តទៅតាមទោសដែលគេបានកំណត់។

[០៩:២៦:៣៧]

នៅពេលនេះខ្ញុំសូមលើកឡើងអំពីការរំលោភសេពសន្ថវៈ ដែលជាប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយ។ តុលាការកំពូលបានចោទសួរថា តើការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មមួយសាហាវនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬទេ អនុលោមតាមច្បាប់អន្តរជាតិ?

មូលដ្ឋាននៃបណ្ដឹងសាទុក្ខរបស់យើងមានសរសេរនៅក្នុងកថាខណ្ឌ១៩៦ និង២០៨។ ដូច្នេះ ខ្ញុំសូមចាប់ផ្ដើមលើកឡើងថា សាលាដំបូងបានរកឃើញថា ការរំលោភសេពសន្ថវៈគឺជា វាជាបទល្មើសមួយដាច់ដោយឡែក ដែលទទួលស្គាល់នៅក្នុងច្បាប់ អ..វ.ត.ក និងច្បាប់អន្តរជាតិ។

[០៩:២៧:២២]

នៅពេលដែលខ្ញុំលើកឡើងចំណុចនេះ គឺខ្ញុំមិនធ្វើការជំទាស់ទៅលើការរកឃើញនៅក្នុងសាលក្រមរបស់សាលាដំបូង កថាខណ្ឌ៣៦៨ នោះទេ។ សាលាដំបូងបានសម្រេចថាមានករណីរំលោភសេពសន្ថវៈមួយដែលអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអំពើធ្វើទារុណកម្ម។

យើងខ្ញុំសូមលើកឡើងថា សាលាដំបូងមានកំហុសអង្គច្បាប់នៅពេលដែលមិនបានចោទប្រកាន់កាត់ទោសជនជាប់ចោទរូបនេះ អំពីបទរំលោភ។

បទល្មើសរំលោភ ជាប្រភេទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺវាមានលក្ខណៈដូចគ្នា នៅពេល

ដែលបញ្ចូលនៅក្នុងការធ្វើទារុណកម្ម ប្រសិនបើវាមានលក្ខខណ្ឌដូចគ្នា។ លក្ខខណ្ឌដែលខ្ញុំលើកឡើងនៅទីនេះ យើងឃើញមានលក្ខណៈតឹងរ៉ឹងចំពោះការរំលោភសេពសន្ថវៈនៅពេលដែលយើងចង់បញ្ចូលនៅក្នុងអំពើល្មើសទារុណកម្មនោះ។

[០៩:២៨:២៤]

នៅក្នុងករណីរបស់យើង នៅពេលដែលយើងបង្ហាញអំពីធាតុផ្សំនៃអំពើទារុណកម្ម យើងឃើញថាមិនមានផលប៉ះពាល់ទៅដល់ជនជាប់ចោទរូបនេះទេ ប្រសិនបើយើងធ្វើការចោទប្រកាន់កាត់ទោសអំពីការរំលោភសេពសន្ថវៈដោយផ្ទុះបញ្ចាំងអំពីទង្វើរបស់ជននេះ។

យើងបានទទួលស្គាល់ថា នៅក្នុងសេចក្តីសម្រេចថ្មីៗនេះ របស់អង្គបុរេជំនុំជម្រះនៅក្នុងករណីទីពីរដែលតុលាការនេះនឹងលើកមកជំនុំជម្រះ គឺការពិនិត្យមើលថា តើបទរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មគួរឲ្យស្អប់ខ្ពើមប្រឆាំងទៅនឹងមនុស្សជាតិ ឬក៏យ៉ាងណាដែរនោះ?

[០៩:២៩:០៥]

អង្គបុរេជំនុំជម្រះ ក្នុងរឿងក្តីនេះ គឺបានរកបានរកឃើញថា បទរំលោភសេពសន្ថវៈ គឺថាជាបទល្មើសមួយ។ ប៉ុន្តែត្រូវតែផ្តន្ទាទោស ដែលស្ថិតនៅក្នុងប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ-- យើងបានលើកយកបញ្ហានេះ ដោយកំណត់នូវចរិតលក្ខណៈវា ហើយអនុវត្តនូវគោលការណ៍នៃនីត្យានុកូលភាព។ ហើយទឡ្ហីករណ៍របស់យើងគឺងាយទេ ដោយសារថា គោលការណ៍នីត្យានុកូលភាពមិនតម្រូវថាឧក្រិដ្ឋកម្មនេះ គឺត្រូវមានចែងនៅក្នុងពាក្យពេចន៍មួយដែលមានច្បាស់លាស់នោះទេ ឲ្យតែមានហេតុផលដែលយល់ជាមុនបាន និងវាយតម្លៃជាមុនបានចំពោះជនជាប់ចោទ ដែលថាអំពើជាក់លាក់មួយចំនួនឬក៏ការខកខាន គឺមានចែងកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

[០៩:៣០:០០]

ដូចដែលបានចែងរួចមកហើយ គឺថាអំពើរំលោភសេពសន្ថវៈអាចបង្កើតបានទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងឆ្នាំ១៩៧៥ ដល់ ៧៩ គឺថាមិនមានការពាក់ព័ន្ធ ថាតើអំពើនេះត្រូវចោទប្រកាន់នៅក្រោមបទល្មើសរំលោភសេពសន្ថវៈ ឬវាជាអំពើអមនុស្សធម៌។ ដូចដែលខ្ញុំបានលើកឡើងមកហើយ នៅក្នុងរឿងក្តី *អ៊ីសាម៉ូវិច* នៅតុលាការ អាយ.ស៊ី.ធី.វាយ គោលការណ៍នីត្យានុកូលភាពត្រូវបានបំពេញ ប្រសិនណាជាបទល្មើសនេះ គឺអាចនឹងត្រូវយកមកផ្តន្ទាទោសដោយមិនគិតថា បើចោទជាក់លាក់មានចែងនៅក្នុងច្បាប់ដែរ ឬក៏យ៉ាងណានោះ?

ដូច្នេះបញ្ហា គឺថាតើនៅក្នុងសំណើសារណារបស់ខ្ញុំ ថាតើអំពើដែលបង្កើតបានទៅបទរំលោភសេពសន្ថវៈអាចផ្តន្ទាទោសដូចគ្នាទៅនឹងបទល្មើសប្រឆាំងមនុស្សជាតិដែរឬអត់? ថាតើ-- ដែលត្រូវយកមកផ្តន្ទាទោសជនជាប់ចោទសំអាងទៅលើអំពើនៅក្នុងយុត្តាធិការពេលវេលានេះ។

[០៩:៣១:០៥]

នេះគឺជាជំហររបស់យើងខ្ញុំ ដែលថាជនជាប់ចោទ គឺថាអាចគិតមើលឃើញជាមុនបានដោយថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងឆ្នាំ១៩៧៥ ថាហេតុអ្វីបានជាខ្ញុំលើកឡើងយ៉ាងដូច្នេះ? នៅក្នុងសេចក្តីសម្រេចរឿងក្តី *ឃុនណារ៉ាក់* នៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ ច្បាប់លេខ៧៣ បទល្មើសរំលោភសេពសន្ថវៈត្រូវបានចាត់ទុកថា ជាអំពើមួយគួរឲ្យឈឺចាប់បំផុតដែលបង្កទៅលើអ្នកដទៃ ហើយតុលាការរកឃើញថា នៅក្នុងច្បាប់ប្រពៃណីអន្តរជាតិត្រូវបានហាមឃាត់ជាយូរយារណាស់មកហើយ។

អង្គបុរេជំនុំជម្រះរបស់ អ.វ.ត.ក-- របស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ គឺថាត្រូវបានរកឃើញថាហាមឃាត់ជាយូរណាស់មកហើយ ដោយមានចែងទាំងក្នុងច្បាប់មនុស្សធម៌អន្តរជាតិ។ ហើយនៅក្នុងរឿង នួន ជា និង អៀង ធិរិទ្ធ នៅក្នុងដីកាដំណោះស្រាយ គឺអាចរកឃើញនៅក្នុងកថាខណ្ឌ៥១ នៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

[០៩:៣២:០៥]

យើងបានរកឃើញថា ការហាមឃាត់ចំពោះបទរំលោភ-- គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបទរំលោភសេពសន្ថវៈនេះ បើយើងគិតទៅដល់ទសវត្សរ៍១៩៣០។ ខ្ញុំមិនមានពេលវេលាដើម្បីនិយាយលម្អិតទៅលើករណីនីមួយៗនេះទេ។ ច្បាប់ទាំងអស់នេះតាមការពិត គឺថាត្រូវបានអង្គបុរេជំនុំជម្រះលើកឡើងយកមកសំអាងហើយ នៅក្នុងក្រមលេខ៤៤ ដែលជាក្រមមួយដាក់មកនៅក្នុងពេលដែលអាមេរិកមានសង្គ្រាមស៊ីវិល ដែលបានចែងយ៉ាងច្បាស់ថា បទរំលោភសេពសន្ថវៈគឺត្រូវហាមឃាត់យ៉ាងដាច់ខាតចំពោះការប្រព្រឹត្តឡើងដោយយោធារបស់ខ្លួន ហើយក៏មានចែងនៅក្នុងអនុសញ្ញាទីក្រុងហែក *(Hague)* នោះផងដែរ។ ហើយពិធីសារបន្ថែមនៅក្នុងឆ្នាំ១៩៧៧ ក៏មានកំណត់ចំពោះ-- ក៏បានហាមឃាត់ទៅអំពើហិង្សាផ្នែកផ្លូវភេទនេះផងដែរ។

[០៩:៣៣:១១]

ហើយភស្តុតាងបន្ថែមទៀត គឺការហាមឃាត់ចំពោះរំលោភ បទរំលោភសេពសន្ថវៈនៅក្នុងច្បាប់ប្រពៃណីអន្តរជាតិនៅក្នុងឆ្នាំ១៩១៩ គឺហាមឃាត់ និងដាក់ការផ្តន្ទាទោស នៅពេល-- នៅចុងបញ្ចប់នៃ

សង្គ្រាមលោកលើកទី១ គឺថាមានអនុសាសន៍មួយថា ឲ្យនាំយកអធិរាជមួយចំនួនពីប្រទេសអាល្លឺម៉ង់ ដើម្បីយកមកផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងសង្គ្រាមលោកលើកទី១។

នៅក្នុងចំណោមបទចោទចំនួន៣២ គឺថាមិនមានសវនាការមួយកើតឡើងនោះទេ ទាក់ទងទៅនឹងការប្រព្រឹត្តបទល្មើសទាំងអស់នោះ ប៉ុន្តែមានសវនាការកាត់បទល្មើសមួយចំនួនដោយសារតែខ្វះឆន្ទៈខាងផ្នែកនយោបាយ។ តែទោះជាយ៉ាងណាក៏ដោយ នេះគឺជាពេលវេលាមួយដែលយើងបានយល់ច្បាស់ថា បទល្មើសទាំងនេះមានចែងនៅក្នុងច្បាប់។

[០៩:៣៤:១៨]

ក្រោយមកនៅឆ្នាំ១៩៤៥ បទល្មើសរំលោភសេពសន្ថវៈត្រូវបានចាត់ទុកថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងមាត្រា២(គ) ច្បាប់លេខ១០ គឺច្បាប់ដែលត្រូវបានអនុម័តឡើងដើម្បីផ្ដន្ទាទោសឧក្រិដ្ឋជនសង្គ្រាមនៅក្នុងប្រទេសអាល្លឺម៉ង់ បន្ទាប់ពីសង្គ្រាមនោះ ដែលក្រោយមកតុលាការ អាយ.ស៊ី.ធី.វ៉ាយក៏បានផ្ដន្ទាទោស ហើយនៅតុលាការគឺបានផ្ដន្ទាទោសទៅលើមេបញ្ជាការជាន់ខ្ពស់ណាហ្ស៊ី។ ផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

បទប្បញ្ញត្តិទាំងនោះ គឺគ្របដណ្ដប់ទៅលើច្បាប់លេខ១០ ដែលមានចែងថា មិនមានជនជាតិត្រូវបានផ្ដន្ទាទោសទៅលើបទល្មើសរំលោភសេពសន្ថវៈនេះទេ។

[០៩:៣៥:១៦]

អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់បានចង្អុលបង្ហាញថា ភស្តុតាងត្រូវបានបង្ហាញនៅក្នុងសវនាការដែលថាបទរំលោភសេពសន្ថវៈត្រូវបានចាត់ទុកថា ជាអំពើអមនុស្សធម៌ ហើយតុលាការ នូរឹមប៊ឺក បានចាត់ថាបទរំលោភសេពសន្ថវៈជាអំពើអមនុស្សធម៌។ តែទោះជាយ៉ាងណាក៏ដោយបទរំលោភសេពសន្ថវៈត្រូវបានគេយកមកផ្ដន្ទាទោសនៅក្នុងរឿងក្ដីនេះ។ ហើយលើសពីនេះទៅទៀត តុលាការសឹកអន្តរជាតិក៏បានដាក់បញ្ចូលអំពើអមនុស្សនេះ ហើយភស្តុតាងក៏បានយកមកបង្ហាញនៅក្នុងរឿងក្ដីថាមានបទរំលោភសេពសន្ថវៈកើតឡើង។

[០៩:៣៦:០០]

ខ្ញុំសូមបន្តទៅមុខ ដោយសារតែពេលវេលាកាន់តែខិតមកជិតណាស់ទៅហើយ។ ទាំងតុលាការ អាយ.ស៊ី.ធី.វ៉ាយ ទាំងតុលាការឧក្រិដ្ឋកម្មសង្គ្រាម គឺធ្វើការផ្ដន្ទាទោសបទរំលោភសេពសន្ថវៈដាច់ដោយឡែកពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បើទោះបីជាលិខិតុបករណ៍ច្បាប់ទាំងអស់នេះ បានចែងលម្អិតថា

ឧក្រិដ្ឋកម្មមុនពេលឆ្នាំ១៩៨៩ នេះដែលបទរំលោភ-- ផ្តន្ទាទោសតាំងពីក្នុងអំឡុងសង្គ្រាមលោកទី២ រហូតដល់ឆ្នាំ១៩៨៩។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៩៨ គឺត្រូវបានយកបទល្មើសនោះ ចាត់ទុកថាជាបទល្មើសមួយក្នុងចំណោមបទល្មើសប្រឆាំងមនុស្សជាតិ។ ហើយអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា អំពើហិង្សាផ្លូវភេទដែលបានប្រព្រឹត្តឃោរឃៅមកលើមនុស្សជាតិ។ ក្រោយមកតុលាការ រវ៉ាន់ដា បានរកឃើញនូវបទល្មើសរំលោភសេពសន្ថវៈថា ស្ថិតនៅក្នុងប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ហើយក្នុងនោះយើងក៏មានលើកឡើងនៅក្នុងរឿងក្តី *យុនណារ៉ាក់* ហើយជាពិសេសតុលាការ សៀរ៉ាឡេអូន នេះក៏បានរកឃើញដូចគ្នាផងដែរ។

[០៩:៣៧:២៣]

សហព្រះរាជអាជ្ញាសូមលើកឡើងថា វាជាការសមស្របដែលតុលាការ គឺថាត្រូវតែកំណត់នូវយុត្តាធិការទៅលើបញ្ហាទាំងអស់នោះ។ បើទោះបីជាតុលាការ អាយ.ស៊ី.ធី.វ៉ាយ តុលាការ រវ៉ាន់ដា ឬក៏តុលាការពិសេសសម្រាប់ សៀរ៉ាឡេអូន មិនបានកំណត់ចំណុចជាក់លាក់ថា បទរំលោភសេពសន្ថវៈ គឺជាប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ នេះគឺជាសំណើរបស់ខ្ញុំ។ ដូចខ្ញុំបានលើកឡើងគឺថាមិនមានអនុសញ្ញា ឬយុត្តិសាស្ត្រជាក់លាក់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការរំលោភសេពសន្ថវៈក្នុងឆ្នាំ១៩៤៥ ទៅដល់ ឆ្នាំ១៩៩៣ នេះទេ។ តុលាការបានសំអាងទៅលើសេចក្តីសម្រេចរបស់តុលាការដែលបានកាត់នៅមុនឆ្នាំ១៩៧៩ ដោយពិនិត្យមើលទៅលើសេចក្តីសម្រេចដទៃទៀត ដើម្បីយកមកធ្វើការបកស្រាយច្បាប់ ហើយខ្ញុំក៏សូមស្នើឲ្យលោក លោកស្រីចៅក្រម ពិនិត្យ និងសម្រេចដូចគ្នានេះផងដែរ ព្រោះនេះជាការណែនាំមួយដែលអាចផ្តល់នូវការបកស្រាយទៅលើបទល្មើសទាំងអស់នេះ ដើម្បីឲ្យជនល្មើសទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ។

[០៩:៣៨:៤១]

ដូចគ្នានេះដែរ តុលាការ យូហ្គោស្លាវី នៅក្នុងរឿង *ម៉ូសាទូវិច* គឺបានិយាយអំពីគោលការណ៍នីត្យានុកូលភាព ហើយតុលាការសិទ្ធិអឺរ៉ុប ក៏បានអនុញ្ញាតឲ្យមានការបញ្ជាក់ទាក់ទងទៅនឹងវិធានដែលក្របដណ្តប់ទៅលើការបកស្រាយនឹងផ្ទុះបញ្ចាំង ដែលថាវាជាការចាំបាច់-- វាមិនចាំបាច់ក្នុងការថែងកំណត់មកឥឡូវ ប៉ុន្តែត្រូវរៀបរាប់ឲ្យបានលម្អិត។ នៅក្នុងសារណារបស់ខ្ញុំ នេះគឺមានអត្ថន័យខ្លាំងណាស់ដែលថា ត្រូវមានពន្យល់ឲ្យច្បាស់លាស់អំពីបទដ្ឋានអន្តរជាតិតាមរយៈការបកស្រាយនេះទាក់ទង

ទៅនឹងចរិតលក្ខណៈនៃប្រព័ន្ធច្បាប់នីមួយៗ ថាតើក្រមនេះមានចែងនៅក្នុងប្រព័ន្ធច្បាប់ជាតិដែរឬទេ? ច្បាប់អន្តរជាតិដូចលោក លោកស្រីចៅក្រមបានដឹងហើយ គឺជាវាមិនមានច្បាប់អន្តរជាតិណាមួយដែលកំណត់ឲ្យអនុវត្តច្បាប់នេះជាសាកលនោះទេ។ គឺវាអាស្រ័យតែទៅលើសេចក្តីសម្រេចរបស់តុលាការកំណត់ថា តើគោលការណ៍ច្បាប់ក្នុងស្រុកដ៏ល្អិតល្អន់នោះ អាចនឹងអនុវត្តបានដោយរបៀបណា។

[០៩:៣៩:៥៥]

ដើម្បីឲ្យតុលាការនេះផ្តន្ទាទោសទៅលើបទរំលោភសេពសន្ថវៈ ក្រៅពីតុលាការឧក្រិដ្ឋកម្មអន្តរ-ជាតិនេះ គឺថាត្រូវមានការរកឃើញឲ្យស៊ីសង្វាក់គ្នាទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ដែលបានផ្តន្ទាទោសទៅលើបទរំលោភសេពសន្ថវៈដាច់ដោយឡែកពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ទាក់ទងទៅនឹងការរំលោភសេពសន្ថវៈ ទាក់ទងទៅនឹងច្បាប់ដែលអាចនឹងយកមកអនុវត្តបានចំពោះមុខលោក លោកស្រីចៅក្រមទាំងអស់គ្នា គឺថា-- ជាសង្ខេបមកលោក លោកស្រីចៅក្រម គឺមិនមានមូលដ្ឋានណាមួយដែលយើងយកមកសំអាងនៅក្នុងច្បាប់ ជាពិសេសគោលការណ៍នៃនីត្យានុកូលភាពទាក់ទងទៅនឹងសេរីភាពនេះ អង្គបុរេជំនុំជម្រះរកឃើញថា ជនជាប់ចោទត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយមិនត្រូវយោងទៅលើបទប្បញ្ញត្តិណាផ្សេងទៀតនោះទេ។

[០៩:៤១:០២]

ការអនុវត្តបទដ្ឋាននេះ សម្រាប់រឿងក្តីនៅចំពោះមុខយើងសហព្រះរាជអាជ្ញាសូមលើកឡើងថាច្បាប់ប្រពៃណីអន្តរជាតិ គឺថាបានអភិវឌ្ឍន៍ឡើងមករហូតមកដល់ឆ្នាំ១៩៧៥។ ដូច្នេះជនជាប់ចោទរូបនេះ អាចនឹងប្រមើលមើលឃើញថា បទរំលោភសេពសន្ថវៈ គឺជាឧក្រិដ្ឋកម្មមួយហើយ ហើយការដែលឧក្រិដ្ឋកម្មប្រព្រឹត្តមុននេះ គឺថាមិនបានដឹងអំពីបទល្មើសនេះ គឺមិនមានការពាក់ព័ន្ធនោះទេ។

ទ្រឹស្តីទីពីរ នៃលក្ខណៈវិនិច្ឆ័យទៅលើគោលការណ៍នីត្យានុកូលភាពនេះ គឺវាអាចវាយតម្លៃជាមុនបាន ហើយអង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា ទាក់ទងទៅនឹងការវាយតម្លៃទៅលើទ្រឹស្តីនេះ គឺថាយើងអាចយោងទៅលើច្បាប់ស្តីអំពីប្រពៃណី។

នេះគឺជាព័ត៌មានដែលអាចនឹងអាចឲ្យយើងធ្វើការសេចក្តីសន្និដ្ឋានបានថា បទរំលោភសេពសន្ថវៈអាចនឹងមកផ្តន្ទាទោសស្ថិតនៅក្នុងច្បាប់ប្រពៃណីអន្តរជាតិ។ នេះមិនមែនដោយសារថា មិនមាននៅក្នុងច្បាប់ក្នុងស្រុកដែលថាជនជាប់ចោទ គឺថាគាត់-- ដោយសារមិនមានចែងនៅក្នុងច្បាប់ក្នុងស្រុក ជនជាប់ចោទដោះសារថា ខ្លួនមិនបានដឹងថា នេះជាបទល្មើសនោះទេ។

[០៩:៤២:២៥]

ហើយការអនុវត្តរបស់តុលាការយូហ្គោស្លាវី គឺបទរំលោភសេពសន្ថវៈស្ថិតនៅក្នុងបរិបទនៃការធ្វើទុក្ខបុកម្នេញក្នុងលក្ខណៈជាប្រព័ន្ធ និងក្នុងលក្ខណៈទូលំទូលាយទៅលើអំពើរបស់អ្នកទាំងនោះ គឺថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលការរំលោភទាំងអស់នេះ គឺជាឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយអ្នកនោះគឺបានដឹងចំពោះទង្វើរបស់ខ្លួន។ ហើយតុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្កើតនូវគឺថា ភាពអសីលធម៌នេះ គឺថាត្រូវតែហាមឃាត់ដាច់ខាត់ចំពោះអំពើទាំងឡាយប្រឆាំងទៅនឹងមនុស្សជាតិ ដែលមានការអះអាងថា ជនជាប់ចោទមិនបានដឹងថា អំពើនេះគឺជាអំពើព្រហ្មទណ្ឌនោះ។

ដូច្នេះ លោក យើងអាចរកឃើញនៅក្នុងសេចក្តីសម្រេចរបស់ *មីតធីនូវិច* នៅក្នុងកថាខណ្ឌ៤២ ដែលអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការឧក្រិដ្ឋកម្មសង្គ្រាមបានយកមកធ្វើការសម្រេច។

[០៩:៤៣:២៤]

ខ្ញុំសូមចូលទៅដល់ការដាក់ជាទាសករ។

អង្គជំនុំជម្រះបានស្នើសុំឲ្យយើងខ្ញុំដាក់នូវសារណាទាក់ទងទៅនឹងបទល្មើសការដាក់ទៅជាទាសករទាក់ទងទៅនឹង ជាពិសេសបទចោទដែលមានកំណត់នៅក្នុងដីកាដំណោះស្រាយ ដែលយើងបានចោទប្រកាន់អំពីការដាក់ទៅជាទាសករ ទាក់ទងទៅនឹងអ្នកជាប់ឃុំឃាំងមួយចំនួន មិនមែនទាំងអស់នោះទេ។ ហើយក៏ ក.ស.ព យល់ឃើញថា ការដាក់ទៅជាទាសករកើតមានឡើងទៅជនជាប់ចោទនៅមន្ទីរស-២១ មួយចំនួន។

[០៩:៤៤:១២]

ទាក់ទងទៅនឹងនិយមន័យនៃការដាក់ជាទាសករ ខ្ញុំសូមយោងទៅលើកថាខណ្ឌ៣៤២ នៃសាលក្រមសាលាដំបូង ដែលពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខនេះ ហើយខ្ញុំលើកឡើងថាតើសាលាដំបូងបានរកឃើញការដាក់ជាទាសករនេះ គឺយល់ឃើញថាដូចម្តេច? ដែលគាត់យល់ឃើញថា ការប្រភេទមួយនៃពលកម្មដោយបង្ខំ។ ចំណុចនេះ គឺមាននៅក្នុងសារណានៃបណ្តឹងសាទុក្ខរបស់យើងខ្ញុំ។ នេះគឺជាជំហររបស់សហព្រះរាជអាជ្ញាដែលយល់ឃើញថា ជនជាប់ឃុំឃាំងទាំងអស់ គឺជាទាសករនៅមន្ទីរសន្តិសុខស-២១ ហើយមានចែងនៅក្នុងកថាខណ្ឌ២៧៣ និង២៧៤ នៃសារណាបណ្តឹងសាទុក្ខរបស់យើងខ្ញុំ។

សារណានេះ គឺបានកំណត់-- អ្នកទាំងអស់នេះត្រូវបានបង្ខំឲ្យធ្វើការនៅមន្ទីរសន្តិសុខស-២៤ ដូចជាទាសករ។ នៅក្នុងដីកាដំណោះស្រាយ ដែលបានចេញទៅដោយ ក.ស.ច.ស ហើយខ្ញុំសូមលើក

ឡើងតែម្តង គឺថាអ្នកជាប់ឃុំឃាំងមួយចំនួននៅស-២១ និងព្រៃស ត្រូវបានបង្ខំឲ្យធ្វើពលកម្មក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹងបំផុត ដោយមានការគ្រប់គ្រងទៅលើគ្រប់ចំណុចទាំងអស់នៃជីវិតរបស់ខ្លួន។ ការហាមឃាត់ចំពោះការធ្វើចលនា ការឃាមកាមយ៉ាងល្អិតល្អន់ ទប់ស្កាត់ការរត់គេចខ្លួន។ ជាលទ្ធផលពីអំពើនេះជនជាប់ឃុំឃាំងត្រូវបានដកហូតនូវសេរីភាពរបស់ខ្លួន។

[០៩:៤៦:០៥]

ហើយខ្ញុំសូមលើកឡើងភ្លាមៗ ថាតើអង្គជំនុំជម្រះឈានចូលទៅដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនដោយរបៀបណា? ដែលសហចៅក្រមស៊ើបអង្កេតបានកម្រិតទៅលើ ថាតើអ្នកជាប់ឃុំឃាំងណាខ្លះដែលទទួលរងការបង្ខំឲ្យទៅជាទាសករនេះ ការដាក់ឲ្យទៅជាទាសករនេះ? ប៉ុន្តែ ខ្ញុំសូមលើកឡើងនៅក្នុងកថាខណ្ឌនៅក្នុងដីកាដំណោះស្រាយ គឺនៅក្នុងកថាខណ្ឌ១៣៥ នៃដីកាដំណោះស្រាយ ខ្ញុំមិនអាចអានលម្អិតបានទេ។ ក៏ប៉ុន្តែ សូមចូលទៅមើលកថាខណ្ឌ៦២, ៦៣, ៦៦។

នេះគឺពាក់ព័ន្ធទៅនឹងស-២១ ឬក៏ទួលស្លែង ដែលចៅក្រមបានយល់ឃើញច្បាស់ ហើយថាការដាក់ឲ្យទាសករ គឺមិនស្ថិតនៅក្នុងប្រភេទបទចោទនៃពលកម្មដោយបង្ខំនេះទេ។ អ្នកជាប់ចោទទោសគឺថាត្រូវបានជាប់ឃុំឃាំង២៤ម៉ោងក្នុងមួយថ្ងៃ ហើយវិធានដែលគ្របដណ្តប់ទៅដល់អ្នកទោសទាំងអស់នេះ គឺថាបានដកហូតសេរីភាពរបស់គេទាំងអស់។ ហើយនៅពេលយប់ គឺត្រូវបានគេដាក់ខ្នោះជើង។

[០៩:៤៧:៣៤]

សារណារបស់យើងខ្ញុំ បើទោះបីកថាខណ្ឌ១៣៥ មានការកម្រិតក៏ដោយ ប៉ុន្តែមើលកថាខណ្ឌចុងក្រោយ លទ្ធផលនៃអំពើនេះ គឺអ្នកជាប់ឃុំឃាំងគឺត្រូវដកហូតនូវឆន្ទៈរបស់ខ្លួន សេរីរបស់ខ្លួន។ កថាខណ្ឌនេះ គឺថាសូមអានឲ្យហ្មត់ចត់ ដែលបានរៀបរាប់នូវអង្គហេតុទាំងអស់ដែលយើងបានដាក់បញ្ចូល។ នៅក្នុងកថាខណ្ឌ១៣៥នេះ គឺថា ប្រសិនណាអានឲ្យបានចប់សព្វគ្រប់នៅក្នុងកថាខណ្ឌនឹងឃើញថាមានកំណត់អំពីអំពើនេះនៅស-២១ និងស-២៤ហើយ ហើយជាពិសេសគឺថា កថាខណ្ឌ១៣៥គាំទ្រមកដល់ទឡ្ហីករណ៍របស់យើងខ្ញុំនេះ។ ហើយប្រសិនណាជាអង្គជំនុំជម្រះតុលាការកំពូលមិនទទួលយកទឡ្ហីករណ៍របស់ខ្ញុំទេ ខ្ញុំសូមឲ្យលើកយកបញ្ហាច្បាប់យកមកកំណត់ទៅលើបទចោទឲ្យច្បាស់ដែលមានចែងនៅក្នុងវិធាន១១០ របស់តុលាការដែលចែងថា៖ សាលក្រមត្រូវតែកំណត់ទៅលើអង្គហេតុដែលមានចែង ឬក៏ថាអាចចែកផ្លាស់ប្តូរចរិតលក្ខណៈនៃបទចោទនេះឲ្យតែអង្គជំនុំជម្រះរកឃើញនូវធាតុផ្សំណាមួយដែលអាចយកមកអះអាងបាន។

[០៩:៤៨:៥៤]

ដូចដែលខ្ញុំបានជម្រាបជូនហើយ ធាតុផ្សំនៃពលកម្មដោយបង្ខំ ដែលសាលាដំបូងបានសម្រេច ទាំងមានកំហុស ដោយបានលើកថា "ការដាក់ឲ្យទៅជាទាសករ គឺថាកើតមានឡើងដោយមិនបាច់មានពលកម្មដោយបង្ខំនោះទេ" ប៉ុន្តែជំហររបស់យើងខ្ញុំ ការដាក់ឲ្យទៅជាទាសករ គឺវាមានលក្ខណៈខុសគ្នាទៅនឹងពលកម្មដោយបង្ខំ ដែលពាក់ព័ន្ធទៅនឹងជនជាប់ឃុំឃាំងទាំងអស់ដែលបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១។

[០៩:៤៩:២៩]

បន្ទាប់មកទៀត ខ្ញុំសូមនិយាយសង្ខេប ដោយសារខ្ញុំនៅសល់ពេលតិចពេក។ ខ្ញុំលើកឡើងទៅលើធាតុផ្សំទាក់ទងទៅនឹងរឿងក្តីនៅចំពោះមុខយើងនេះ។ ចំណុចនេះបើ-- ទាក់ទងទៅនឹងអ្វីដែលខ្ញុំបានលើកឡើងខាងដើមទាក់ទងទៅនឹងការផ្តន្ទាទោសត្រួតគ្នា។ អ្វីដែលខ្ញុំចង់លើកឡើង គឺថាខ្ញុំចង់លើកឡើងពីធាតុសត្យានុម័តអំពីការធ្វើទុក្ខបុកម្នេញ ហើយនិងការដាក់ឲ្យទៅជាទាសករ។

ការធ្វើទុក្ខបុកម្នេញ តម្រូវឲ្យមានលទ្ធផល គឺថាអាចនឹងឈានឲ្យមានការដល់ស្លាប់របស់--ការស្លាប់មនុស្សណាម្នាក់។

ការដាក់ឲ្យទៅជាទាសករ តម្រូវឲ្យមានការអនុវត្តអំណាច ទាក់ទងទៅនឹងការគ្រប់គ្រងទៅលើជីវិតរបស់មនុស្សណាម្នាក់។ ធាតុផ្សំនេះ គឺមិនមាននៅក្នុងការធ្វើទុក្ខបុកម្នេញទេ។

[០៩:៥០:២៩]

ទាក់ទងទៅនឹងអង្គហេតុរឿងក្តីនេះ គេអាចធ្វើការញែកពីគ្នារវាងអង្គហេតុ ដែលថាលក្ខខណ្ឌនៃការឃុំខ្លួនអាចបណ្តាលឲ្យមានការស្លាប់ ហើយលក្ខខណ្ឌសម្រាប់ការឃុំខ្លួនដែលវាចាំបាច់ ដែលបង្ខំឲ្យបុគ្គលណាម្នាក់ក្លាយទៅជាទាសករ។

[០៩:៥១:០៤]

អ៊ីចឹង ជាសង្ខេបមកវិញលក្ខខណ្ឌនៃការឃុំឃាំង ដែលបណ្តាលឲ្យឈានទៅដល់ការដាក់ឲ្យទៅជាទាសករ លោក លោកស្រីចៅក្រមអាចរកឃើញនៅក្នុងកថាខណ្ឌ១៦៦, ១៦៣, ១៦២, ១៦៤ នៃដីកាដំណោះស្រាយ។ នេះជាសារណារបស់ខ្ញុំ ដែលខ្ញុំសូមស្នើថា ការញែកឲ្យដាច់ពីគ្នារវាងការសម្លាប់រង្គាល ហើយនិងការដាក់ទាសករសម្រាប់បទល្មើសទាំងពីរ។ ហើយលើសពីនេះទៅទៀត ដែលថាការដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេច គឺថាគាំទ្រទៅដល់-- តាមខ្ញុំដឹង គឺមានបុគ្គលមួយចំនួន

ដែលរស់រានមានជីវិតពីការឃុំឃាំងនៅមន្ទីរស-២១ បានបង្ហាញនូវអង្គហេតុទាំងអស់នេះ ដែលមានអ្នកជាប់ឃុំឃាំងមួយចំនួនបានរស់រានមានជីវិត ហើយបានប្រឈមមុខទៅនឹងការឃុំឃាំងខ្លួនដែលបណ្តាលឲ្យគាត់ក្លាយទៅជាទាសករ។

[០៩:៥២:៣៥]

ខ្ញុំសូមលើកឡើងដោយសង្ខេបបន្តទៀត ដោយសារតែខ្ញុំជិតអស់ពេលរួចទៅហើយ ខ្ញុំនៅមានពេលតែបីនាទីទៀតទេ ដែលនៅសល់តាមសហការីរបស់ខ្ញុំបានប្រាប់។

ចំពោះការធ្វើទុក្ខបុកម្នេញ ខ្ញុំសូមបញ្ជាក់ទៅលើចំណុចនេះ ដែលជាប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ យើងហាក់ដូចជា គាំទ្រការរកឃើញរបស់សាលាដំបូង ដែលថាយើងមិនមានអ្វីបន្ថែមច្រើនទៀតទេលើចំណុចហ្នឹង។ ខ្ញុំនឹងសូមបញ្ជាក់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលក៏មានលើកឡើងទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការធ្វើទុក្ខបុកម្នេញនៅក្នុងកថា៣៧៤ ទៅដល់៣៩៦ នៃសាលក្រម។ នៅក្នុងឆ្នាំ១៩៧៥ ទៅដល់ ឆ្នាំ១៩៧៩ យើងក៏ឃើញមានច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលបង្ហាញថា វាមានការធ្វើទុក្ខបុកម្នេញនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

[០៩:៥៣:៣៧]

មាត្រា៦ នៃតុលាការអន្តរជាតិក៏បានរកឃើញថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្ស។ មាត្រា៥ នៃតុលាការយោធា ក៏យើងឃើញថា ការធ្វើទុក្ខបុកម្នេញក៏ជាប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ដោយផ្អែកទៅលើមូលដ្ឋាននយោបាយ។

សេចក្តីសម្រេចរបស់មហាសន្និបាត ក៏បានបង្ហាញអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងពេលមានសន្តិភាព។ ហើយនៅក្នុងឆ្នាំ១៩៤៥ ក៏មានការលើកឡើងអំពីធម្មនុញ្ញ ដែលនៅក្នុងបញ្ជាក់ថាការធ្វើទុក្ខបុកម្នេញត្រូវបានគេរកឃើញថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

[០៩:៥៤:២៤]

សេចក្តីសម្រេចរបស់មហាសន្និបាត៩៥ បញ្ជាក់អំពីច្បាប់អន្តរជាតិតម្កល់ទៅលើនូរីមប៊ឺក--សាលាក្តីនូរីមប៊ឺក ហើយយើងឃើញថា ការធ្វើទុក្ខម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

សេចក្តីសម្រេចរបស់មហាសន្និបាត៣៩១ ក៏បានបញ្ជាក់អំពីករណីនេះ ហើយគេបានលើកឡើងថា ការធ្វើទុក្ខបុកម្នេញនោះក៏ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ មិនថាប្រព្រឹត្តក្នុងពេលមានសន្តិភាពឬក៏ពេលសង្គ្រាមនោះឡើយ ដែលសេចក្តីសម្រេចចុងក្រោយនេះ ឃើញមាននៅក្នុងឆ្នាំ១៩៤៥។

ការធ្វើទុក្ខបុកម្នេញក៏បានបញ្ចូលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងករណី អាយ.អុិល. ស៊ី ហើយយើងឃើញមានក្នុងមាត្រា២ អនុមាត្រា១០ ដែលបញ្ជាក់អំពីការធ្វើទុក្ខបុកម្នេញដោយមូល-ហេតុនយោបាយ ឬក៏ដោយមូលហេតុវប្បធម៌។

[០៩:៥៥:៣០]

នៅក្នុងករណីមួយទៀត ក្នុងឆ្នាំ១៩៥៤ ក៏បានបង្ហាញអំពីការធ្វើទុក្ខបុកម្នេញទៅលើជនស៊ីវិល ដោយផ្អែកទៅលើមូលហេតុសាសនានិងនយោបាយ។ ទាំងអស់នេះហើយ គឺយើងបញ្ជាក់ថា ការធ្វើទុក្ខបុកម្នេញគេបានដាក់បញ្ចូលនៅក្នុងច្បាប់ក្រុមប្រឹក្សាលេខ១០ ផងដែរ ដូចដែលខ្ញុំបញ្ជាក់កាលពីមុននេះ។

នេះគឺជា-- ស្ថាប័ននោះ គឺជាស្ថាប័នដែលបង្កើតឡើងដោយសម្ព័ន្ធមិត្តក្រោយពីសង្គ្រាម ហើយវាក្រោយមកក៏គេបានបង្កើតជាសាលាក្តីយោធាអន្តរជាតិ ដើម្បីធ្វើការកាត់ទោសឧក្រិដ្ឋកម្ម-- ឧក្រិដ្ឋជនសង្គ្រាម។ នៅក្នុងឆ្នាំ១៩៨១ លោក *អាយស្មិន* ក៏ត្រូវបានគេរកឃើញអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងនោះមានការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនិងសាសនា។ នៅក្នុងឆ្នាំ១៩៨៥ ក៏គេមានការអនុញ្ញាតឲ្យធ្វើការកាត់ទោសទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាពិសេសការធ្វើទុក្ខបុកម្នេញក្រោយសង្គ្រាមលោកលើកទីពីរ។

[០៩:៥៦:៣៧]

ខ្ញុំគិតថា ខ្ញុំអស់ពេលវេលាហើយ ដូច្នេះហើយ គឺខ្ញុំសូមលើកឡើងថា ការធ្វើទុក្ខបុកម្នេញ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយត្រូវបានគេបង្កើត បង្ហាញថា មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរ-ជាតិ។ ដោយសារមានការអនុញ្ញាតពីលោកប្រធាន និងលោកស្រីចៅក្រម ខ្ញុំថ្លែងអំណរគុណយ៉ាងច្រើនដែលអនុញ្ញាតឲ្យខ្ញុំធ្វើការផ្តល់នូវសេចក្តីសន្និដ្ឋានរបស់ខ្ញុំនេះ។ សូមអរគុណ។

[០៩:៥៧:១៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីការពារក្តីជនជាប់ចោទ ធ្វើសេចក្តីឆ្លើយតប។

**លោក កង ឫទ្ធារី៖**

ជាបឋម សូមគោរពលោកប្រធានតុលាការកំពូល និងអង្គជំនុំជម្រះតុលាការកំពូលទាំងមូល។ ដោយហេតុថា ខ្ញុំជាមេធាវីតំណាងផលប្រយោជន៍ឲ្យជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ហើយយើងបានសន្មតថា អ.វ.ត.ក អត់មានយុត្តាធិការលើបុគ្គល កាំង ហ្កេកអ៊ាវ ហៅ ឌុច នេះទេ។ ដូចដែល

យើងបានពិភាក្សាកាលពីម្សិលមិញអ៊ីចឹង។ ហេតុនេះហើយជាដើមហេតុ ដែលយើងមិនដាក់សារណាជាលាយលក្ខណ៍អក្សរឆ្លើយតបទៅនឹងអ្វីដែលជាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាមកកាន់តុលាការកំពូលនេះ។ នេះជាដើមហេតុដែលយើងមិនដាក់សារណាជាលាយលក្ខណ៍អក្សរ។ ប៉ុន្តែដោយហេតុថាយើងបានទទួលនូវការបង្គាប់ជាធម្មានុរូបពីតុលាការកំពូលឲ្យយើង ក្រុមយើងធ្វើការឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។ ប៉ុន្តែអម្បាញ់មិញនេះ ខ្ញុំបានទទួលដំណឹងពីកូនក្តីខ្ញុំ គឺគាត់នៅតែរក្សាជំហរសុំឲ្យបដិសេធមិនឆ្លើយតប។ ប៉ុន្តែ ដោយការពន្យល់របស់យើងខ្ញុំអំពីផលប្រយោជន៍របស់គាត់ ទើបគាត់អនុញ្ញាតឲ្យយើងខ្ញុំឆ្លើយតបដោយខ្លីៗ។

ដូច្នេះ ខ្ញុំនៅឈរចន្លោះរវាងកាតព្វកិច្ចច្បាប់ដែលគោរពតុលាការកំពូល ហើយនិងកាតព្វកិច្ចត្រូវគោរពផលប្រយោជន៍កូនក្តីខ្ញុំផងដែរ។ ហេតុនេះខ្ញុំមិនធ្វើសេចក្តីថ្លែងការណ៍ណាមួយវែងឆ្ងាយពេកទេតបទៅនឹងសហព្រះរាជអាជ្ញា។

[០៩:៥៨:៤៥]

ការឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មប្រឆាំង-- និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទោះបីជាថាដំណើរការនៃសាលាជម្រះក្តីនានា ដែលបង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅលើពិភពលោកយើងនេះ មិនបានកំណត់ច្បាស់លាស់អំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយ៉ាងណាក៏ដោយក៏យើងរកបានវានៅក្នុងមាត្រា១៨៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាដែលចែងថា "បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាអំពើមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលដែលអំពើនេះត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌក្នុងការវាយលុកជាទូទៅ ឬជាប្រព័ន្ធសំដៅប្រជាជនស៊ីវិល។ ឃាតកម្ម ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ឬជម្លៀសដោយបង្ខំ ការដាក់ពន្ធនាគារ ឬគ្រប់រូបភាពដទៃទៀត នៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ការធ្វើទារុណកម្ម ការចាប់បង្ខំរលោភសេពសន្ថវៈ ការធ្វើទាសកម្មខាងផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយបង្ខំ វណ្ឌកម្មដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀត នៃអំពើហិង្សាខាងផ្លូវភេទ ដែលមានទម្ងន់ប្រហាក់ប្រហែលគ្នា។

[១០:០០:០៦]

ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសមូហភាពដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិពន្ធ វប្បធម៌ សាសនា ឬភេទ។ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍

ជាប្រព័ន្ធតាមបែបអាប៉ាថេត គ្រប់អំពើអមនុស្សធម៌ផ្សេងទៀតដែលបង្កឲ្យមានការឈឺចាប់យ៉ាងខ្លាំង ឬការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ។

តុលាការជាទីគោរព, ខ្ញុំនៅតែរំឭកថា ខ្ញុំកំពុងឈរនៅចំចំណុចកណ្តាលនៃប្រទេសដែលប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិលឡ។ ហេតុនេះ អត្ថន័យនៃការដកស្រង់សេចក្តីសម្រេចចិត្តរបស់តុលាការផ្សេងៗទៀត ដែលជាករណីយុត្តិសាស្ត្រដែលធ្លាប់ប្រើប្រាស់ក្នុងប្រព័ន្ធខំមិនឡ គួរគប្បីនឹងពិចារណាថាគួរទាត់ចោល។ ក៏ប៉ុន្តែ ដើម្បីលើកតម្លៃនៃបទដ្ឋានច្បាប់អន្តរជាតិ និងការរួមជាទូទៅអំពីច្បាប់ យើងក៏សង្កេតឃើញនូវធាតុផ្សំបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថា វាត្រូវទាមទារឲ្យមានធាតុផ្សំពីរសំខាន់ៗទៀត ដែលបន្ថែមទៅលើធាតុចេតនា ហើយនិងធាតុសត្យានុម័ត។

[១០:០១:០៥]

ធាតុចេតនាគឺបទឧក្រិដ្ឋប្រឆាំងមនុស្សទាមទារឲ្យមានលក្ខណ:ជាប្រព័ន្ធ។ គឺមានបទបញ្ជាពីលើចុះទៅក្រោម ហើយនិងការរាយការណ៍ពីក្រោមឡើងមកលើវិញ។ ទីមួយ។

ទីពីរ ធាតុសន្យានុម័តិទាមទារឲ្យវាមានលក្ខណ:ជាទ្រង់ទ្រាយធំ ជាភាសាអង់គ្លេសប្រើថា *ម៉ាស* បើសិនជាការសម្លាប់ ដូចជារៀបរាប់ក្នុងមាត្រា១៨៨ អម្បាញ់មិញ គឺការសម្លាប់ជាទ្រង់ទ្រាយធំ ហើយមានការរំលោភ ក៏រំលោភជាទ្រង់ទ្រាយធំដែរ ហើយបើការដាក់ទាសករ គឺជាទាសករជាទ្រង់ទ្រាយធំ និងមានលក្ខណ:ជាប្រព័ន្ធ។ ដូច្នេះ ធាតុផ្សំពីរសំខាន់ណាស់ដែលត្រូវលើកមកពិភាក្សា គឺជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ។ វាស្របតាមមាត្រា១៨៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាបច្ចុប្បន្ន ហើយក៏ស្របទៅតាមធម្មនុញ្ញរបស់សាលាជម្រះក្តី នូរឹមប៊ឺក និង តូក្យូ ផងដែរ។

[១០:០២:០០]

ការលើកឡើងនេះ ខ្ញុំចង់ទាញឧទាហរណ៍បង្ហាញអំពីការរំលោភសេពសន្ថវ: ឆ្លើយតបទៅនឹងសារណារបស់សហព្រះរាជអាជ្ញាថា នៅស-២១ មានការរំលោភសេពសន្ថវ:ដែលចាត់ទុកថាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការលើកឡើងបែបនេះ ដូចជាគ្មានទឡ្ហីករណ៍ណាបញ្ជាក់ច្បាស់លាស់សោះ។ ជាទម្លាប់របស់សហព្រះរាជអាជ្ញានៅសាលាក្តីនេះ កាលណាគាត់លើកឡើង មិនដែលទាញភស្តុតាងច្បាស់លាស់ណាមួយយកមកបង្ហាញយើងទេ ហើយក៏មិនបង្ហាញបទអត្ថបទច្បាប់ដែរ ក្រៅតែនិយាយដដែលៗ អំពីសាលាជម្រះក្តី យូហ្គោស្លាវី តែប៉ុណ្ណោះ។

[១០:០២:៣១]

នៅមន្ទីរស-២១ មានករណីរំលោភតែមួយករណីគត់ ហើយការរំលោភមួយករណីគត់នេះ គឺមិនមែនមានលក្ខណៈជាប្រព័ន្ធនិងទ្រង់ទ្រាយធំទេ ដូចដែលធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូច្នេះហើយ ការរំលោភមួយករណីនេះ វាមិនមែនជាធាតុមួយនៃធាតុផ្សំឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ ពីព្រោះថារំលោភមួយករណីនេះ ឌុច បានចាត់វិធានការដោយផ្ទាល់របស់គាត់។ ទីមួយគាត់បានរាយការណ៍ទៅថ្នាក់លើរបស់គាត់ សុន សេន សុំវិធានការចាត់ការចំពោះជនជាប់ចោទរំលោភសេពសន្ថវៈនេះ។ នៅពេលដែល សុន សេន មិនធ្វើការមិនដឹងមិនឮចំពោះចម្លើយតប--ចំពោះសំណើរបស់លោក កាំង អ៊ាវហ្កេក ហៅ ឌុច។

ឌុច ខ្លួនឯងនេះបានចាត់វិធានការរដ្ឋបាលដោយអស់ពីសមត្ថភាពគាត់ ដោយផ្លាស់អ្នកទោស--អ្នកសួរចម្លើយ -សុំទោស- ដោយផ្លាស់អ្នកសួរចម្លើយ ជាមនុស្សប្រុសឲ្យមកជាអ្នកសួរចម្លើយជាមនុស្សស្រីវិញ។ នេះជាវិធានការរាំងស្កាត់ការរំលោភសេពសន្ថវៈ។

[១០:០៣:៣០]

ដូច្នេះ វាមិនមានលក្ខណៈជាប្រព័ន្ធទេ លក្ខណៈជាប្រព័ន្ធបានន័យថា ប្រព្រឹត្តដោយរដ្ឋាភិបាល។ តែចំពោះការបង្កើតគុក ការធ្វើទារុណកម្មដែលមានលក្ខណៈជាប្រព័ន្ធ យើងអត់បដិសេធទេចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សនៅស-២១។ ដូច្នេះ យើងត្រូវពិចារណាផង តែមួយករណីគត់។

[១០:០៣:៤៨]

ហេតុដូចម្តេច ក៏គេមិនចោទប្រកាន់រដ្ឋាភិបាលបច្ចុប្បន្នឲ្យជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ គ្រាន់តែព្រឹកមិញនេះ លោកអានកាសែតឃើញ ខ្ញុំឃើញពីម្សិលមិញ ដល់ថ្ងៃនេះ ជាងដប់ករណីគ្រាន់តែការរំលោភ។ អ៊ីចឹង យើងអាចចាត់ទុកថានេះ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ? ចម្លើយថាគ្មានទេ។ ប៉ុន្តែនៅ នូរឹមប៊ឺក ហើយនិងនៅ តូក្យូ វាមានករណីផ្សេងពីនេះ។ ឯនៅ យូហ្គោស្លាវី ក៏ដូចគ្នាដែរ។ ដោយហេតុថា ចៅក្រមនៅទីនេះមានចៅក្រមជនជាតិជប៉ុនម្នាក់ ខ្ញុំសូមគោរព និងសូមអភ័យទោសពីលោកជាមុន។ គឺថាការរំលោភរបស់យោធាជប៉ុននៅ ណានគីង គឺនៅទីក្រុងចិន គឺមិនមែនទ្រង់ទ្រាយបែបនេះទេ ដែលគេកំណត់ថា វាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ គឺការរំលោភ និងដាក់ទាសករនៅស្ត្រីជនជាតិចិនហ្នឹងជាទាសករសម្រាប់ទាហានជនជាតិជប៉ុនហ្នឹង គឺទ្រង់ទ្រាយធំតែម្តងហើយការបៀតបៀនផ្លូវភេទហ្នឹងក៏សាហាវព្រៃផ្សៃសម្បើមណាស់ដែរ។ មិនមែនដូចនៅករណីនៅស-២១ នោះទេ។

[១០:៤:៤២]

ទីពីរ នៅ យូហ្គោស្លាវី១ ទាហានរបស់ ស្លូបូដាន មីឡូសីវិច រំលោភដោយអត់រើសមុខទៅលើ អំបូរជនជាតិភាគតិច អាល់បានី ដែលកាន់សាសនាអ៊ីស្លាម ហើយគាត់ដឹងថាការរំលោភបែបនេះ បង្ក ឲ្យមានបញ្ហាទាំងរូបកាយនិងផ្លូវចិត្ត ពីព្រោះថាជនជាតិអំបូរ អាល់បានី ដែលកាន់សាសនាអ៊ីស្លាមនេះ គឺមានការតឹងរ៉ឹងណាស់អំពីការប៉ះពាល់ផ្លូវភេទនេះ ធ្វើឲ្យសហគមន៍គាត់ទាត់គាត់ចោលទៀតផង។ នេះ ហើយជាការឈឺចាប់ផ្លូវកាយ។ ហើយមេបញ្ជានៃកងព័ទយូហ្គោស្លាវី ក្រោមបញ្ជារបស់ ស្លូបូដាន មីឡូសីវិច មិនដែលចាត់វិធានការម្តងណាទល់នឹងបុគ្គលិកយោធារបស់គាត់នោះទេ។ នេះហើយបាន មានលក្ខណៈដែលបង្ហាញថាធាតុផ្សំនៃធាតុចេតនាហ្នឹង គឺចេតនាចេញពីរដ្ឋភិបាលទៅតែម្តង ឲ្យអ្នក នោះអនុវត្ត ដោយមាការលើកទឹកចិត្ត ញុះញង់ ឬបង្ខំ បញ្ជា ឬក៏ការដោយសារសន្យា ឬក៏ធ្វើមិនដឹងមិន ឮតែម្តង។ ហើយឯទ្រង់ទ្រាយនៃការរំលោភគឺទ្រង់ទ្រាយធំ ដូចដែលខ្ញុំបានលើក ដោយគាត់ថាប្រព្រឹត្ត ដោយកងទ័ពជប៉ុន ហើយនិងកងទ័ពរបស់ ស្លូបូដាន មីឡូសីវិច យ៉ាងដូច្នេះដែរ។

[១០:០៥:៤៨]

ការដាក់ជាទាសករ១ និយមន័យរបស់ច្បាប់អន្តរជាតិគឺអត់ច្បាស់ដូចគ្នា ប៉ុន្តែមានក្នុង-- វាជា ធាតុផ្សំមួយនៃធាតុទាំងឡាយក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងមាត្រា១៨៨ ដូចគ្នា។

ប៉ុន្តែ តាមទំនៀមទម្លាប់អន្តរជាតិ ដែលយើងព្យាយាមមិនលើកវាមកបង្ហាញ គឺថាការអប់រំជា ទូទៅ គឺការដាក់ជាទាសករនេះ គឺសំដៅលើការរឹបអូសទ្រព្យសម្បត្តិទៀតផង មិនមែនដោយពលកម្ម ដោយបង្ខំតែមួយនោះទេ ដែលជាធាតុផ្សំ។ ការរឹបអូសយកទ្រព្យសម្បត្តិសិទ្ធិជាសារវន្តរបស់បុគ្គល និង ការដាក់បង្ខំដោយអត់ពលកម្មដោយឥតមានផលប្រយោជន៍។ ប៉ុន្តែជាទូទៅ យើងត្រូវសួរខ្លួនយើងថា គ្រប់មន្ទីរឃុំឃាំងទាំងអស់នៃពិភពលោកនេះ ដែលទោសដាក់ឲ្យធ្វើការដោយពលកម្មដោយជាទម្ងន់ នោះ ទោសអស់មួយជីវិតហើយ ធ្វើពលកម្មជាទម្ងន់ ដូចជានៅ ចិន នៅសហអាមេរិក នោះ តើវាជា ធាតុផ្សំនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែរទេ? ចម្លើយថា ទេ គឺវាមិនអាចទេ។

[១០:០៦:៥៥]

ដូច្នេះ ការចាប់យកចំណុចតែមួយរបស់សហព្រះរាជអាជ្ញាមកចោទថា ការអនុវត្តនៅស-២៤ ចំពោះពលកម្មដែលអត់មានតម្លៃតបស្នង ហើយដាក់រឹតត្បិត ចំពោះសិទ្ធិសេរីភាពរបស់ជនរងគ្រោះនៅ ស-២៤ នោះ ថាជាទាសករគឺមិនត្រូវទេ។ ពីព្រោះថាមន្ទីរឃុំឃាំងណាក៏ដូចតែគ្នាដែរ កាលណាគេដាក់

គុកហើយ គឺបានន័យ គេកាត់សេរីភាពមិនឲ្យដើរឆ្វេចឆ្វាចទេ បើដើរបានតាមចិត្តមិនមែនជាមន្ទីរឃុំឃាំងទេ។ ហើយការធ្វើពលកម្មនេះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចយើងបានដឹងស្រាប់ហើយ គឺធ្វើស្មើគ្នាទាំងអស់ មិនមែនអ្នកជាប់ឃុំទេដែលធ្វើស្មើគ្នា ហើយមិនមែនតែអ្នកជាប់ឃុំទេ ដែលត្រូវកាត់របបអាហារ គឺយើងប្រជាជនទូទៅក៏កាត់របបអាហារដែរ រួមទាំងកម្មាភិបាលថ្នាក់កណ្ដាលរបស់របបកម្ពុជាប្រជាធិបតេយ្យផងដែរ។

ដូច្នេះ គ្មានទេធាតុចេតនាដែលដាក់ជាទាសករនៅស-២១។ មុនងារសំខាន់របស់ស-២១ ដូចកូនក្ដីរបស់ខ្ញុំបាទ កាំង ហ្គេកអ៊ាវ ហៅ ឌុច គាត់បានសារភាពហើយ។ គាត់មិនបដិសេធទេអំពើទារុណកម្មនៅទីនោះ វាពិតជាកើតមាន។ មុខងារសំខាន់របស់ស-២១ គឺសួរចម្លើយ ហើយសម្លាប់។ តែពីរហ្នឹងគត់។ ឯស-២៤ គឺជាវិធានការរដ្ឋបាលដាក់ចំពោះតែបុគ្គលិករដ្ឋបាលរបស់គាត់ ដែលប្រព្រឹត្តវិន័យខុសវិន័យស្រាលៗ តែប៉ុណ្ណោះ ដែលមានសំណាងណាស់ ហើយបានទៅនៅស-២៤ នោះ។

[១០:០៨:១៦]

វាមិនបម្រើឲ្យមុខងារក្នុងការដាក់ជាទាសករទេ ស-២១ ក៏ដូចស-២៤ ដែរ។ បើស-២១ មានតែយ៉ាងគត់ គឺសួរចម្លើយ វាយការណ៍ថ្នាក់លើចប់ សម្លាប់ចោល ចប់ហើយ។ ចូលស-២១ គ្មានថ្ងៃចេញទេ។ នេះជាតឹកតាង ជាភស្តុតាងដែលបញ្ជាក់ថា ស-២១ អវត្តមានការដាក់ជាទាសករ។ ប៉ុន្តែសំណួរថា តើយើងបដិសេធទេ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅស-២១ ផ្សេងៗទៀត ក្រៅពីការរំលោភសេពសន្ថវៈ ហើយនិងដាក់ជាទាសករ? មេធាវីមិនធ្វើសេចក្ដីសន្និដ្ឋានតបទៅនឹងសហព្រះរាជអាជ្ញាទេ ចំពោះបញ្ហានេះ ហើយកូនក្ដីរបស់ខ្ញុំបាទ ក៏មិនឆ្លើយតបទៅនឹងបញ្ហានេះដែរ ពីព្រោះថាគាត់បានសារភាពអស់ទៅហើយ នៅឯសាលាដំបូងរបស់ អ.វ.ត.ក។

[១០:០៩:០៣]

ឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា ចំពោះការ-- សារណារបស់សហព្រះរាជអាជ្ញាដែលនិយាយអំពីទោសស្រូប។ ការកាត់ទោសស្រូប គឺជាឆន្ទានុសិទ្ធិរបស់សហចៅក្រម ស្របតាមមាត្រា៣៩ (ថ្មី) នៃច្បាប់អ.វ.ត.ក ដែលកំណត់ទោសឧក្រិដ្ឋត្រូវផ្ដន្ទាទោសពីប្រាំឆ្នាំដល់មួយជីវិត។ ហេតុនេះ ឲ្យតែតុលាការកម្រិតទោសចន្លោះពីប្រាំឆ្នាំ ទៅទោសអស់មួយជីវិត គឺអត់វាខុសនឹងនីត្យានុកូលនៃទោសទេ។ ហេតុអីក៏ថាគាត់សម្រេចនេះខុស? ពីព្រោះទោសនេះវានៅចន្លោះពីហ្នឹង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទោះជាដកទាសករចេញ ដកការរំលោភសេពសន្ថវៈ ក៏នៅតែមានធាតុផ្សំនៃបទល្មើសបទឧក្រិដ្ឋកម្ម

ប្រឆាំងមនុស្សជាតិពេញលេញដែរ ហើយទោសពីប្រាំឆ្នាំទៅអស់មួយជីវិត គឺជាកាដាក់ទោសត្រឹមត្រូវ។

[១០:១០:០៩]

ប៉ុន្តែ ស្ថានភាពកូនក្តីខ្ញុំ ដែលខ្ញុំបានតវ៉ា ចំពោះការផ្តន្ទាទោសក្នុងបណ្តឹងសាទុក្ខ គឺថាដាក់ទោស ៣៥ឆ្នាំ វាធ្ងន់ធ្ងរហួស ចំពោះគុណភាពកូនក្តីខ្ញុំបាទ ដែលសារភាព និងធ្វើការសហការយ៉ាងល្អជាមួយនឹងតុលាការ មានគុណភាពជាសាក្សីផង ហើយត្រូវកាត់ទោសដោយទ្វេស្តង់ដារ។ សហព្រះរាជអាជ្ញាបានស្នើ *ដាប់ប៊ល ស្តេនដាត* ប្រើស្តង់ដាទ្វេរចំពោះកូនក្តីខ្ញុំ។ ដូចដែលយើងបានលើកពីម្សិលមិញហើយ ១៩៥ គុកទៀត អត់យកមកកាត់ទោសទេ យកតែមួយមកកាត់ទោស ហើយមួយនេះ សហការល្អណាស់ជាមួយនឹងតុលាការ បានបង្ហាញទាំងអស់ឲ្យតុលាការដំណើរការបានដោយរលូន។

[១០:១០:៤៦]

គាត់ត្រូវតែទទួលបាននូវស្ថានសម្រាល បើគាត់ត្រូវបានទទួលសម្រាល ចន្លោះតាមក្រមព្រហ្មទណ្ឌកម្ពុជា ស្ថានសម្រាលនេះត្រូវកំណត់ពី១៥ឆ្នាំ ទៅ ៣០ឆ្នាំ។ ហេតុនេះដាក់ទោសគាត់ដល់៣៥ឆ្នាំ គឺលើសទៅដល់៥ឆ្នាំទៅទៀត។ វាគួរតែស្ថិតនៅក្នុងការពិចារណាមួយដែលអង្គជំនុំជម្រះតុលាការកំពូលគួរពិចារណានោះ គឺថាផ្តល់ស្ថានសម្រាលឲ្យគាត់តែកម្រិតអប្បបរមា គឺ១៥ឆ្នាំ គឺគ្រប់គ្រាន់ណាស់ហើយ។

[១០:១១:២៣]

បាទ, ហេតុនេះខ្ញុំមិនធ្វើសេចក្តីថ្លែងការណ៍វែងតទៅទៀតទេ ព្រោះមិនមែនជាគោលជំហររបស់សហមេធាវីដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា ចំពោះសារណាបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាឡើយ។ ពីព្រោះយើងនៅតែយល់ថា អ.វ.ត.ក អត់មានយុត្តាធិការលើបុគ្គល កាំង ហ្កេកអ៊ាវ ហៅ ឌុចទេ ប៉ុន្តែដោយហេតុថា យើងបានទទួលនូវបទបញ្ជារបស់តុលាការកំពូលឲ្យឆ្លើយតប ហេតុនេះខ្ញុំសំណូមពរជាចុងក្រោយចំពោះការឆ្លើយតបរបស់ខ្ញុំនេះថា វាមិនមែនជាគោលជំហរពិតប្រាកដរបស់យើងទេ។ ប៉ុន្តែ ដោយតម្រូវតាមនីតិវិធី ខ្ញុំសំណូមពរសូមឲ្យតុលាការមេត្តា តុលាការកំពូលមេត្តាពិនិត្យពិចារណាលើស្ថានសម្រាលទោសក្នុងមាត្រាហ្នឹង។

[១០:១២:៣៨]

សូមឲ្យតុលាការកំពូលមេត្តាពិចារណាស្ថានសម្រាលទោស តាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ដែលកម្រិតទោសអប្បបរមាត្រឹម១៥ឆ្នាំ។

**ប្រធានអង្គជំនុំៈ**

អ៊ីចេះៗ លោកមេធាវី ទាក់ទងនឹងបញ្ហាការកំណត់ទោសហ្នឹង គឺយើងធ្វើនៅវគ្គក្រោយ។ ដូច្នេះ ចាំធ្វើសារណាតបនៅពេលក្រោយ។

**លោក កង ឫទ្ធារីៈ**

បាទ, អរគុណ។

[១០:១៣:១៧]

**ប្រធានអង្គជំនុំៈ**

លោកសហព្រះរាជអាជ្ញាមានអី-- សហមេធាវីមានអីបន្ថែមទេ?

**លោក ការ សាវុត្ថៈ**

សូមគោរពឯមឧត្តមប្រធាន សូមគោរពលោកចៅក្រមជាតិនិងអន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល។ ខ្ញុំសូមអនុញ្ញាតធ្វើការបកស្រាយបន្តិចអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ យោងតាមមាត្រា១២៨(ថ្មី) រដ្ឋធម្មនុញ្ញនៃព្រះរាជអាណាចក្រកម្ពុជាដែលបានចែងថា ជម្រះក្តីយុត្តិធម៌ គឺត្រូវធ្វើតាមនីតិវិធី និងតាមច្បាប់ជាធរមាន។ ហើយតុលាការ អ.វ.ត.ក យើងនេះ ជាតុលាការរបស់ជាតិត្រូវតែអនុវត្តតាមច្បាប់ជាតិ។ ហើយបើតាមច្បាប់ជាតិក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ត្រង់មាត្រា១៨៨ បានឲ្យនិយមន័យច្បាស់លាស់ណាស់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយបញ្ជាក់អំពីធាតុផ្សំរបស់វាទាក់ទងនឹងវត្តមាននៃសម្ព័ន្ធភាពប្រដាប់អាវុធ គឺជាអំពើដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ នៃការវាយប្រហារជាទូទៅ ជាប្រព័ន្ធសំដៅប្រឆាំងនឹងជនស៊ីវិល នេះបើតាមក្រមព្រហ្មទណ្ឌ។

[១០:១៤:៣៨]

បើជាទំនៀមទម្លាប់នៃច្បាប់អន្តរជាតិ អនុវត្តតែចំពោះទំនាក់ទំនងនានា រវាងរដ្ឋនិងរដ្ឋ ហើយមិនមែនអនុវត្តចំពោះអំពើរបស់បុគ្គលនោះឡើយ។ ហេតុដូច្នេះហើយ បុគ្គលទាំងឡាយពុំត្រូវបានដាក់ឲ្យទទួលខុសត្រូវតាមច្បាប់អន្តរជាតិ ដែលជាគោលការណ៍ច្បាប់មួយ ដែលមិនទទួលស្គាល់នៅក្រោមធម្មនុញ្ញនូរីមប៊ឺកទេ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនត្រូវបានអនុវត្តដោយផ្ទាល់នៅកម្ពុជា ក្នុងចន្លោះឆ្នាំ១៩៧៥ និង៧៩ នោះទេ។ ដូច្នេះ វាតម្រូវឲ្យមានការធ្វើច្បាប់ដើម្បីអនុវត្ត ហើយច្បាប់សម្រាប់អនុវត្តបែបនេះ មិនមានទេនៅពេលនោះ។

ហេតុនេះការទទួលខុសត្រូវ មិនអាចប្រមើលមើលទុកជាមុននៅកម្ពុជា ក្នុងចន្លោះពីឆ្នាំ១៩៧៥ ទៅ៧៩ នោះទេ ហើយប្រសិនបើកម្ពុជាអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយប្រព្រឹត្តផ្ទុយទៅនឹងមាត្រា១២ នៃវិធាន១២ នៃវិធាន អ.វ.ត.ក ក៏ដោយ ក៏អង្គជំនុំជម្រះត្រូវតែសម្រេចថា តើធាតុផ្សំនៃបទល្មើស និងអំពើល្មើសនីមួយៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សឃាតនោះមានអ្វីខ្លះ? ធាតុផ្សំនៃបទល្មើសនិងអំពើល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនអាចបកស្រាយបាន ឬស្រាយបំភ្លឺបានទេ ដរាបណាមិនទាន់រកឃើញអត្ថិភាពរបស់ពួកវានោះ។

[១០:១៦:២៧]

ដោយផ្អែកលើភស្តុតាងនៃធម្មនុញ្ញនូរ៉ឹមប៊ឺក និងច្បាប់ជាតិជាធរមាន ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឲ្យមានសម្ព័ន្ធភាពប្រដាប់អាវុធ។ ហេតុនេះ លក្ខណៈច្បាប់នៅចន្លោះឆ្នាំ១៩៧៥ ទៅ ១៩៧៩ មិនមានអ្វីច្បាស់លាស់នៅឡើយទេ។ បានសេចក្តីថា បើពិនិត្យទៅលើឧក្រិដ្ឋកម្មចន្លោះពីឆ្នាំ ១៩៧៥ ដល់ ៧៩ ពុំឃើញមានធាតុផ្សំច្បាស់លាស់ ឬអត្ថិភាព នៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឲ្យបានច្បាស់លាស់ឡើយ។ ទោះបីជារកឃើញថា មានអំពើល្មើសមួយចំនួនរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏គេបានទាញហេតុផលថា ការប្រព្រឹត្តឡើងក្នុងលក្ខណៈជាកម្មវិធី បោសសម្អាតក្នុងស្រុក មិនមែនជាលក្ខណៈជម្លោះប្រដាប់អាវុធប្រឆាំងនឹងវៀតណាម ឬថៃឡើយ។

[១០:១៧:៣៦]

ដូច្នេះ ការចោទប្រកាន់ដោយផ្អែកលើមូលដ្ឋានមាត្រា៥ នៃច្បាប់ អ.វ.ត.ក ទាក់ទងនឹងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឃើញថា បានព្យាយាមទាញតម្លៃពិតប្រាកដរបស់ច្បាប់ឲ្យដើរថយក្រោយ។ ហើយប្រព្រឹត្តផ្ទុយនឹងគោលការណ៍ជាទូទៅ នៃច្បាប់អន្តរជាតិ រួមមាន ការហាមឃាត់ ស្តីពីការធ្វើច្បាប់ជំនុំជម្រះក្រោយអង្គហេតុ។ បានសេចក្តីថា ច្បាប់ពុំមានអានុភាពជាប្រតិសកម្មបានទេ។ នេះជាអ្វីដែលខ្ញុំបាទលើកឡើងជូនទៅតុលាការ ដើម្បីតុលាការធ្វើការពិចារណា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញសហព្រះរាជអាជ្ញា ធ្វើការឆ្លើយតបនឹងចម្លើយរបស់សហមេធាវីការពារជនជាប់ចោទ។

**លោក អាន់ត្រូ ខេលី៖**

ខ្ញុំសូមលើកឡើងដោយសង្ខេប ជូនលោក លោកស្រីចៅក្រម។

សហមេធាវីការពារក្តីបានលើកឡើង អំពីបទរំលោភដែលកើតមាននៅក្នុងស-២១ ដែលតម្រូវឲ្យមានលក្ខណៈប្រព័ន្ធ ឬមានលក្ខណៈធំធេង។ យើងឃើញថា មានអំពើមួយដែលអាចកើតជាបទរំលោភសេពសន្ថវៈ។ ដូច្នេះ ខ្ញុំសូមធ្វើការបកស្រាយករណីនេះ ហើយយើងបានរកឃើញ យ៉ាងច្បាស់លាស់នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ។ ការវាយប្រហារនោះដោយខ្លួនឯង ដែលតម្រូវឲ្យមានលក្ខណៈប្រព័ន្ធ និងធំធេងមិនមែនតម្រូវឲ្យការរំលោភទៅលើជនជាប់ចោទនោះ ឲ្យមានលក្ខណៈប្រព័ន្ធ និងទូលំទូលាយនោះឡើយ។

[១០:១៩:៣៩]

លោក លោកស្រីចៅក្រម អាចពិចារណានៅក្នុងសាលក្រមរបស់សាលាដំបូង ដែលក្នុងនោះបានកំណត់ត្រង់កថាខណ្ឌ៣០១ ដែលក្នុងនោះចែងថា លក្ខណៈប្រព័ន្ធ និងធំធេងនោះ គឺវាមិនពាក់ព័ន្ធទៅនឹងបទល្មើសនីមួយៗ ដែលតម្រូវឲ្យមានលក្ខណៈធំធេងនោះទេ។ កថាខណ្ឌ៣០១ គេចែងតម្រូវអំពីការវាយប្រហារតែប៉ុណ្ណោះ ដែលមានលក្ខណៈប្រព័ន្ធ តម្រូវឲ្យមានលក្ខណៈប្រព័ន្ធ និងទូលំទូលាយមិនមែនកំណត់ថា អំពើនីមួយៗនៅក្នុងបទល្មើសនោះ តម្រូវឲ្យមានការលក្ខណៈទូលំទូលាយ និងលក្ខណៈប្រព័ន្ធនោះឡើយ។ សូមអរគុណលោក លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញចៅក្រមរបាយការណ៍ មានសំណួរទៅលើសហព្រះរាជអាជ្ញា និងសហមេធាវីជនជាប់ចោទ។

[១០:២០:០៨]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណលោកប្រធាន។ ដោយសារតែយើងមិនមានពេលវេលាយូរ ប៉ុន្តែចរិតលក្ខណៈពិសេសមួយ ឬក៏ពីរនេះគឺថា យើងមានការទាក់ទាញដោយសញ្ញាណនៃបទល្មើសដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ដែលសហព្រះរាជអាជ្ញាយល់ឃើញថា គួរតែផ្តន្ទាទោសជនជាប់ចោទ ដាច់ដោយឡែកដែល-- ប៉ុន្តែដែលនៅក្នុងយោងទៅតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ក៏ប៉ុន្តែ ខ្ញុំមានការចង់ដឹងថាតើខាងសហព្រះរាជ្ញាអាចបង្ហាញនូវជំហរនោះទៅ ទាក់ទងទៅនឹងនិយមន័យជាក់លាក់ នៃបទល្មើសនេះបានទេ ក្នុងលក្ខណៈជាឧក្រិដ្ឋកម្មអន្តរជាតិ ទាក់ទងទៅនឹងយុត្តាធិការពេលវេលារបស់ពេលវេលារបស់តុលាការនេះ?

**លោក អាន់ឌ្រូ ខេលី៖**

លោកស្រីចៅក្រម ដូចខ្ញុំបានលើកឡើងហើយថា និយមន័យនៃបទល្មើសនេះ គឺត្រូវបានគេធ្វើការអភិវឌ្ឍជាបន្តបន្ទាប់។ ប៉ុន្តែមិនមានន័យ មិនមានហេតុផលសម្រាប់តុលាការនោះទេ ក្នុងការដែលត្រូវរកមើលការបកស្រាយរបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ ក៏ដូចជាតុលាការសម្រាប់ប្រទេស រវ៉ាន់ដាដែលតុលាការទាំងនោះ អនុវត្តយុត្តិសាស្ត្ររបស់ខ្លួន ទាក់ទងទៅនឹងការបកស្រាយ ធាតុផ្សំនៃបទល្មើសទាំងអស់នេះ ដែលតុលាការនេះ គឺថាបានធ្វើការអភិវឌ្ឍចាប់ក្រោយពីសង្គ្រាមលោកលើកទី២ ហើយខ្ញុំស្នើសុំឱ្យតុលាការកំពូល មេត្តាពិនិត្យមើលទៅលើការណែនាំទាំងអស់នោះ ថាតើធាតុផ្សំនៃបទល្មើសទាំងអស់នេះបានកំណត់និងបកស្រាយដូចម្តេច? ដែលតុលាការទាំងនោះបានពិនិត្យមើលទៅលើប្រវត្តិ-សាស្ត្រ ហើយនិងទាក់ទងទៅនឹងការសម្រេចរបស់តុលាការទាំងពីរនោះ ទាក់ទងទៅនឹងបទល្មើសដែលលោកស្រីចៅក្រមបានសួរនេះ។

ហើយជំហររបស់ខ្ញុំ គឺមិនមានដូចគ្នា ប៉ុន្តែខ្ញុំបានជម្រាបជូនហើយ គឺថាក្នុងមួយអំឡុងក្រោយពីសង្គ្រាមលោកលើកទី២ មកគឺគេបានធ្វើការអភិវឌ្ឍនូវបទល្មើសមួយនេះ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញា មានចង់អីបន្ថែមទៀតទេ? បើមានសូមអញ្ជើញបន្ថែម។

**លោក អាន់ឌ្រូ ខេលី៖**

តាមយុត្តាធិការដែលខ្ញុំបានលើកហើយ ខ្ញុំមិនអាចឈរបានទេ ខ្ញុំការអនុញ្ញាតអង្គុយចុះ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមតុលាការប្រកាសសម្រាក ហើយម៉ោងដប់មួយយើងចូលវិញ ហើយសូមអញ្ជើញខាងមន្ត្រីពន្ធនាគារនាំជនជាប់ចោទចូលកន្លែងសម្រាកសិន។

**លោក ផន ធឿន៖**

បាទ, សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៥ នាទី ដល់ម៉ោង ១១:០២ នាទី)*

[១១:០២:០០]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ។ អង្គជំនុំជម្រះប្រកាសចូលដល់បណ្តឹងសាទុក្ខទាក់ទងនឹងការកំណត់ទោស។

សូមអញ្ជើញ សហចៅក្រមរបាយការណ៍ធ្វើសេចក្តីរាយការណ៍។ សូមអញ្ជើញ!

**ចៅក្រម ស៊ិន រិទ្ធ៖**

**ការកំណត់ទោស៖**

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្តន្ទាទោសលើជនជាប់ចោទ ៣៥ឆ្នាំ។ បន្ទាប់មក អង្គជំនុំជម្រះពិចារណាឃើញថា ត្រូវកាត់បន្ថយ ៥ឆ្នាំ ដោយយល់ឃើញថាមានការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទដែលបណ្តាលមកពីការឃុំខ្លួនខុសនីតិវិធី ដោយតុលាការយោធានៅកម្ពុជាចន្លោះពីថ្ងៃទី១០ ខែឧសភា ដល់ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងដាក់ស្លានទម្ងន់ទោសមិនគ្រប់គ្រាន់ទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយជនជាប់ចោទ និងតួនាទីដឹកនាំរបស់ជនជាប់ចោទ និងឆន្ទៈនៃការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។

[១១:០៣:៤១]

អង្គជំនុំជម្រះសាលាដំបូងដាក់ស្លានទម្ងន់ទោសមិនត្រឹមត្រូវ ដោយគិតស្លានសម្រាលច្រើនជាង និងកំណត់ទោសដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ជាក់ស្តែងមិនមានលក្ខណៈសមល្មម និងគ្មានភាពច្បាស់លាស់នោះទេ។ សហព្រះរាជស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលពិនិត្យកែប្រែការកំណត់ទោសដែលបានធ្វើឡើយដោយអង្គជំនុំជម្រះសាលាដំបូង ជាការដាក់ទោសពន្ធនាគារអស់មួយជីវិតឡើងវិញ។ បង្គាប់កំណត់ទោសនេះ បានកាត់បន្ថយមកដាក់ទោសពន្ធនាគារក្នុងរយៈពេល ៤៥ឆ្នាំ ដើម្បីផ្តល់ការទូទាត់សមស្របមួយដែលបានឃុំខ្លួនខុសនីតិវិធីច្បាប់មុនពេលការឃុំនៅ អ.វ.ត.ក។

បង្គាប់ថា ការកាត់បន្ថយបន្តទៀត ត្រូវធ្វើឡើងឲ្យបានសមស្រមចំពោះស្លានសម្រាលដែលមានកម្រិត ដែលត្រូវទទួលបាននៅក្នុងក្នុងកាលៈទេសៈនៃរឿងក្តីដោយមានការកាត់បន្ថយទោសជាអតិបរិមាមានត្រឹមតែ៥ឆ្នាំ ប៉ុណ្ណោះ។ សម្រេចថាជនជាប់ចោទនឹងត្រូវទទួលការផ្តន្ទាទោសដាក់ពន្ធនាគារ ដោយមិនមានការដោះលែងដោយមានលក្ខខណ្ឌឡើយ។ មេធាវីការពារក្តីមិនបានដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរ ទៅនឹងបណ្តឹងសាទុក្ខរបស់ព្រះរាជអាជ្ញាឡើយ។

[១១:០៤:៥៧]

មេធាវីការពារក្តីលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងប្រព្រឹត្តដោយកំហុសឆ្គងខកខានមិនបានពិចារណាឲ្យបានត្រឹមត្រូវលើមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩។ សហព្រះរាជអាជ្ញាបានធ្វើការឆ្លើយតបថា ទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលគ្មានមូលដ្ឋានច្បាស់លាស់ ឬនិយាយម្យ៉ាងទៀតខកខានបានបំពេញនូវលក្ខខណ្ឌតម្រូវការជាអតិបរមានៃបណ្តឹង គប្បីត្រូវបដិសេធចោលដោយអង្គជំនុំជម្រះតុលាការកំពូល។ សហព្រះរាជអាជ្ញាជំទាស់ផងដែរថា ទឡ្ហីករណ៍ទីពីរ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីមិនត្រូវផ្តាច់ចេញពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីអំពីយុត្តាធិការបុគ្គលិក។

ដូច្នេះហើយគប្បីត្រូវបដិសេធចោល ដោយមូលហេតុដូចគ្នានេះឯង។ សូមអរគុណ។

[១១:០៥:៥៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្តីថ្លែងអំពីសារណារបណ្តឹងសាទុក្ខទាក់ទងនឹងការកំណត់ទោស។ សូមអញ្ជើញ!

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតលើកទឡ្ហីករណ៍ជូនអង្គសវនាការ។

ចំណុចទីមួយ ដែលខ្ញុំលើកឡើងទាក់ទងទៅនឹងការកំណត់ទោសមានដូចតទៅ៖

គឺចំណុចដែលលើកឡើងដោយតុលាការកំពូលនៅក្នុងដីកាកំណត់ការបរិច្ឆេទសវនាការ ដែលក្នុងនោះអង្គតុលាការកំពូលស្នើសុំសួរមកយើងខ្ញុំថាតើក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ទាក់ទងទៅនឹងមាត្រា៦៨នោះ ដែលពាក់ព័ន្ធទៅនឹងការកំណត់ទោសនោះយ៉ាងម៉េច? នៅក្នុងនោះគឺបានលើកឡើងនៅក្នុងកថាខណ្ឌ៤ នៃដីកាកំណត់ការបរិច្ឆេទ។

[១១:០៧:០១]

នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើងពាក់ព័ន្ធទៅនឹងមាត្រា១០ និងមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌ-- ខ្ញុំសូមលើកសេចក្តីយោងនេះនៅត្រង់ចំណុចខុសគ្នា មាត្រា៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាចែងថា ក្នុងករណីមានការបន្ធូបន្ថយទោសដោយផ្អែកទៅលើ-- កាលណាបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមត្រូវផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសពន្ធនាគារក្នុងចម្លោះរវាង១៥ និង៣០ឆ្នាំ។ មាត្រា១០ ក្នុងនោះក៏បានចែងអំពីទោសផងដែរ។

[១១:០៧:៥៥]

កថាខណ្ឌទាំងឡាយខ្ញុំសូមលើកឡើងថា នៅក្នុង មានការប៉ះពាល់គ្នារវាងច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក និងបទប្បញ្ញត្តិនៃក្រមនេះត្រូវអនុវត្តដោយអនុលោមទៅតាមវិធានដែលមានចែងគន្ថីទីមួយនៃក្រមនេះ។ យើងខ្ញុំសូមលើកឡើងថា នៅក្នុងតុលាការនេះ មាត្រា៩៥ និងមាត្រា៦៦៨ ជាមាត្រាធរមានក្នុងអនុវត្តនៅក្នុងករណីនេះ។

ដូច្នេះហើយ ខ្ញុំគិតថា ខ្ញុំមិនលើកឡើងពាក់ព័ន្ធទៅនឹងមាត្រានេះទៀតទេ។ ប៉ុន្តែ ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់មាត្រា៦៦៨ គឺមានបទប្បញ្ញត្តិចែងដែលក្នុងនោះ ចែងថានៅក្នុងករណីដែលមានទំនាស់រវាងច្បាប់ និងបទល្មើសព្រហ្មទណ្ឌដោយឡែក និងបទប្បញ្ញត្តិដែរនៃក្រមនេះ ត្រូវអនុវត្តដោយអនុលោមតាមវិធានមានចែងក្នុងគន្ថីទីមួយនៃក្រមនេះ។ ប៉ុន្តែ នៅក្នុងកថាខណ្ឌចុងក្រោយនៃមាត្រាដដែលចែងថា បទប្បញ្ញត្តិនៃកថាខណ្ឌទីពីរខាងលើ មិនត្រូវយកមកអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេសឡើយ។

[១១:០៩:២១]

ពាក្យថា "ច្បាប់ព្រហ្មទណ្ឌពិសេសនេះ គឺសំដៅទៅលើច្បាប់ព្រហ្មទណ្ឌតុលាការនេះ"។ ហេតុដូច្នេះ អ្នករៀបចំសេចក្តីព្រាងនៃក្រមព្រហ្មទណ្ឌ២០០៩ បានបង្ហាញថាមាត្រា៩៥ គឺមិនត្រូវយកមកអនុវត្តចំពោះនីតិវិធីនេះឡើយ។

ដូច្នេះ ប្រសិនបើអ្នករៀបចំសេចក្តីព្រាងនៃច្បាប់ អ.វ.ត.ក ចង់ឲ្យយកមាត្រានោះមកអនុវត្តក្នុងនេះនោះ គេនឹងអនុម័តទៅលើច្បាប់នោះរួចទៅហើយ។ សភានឹងធ្វើការអនុម័តមាត្រា៩៥ យកមកអនុវត្តរួចទៅហើយ។ ប៉ុន្តែសភាបានចែងថា មាត្រានុំងមិនត្រូវយកមកអនុវត្តនៅក្នុងករណីនេះឡើយ។ ដូច្នេះ ទឡ្ហីករណ៍ទាំងឡាយដែលយើងបានលើកឡើង ជាពិសេសមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មិនត្រូវបានយកមកអនុវត្តពាក់ព័ន្ធទៅនឹងការដាក់ទោសនៅក្នុងករណីនេះឡើយ។

[១១:១០:៣០]

ខ្ញុំសូមបន្ថែមថា នៅក្នុងករណីណាក៏ដោយ មាត្រា៩៥ គឺមិនពាក់ព័ន្ធសម្រាប់ការពិចារណារបស់លោកចៅក្រមឡើយ។ ដោយសារតែយើងសូមបញ្ជាក់ថា ស្ថានសម្រាលដែលពាក់ព័ន្ធទៅនឹងកម្រិតនេះយើងត្រូវយកមកពិចារណា។ ដូច្នេះ មាត្រា៩៥ ទាក់ទងទៅនឹងស្ថានសម្រាល យើងមិនត្រូវយកមកអនុវត្តឡើយ។

[១១:១១:០០]

យើងខ្ញុំក៏បង្ហាញជំហរផងដែរថា មាត្រា៩៥ មិនត្រូវយកមកអនុវត្តចំពោះករណី អ.វ.ត.ក របស់យើងនោះទេ។ ដោយសារតែកិច្ចព្រមព្រៀងនិងច្បាប់ អ.វ.ត.ក វិធានទាំងឡាយបានចែងអំពីច្បាប់ពិសេសរបស់តុលាការនេះ។ សូម្បីចៅក្រម ឡាវ៉ែន៍ ដែលផ្តល់ជាមតិជំទាស់ទៅលើការដាក់ទោសក៏បានលើកឡើងផងដែរ នៅក្នុងការយល់ឃើញរបស់គាត់ថា វាជាការកំណត់ទោសខុស។ ដោយក្នុងនោះលោកចៅក្រមលើកឡើងថា តុលាការនេះត្រូវមានច្បាប់ពិសេសរបស់ខ្លួនត្រូវយកមកអនុវត្ត។

[១១:១១:៤២]

កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក គឺបានឆ្លុះបង្ហាញអំពីការចរចាវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ។ កិច្ចព្រមព្រៀងនិងច្បាប់ចែងអំពីប្រព័ន្ធច្បាប់ពិសេសពាក់ព័ន្ធទៅនឹងការកំណត់ទោសទៅជនជាប់ចោទក្នុងតុលាការនេះ។ ប្រសិនបើ អង្គសវនាការពិចារណាទៅលើកថាខណ្ឌ៥៧៤ នៅក្នុងករណីនេះជាពិសេសនៅក្នុងសាលក្រមបានចែងថា កិច្ចព្រមព្រៀងបានបង្កើតប្រព័ន្ធច្បាប់ពិសេស។ ដូច្នេះហើយ វាធ្វើឱ្យយើងមានការសង្ស័យថា តើមាត្រា៣៣(ថ្មី) នៃច្បាប់ អ.វ.ត.ក នោះ គឺ យើងត្រូវអនុវត្តយ៉ាងណាទាក់ទងទៅនឹងកិច្ចព្រមព្រៀង។ ការបកស្រាយនោះគឺថា ការដាក់ទោសនោះវាអាចជាអនុភាពត្រូវពិចារណាទៅលើកិច្ចព្រមព្រៀងផងដែរ។ ដូច្នេះ ការកំណត់ទោសនៅទីនេះយើងត្រូវអនុវត្តតាមច្បាប់ពិសេស។

[១១:១២:៥៦]

អង្គជំនុំជម្រះសាលាដំបូងរកឃើញទៀតថា លក្ខណៈអន្តរជាតិនៃបទល្មើសដែលកាត់ទោសទៅលើជនជាប់ ហើយនិងភាពមិនប្រាដកប្រជាទៅលើភស្តុតាងវិវឌ្ឍន៍នៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជាចាប់ពីឆ្នាំ១៩៥៦ មក គឺវាអាចឱ្យយើងគិតពិចារណាទៅលើការរបបនៃការកំណត់ទោសនៅក្នុងនេះ។

អ្នករៀបចំសេចក្តីព្រាងនៃកិច្ចព្រមព្រៀង និងអ្នករៀបចំសេចក្តីព្រាងនៃច្បាប់ អ.វ.ត.ក គឺគេអនុវត្តឱ្យយើងងាកចេញពីការអនុវត្តច្បាប់ជាតិ ដោយសារតែគេចង់បង្កើតនូវក្របខ័ណ្ឌពិសេសសម្រាប់តុលាការនេះ។ ឧទាហរណ៍ទាំងអស់នេះ អាចមើលឃើញនៅក្នុងមាត្រា១០ នៃកិច្ចព្រមព្រៀង ដែលក្នុងនោះងាកចេញពីច្បាប់កម្ពុជា ដែលត្រូវកំណត់ទោសជាប់ពន្ធនាគារអស់មួយជីវិត ដែលជាទោសអតិបរមាចំពោះទោសនៅ អ.វ.ត.ក។

[១១:១៤:០៤]

មាត្រា៣ នៃច្បាប់ អ.វ.ត.ក ចែងបំភ្លឺផងដែរថា ការកំណត់ទោសចំពោះបទល្មើសជាតិមានចែងនៅក្នុងមាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់ អ.វ.ត.ក។ ចំណុចទាំងអស់នេះ វាបង្ហាញអំពីការដាកចេញពីការមិនអនុវត្តក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

អវត្តមាននៃការចែងយោងទៅលើការអនុវត្តនឹងច្បាប់ជាតិក៏បានបង្ហាញថា កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក ជាច្បាប់មួយដោយឡែកពីសាលាក្តីអន្តរជាតិដទៃៗទៀត។ ដូច្នេះហើយក៏វាតម្រូវឲ្យចៅក្រមធ្វើការពិចារណាទៅលើក្របខ័ណ្ឌនៃការដាក់ទោសជាតិ នៅក្នុងក្របខ័ណ្ឌជាតិផងដែរ។

ឧទាហរណ៍៖ លោក លោកស្រីចៅក្រមអាចពិចារណាទៅលើលក្ខន្តិកៈមាត្រា២៤ នៃលក្ខន្តិកៈ អាយ. ស៊ី. ធី. វ៉ាយ ដែលក្នុងនោះចែងអំពីការកំណត់ទោស។

[១១:១៥:០០]

ខ្ញុំសូមលើកឡើងទោសដែលកំណត់ដោយសាលាដំបូង គឺត្រូវតែទោសជាប់ពន្ធនាគារ។ នៅពេលកំណត់ទោសពន្ធនាគារ ចៅក្រមត្រូវពិចារណាទៅលើការអនុវត្តជាទូទៅទាក់ទងទៅនឹងការកំណត់ទោសនៅប្រទេសយូហ្គោស្លាវី។ បទប្បញ្ញត្តិដូចគ្នានេះក៏មានចែងនៅក្នុងតុលាការ អាយ.ស៊ី.ធី.អ័រ នៅពេលដែលគេកំណត់ទោសអនុលោមតាមបទល្មើសអន្តរជាតិ។ ការខកខានមិនមានចែងនៅក្នុងច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងរបស់យើង បានគូសបញ្ជាក់អំពីគោលបំណងរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងចង់បង្កើតតុលាការនេះឲ្យមានច្បាប់ពិសេស។ ជាពិសេស ប្រសិនបើយើងមើលវិធានផ្ទៃក្នុង និងបទប្បញ្ញត្តិទាំងឡាយដែលធ្វើឡើងដោយចៅក្រម វាបញ្ជាក់អំពីលក្ខណៈពិសេសនៃរបបកំណត់ទោសនៅទីនេះ។ ប្រសិនបើយើងមើលវិធាន៩៨ នៃវិធានផ្ទៃក្នុងចែងថា "ប្រសិនបើរកឃើញទោសលើជនជាប់ចោទអង្គជំនុំជម្រះអាចធ្វើការកំណត់ទោសទៅតាមកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងនេះ"។

[១១:១៦:១៤]

នៅពេលដែលយើងអនុវត្តក្របខ័ណ្ឌដែលមានកំណត់នៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង វាបានបង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជម្រះមានអំណាចក្នុងការដាក់ទោសក្នុងចន្លោះទោសជាប់ពន្ធនាគារ-- ទោសប្រាំឆ្នាំ ទៅទោសជាប់ពន្ធនាគារមួយជីវិត ដោយយើងមិនចាំបាច់គិតទៅលើទឡ្ហីករណ៍ទាំងឡាយដែលបានលើកឡើង។ មានន័យថា យើងឃើញថា វាមិនមានច្បាប់ពិសេសណាមួយចែងនៅក្នុងច្បាប់ អ.វ.ត.ក តម្រូវឲ្យ អ.វ.ត.ក កំណត់បន្ថយទោសពីទោសពន្ធនាគារមួយជីវិត

មកត្រឹម៣០ឆ្នាំ នៅពេលដែលមានស្ថានសម្រាលទោសនោះឡើយ។

[១១:១៧:០៤]

គោលការណ៍ស្ថានសម្រាលទោស ក៏បានលើកឡើងដើម្បីជាផលប្រយោជន៍សម្រាប់អង្គជំនុំជម្រះនេះផងដែរ។ យើងខ្ញុំបង្ហាញជំហរថា គោលការណ៍នេះ គឺមិនទាមទារឲ្យមានការអនុវត្តមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩នោះទេ ចំពោះការកំណត់ទោសនៅក្នុងតុលាការនេះ។ ទាំងអស់នេះហើយ ជាហេតុផលដែលយើងបញ្ជាក់នៅក្នុងសារណារបស់យើងខ្ញុំ។

គោលការណ៍ស្ថានសម្រាលទោស គឺមានន័យថា ប្រសិនបើច្បាប់ពាក់ព័ន្ធទៅនឹងជនជាប់ចោទ ហើយបានធ្វើវិសោធនកម្មនោះ ច្បាប់ទាំងឡាយដែលមានលក្ខណៈស្រាលជាងគួរតែអនុវត្តចំពោះជនជាប់ចោទ។

មាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចែងនៅក្នុងផ្នែកពាក់ព័ន្ធថា ប្រសិនបើបទល្មើស ហើយមានបទប្បញ្ញត្តិណាមួយចែងអំពីទោសពន្ធនាគារ ឬក៏ទោសស្រាលជាងនោះ ជនជាប់ចោទ ជនសង្ស័យអាចទទួលផលប្រយោជន៍ពីករណីនេះ។ ជនជាប់ចោទរូបនេះ មិនអាចទទួលផលប្រយោជន៍នៅទីនេះនោះទេ តាមហេតុផលដូចដែលខ្ញុំបានលើកឡើង។ បទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មិនអាចយកមកអនុវត្តនៅក្នុងតុលាការនេះឡើយ។

គោលការណ៍ដែលពាក់ព័ន្ធទៅនឹងការកំណត់ទោស យើងមិនអាចយកមកអនុវត្តនៅទីនេះទេ ដោយសារតែអង្គជំនុំជម្រះមិនមានកាតព្វកិច្ចគោរពតាមនោះឡើយ ហើយជនជាប់ចោទក៏មិនអាចមានផលប្រយោជន៍-- ក៏មិនអាចទទួលផលប្រយោជន៍ពីករណីទាំងអស់នេះផងដែរ។

[១១:១៨:៤៦]

តុលាការយូហ្គោស្លាវី បានលើកឡើងអំពីគោលការណ៍មួយនៅក្នុងករណី នីកូលីក។ តុលាការកំពូលរកឃើញថា ជនជាប់ចោទអាចទទួលផលប្រយោជន៍ចំពោះទោសមានលក្ខណៈទន់ស្រាល ឬក៏ស្រាលជាង ប្រសិនបើមានធ្វើវិសោធនកម្មទៅលើច្បាប់។ ដូច្នេះ នៅពេលដែលមានទោសណាស្រាលមួយ យើងគួរតែកំណត់រយៈពេលទោសទៅតាមហ្នឹង។

[១១:១៩:១៥]

អង្គជំនុំជម្រះតុលាការកំពូល មានការប្រុងប្រយ័ត្នទៅលើចំណុចនេះ ដែលក្នុងនោះអនុញ្ញាតឲ្យយកគោលការណ៍សម្រាលទោសមកអនុវត្តចំពោះការកំណត់ទោសនៅក្នុងសាលាក្តីអន្តរជាតិ ដោយផ្អែក

ទៅតាមការធ្វើវិសោធនកម្មប្រព័ន្ធច្បាប់នៅក្នុងយូហ្គោស្លាវី។ រដ្ឋនៅក្នុងយូហ្គោស្លាវី មានអំណាចនៅក្នុងការផ្តល់អនុភាពទៅដល់សាលាក្តីអន្តរជាតិ។ តុលាការកំពូលរកឃើញថា មិនពាក់ព័ន្ធ។ ដូច្នេះហើយ វាមិនអាចធ្វើឱ្យបាត់បង់ ឬប៉ះពាល់អានុភាពសាលាក្តីអន្តរជាតិនោះឡើយ។

ខ្ញុំសូមបញ្ជាក់ដូចហេតុផលដែលខ្ញុំបានលើកឡើង នៅពេលដែលតុលាការនេះបានបង្កើតឡើង។ កិច្ចព្រមព្រៀងច្បាប់ និងបទប្បញ្ញត្តិគតិយុត្តិទាំងឡាយ បានចែងអំពីរបបកំណត់ទោសសម្រាប់តុលាការនេះរួចជាស្រេច។ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មិនមានកាតព្វកិច្ចចងឱ្យយើងគោរពតាមនោះទេ ហើយជនជាប់ចោទមិនអាចទទួលបទប្បញ្ញត្តិដែលកំណត់ទោសស្រាលជាងនេះតាមក្រមព្រហ្មទណ្ឌនោះឡើយ។

[១១:២០:២៦]

ជាការពិតតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃៗទៀត បានបដិសេធមិនអនុវត្តច្បាប់ក្នុងស្រុករបស់ខ្លួននៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយក៏មានបទប្បញ្ញត្តិចែងស្រដៀងគ្នាដែរ ដែលបទប្បញ្ញត្តិនោះមានដូចមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌដែលថាទោសត្រូវតែមានរយៈពេលខ្ពស់បំផុត៣០ឆ្នាំ។ ក្នុងករណីមានស្ថានសម្រាលទោស អាយ.ស៊ី.ធី.អ័រ បានសម្រេចនៅក្នុងសារណាថា បទប្បញ្ញត្តិស្រដៀងគ្នានឹងមាត្រា៩៥ មិនមានចងកាតព្វកិច្ចទៅដល់តុលាការ រវ៉ាន់ដា នោះទេ។

ដូច្នេះ ខ្ញុំសូមលើកឡើងថា ក្នុងករណីរបស់យើង ក្រមព្រហ្មទណ្ឌ មាត្រាហ្នុង មិនអាចអនុវត្តចំពោះករណីយើងនោះទេ ដូចមានចែងនៅក្នុងមាត្រា៦៨ ហើយលោកស្រី ជា លាង នឹងបញ្ជាក់បន្ថែម តុលាការនេះ ជាតុលាការមានច្បាប់ពិសេស មានក្របខ័ណ្ឌកំណត់ទោសពិសេសចំពោះការដាក់ទោសលើជនជាប់ចោទ ហើយជនជាប់ចោទមិនអាចទទួលផលប្រយោជន៍តាមរយៈបទប្បញ្ញត្តិដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩នោះឡើយ។

[១១:២១:៥៣]

លោកប្រធាន ថាតើយើងនឹងសម្រាកនៅម៉ោងដប់ពីរ ត្រឹមម៉ោងដប់ពីរឬយ៉ាងណានៅក្នុងថ្ងៃនេះ?

ដូច្នេះ ខ្ញុំនឹងព្យាយាមបញ្ចប់សារណារបស់ខ្ញុំត្រឹមអាហារថ្ងៃត្រង់ ហើយខ្ញុំសូមលើកឡើងដោយសង្ខេបទៅលើទស្សនៈករណ៍របស់យើងខ្ញុំលើការកំណត់ទោស។

យើងខ្ញុំសូមលើកឡើងថា សាលាដំបូងមានការភ័ន្តច្រឡំក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនលើការ

កំណត់ ហើយមិនបានកំណត់ទោសមួយឲ្យបានសមស្រប។ យើងខ្ញុំសូមលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំមួយចំនួនលើការកំណត់ទោស ហើយខ្ញុំសូមចូលទៅដល់ការភ័ន្តច្រឡំទាំងប្រាំមួយនោះ។

[១១:២២:៤៦]

ការភ័ន្តច្រឡំទីមួយ គឺសាលាដំបូងនៅក្នុងការរកឃើញរបស់ខ្លួន ថាមានស្ថានសម្រាលទោសច្រើននោះ ហើយការរកឃើញដូច្នេះ វាជាកំហុសមួយជាការភ័ន្តច្រឡំនៅក្នុងការបន្ធូរបន្ថយទោស។

យើងខ្ញុំសូមលើកឡើងថា សាលាដំបូងមានការបកស្រាយដោយភ័ន្តច្រឡំទៅលើការសំអាងរបស់ខ្លួន។ កថាខណ្ឌ៦០៦ ទៅដល់៦១១ បានបង្ហាញយ៉ាងច្បាស់នៅក្នុងសាលក្រមថា វាជាការភ័ន្តច្រឡំលើការបកស្រាយលើរបស់សាលាដំបូង។

[១១:២៣:២៨]

សាលាដំបូង បានរកឃើញថាមានស្ថានសម្រាលទោសជាច្រើន តាមការសន្និដ្ឋានរបស់សាលាដំបូង។ ប៉ុន្តែ សាលាដំបូងបានបដិសេធចោល ហើយមិនបានកំណត់ផ្តល់ទម្ងន់ទៅលើស្ថានសម្រាលនីមួយៗនោះឡើយ។

សូមឲ្យលោក លោកស្រីចៅក្រមមើលស្ថានសម្រាលទីមួយ គឺការបង្ខិតបង្ខំ និងការបញ្ជារបស់ថ្នាក់លើ។

ជាការពិត សាលាដំបូងបានបដិសេធការទទួលបញ្ជាពីថ្នាក់លើនិងការបង្ខិតបង្ខំ។ លោក លោកស្រីចៅក្រម អាចមើលនៅក្នុងកថាខណ្ឌ៦០៧ និង៦០៨ នៃសាលក្រមរបស់សាលាដំបូង។

សាលាដំបូងបានរកឃើញថា ជនជាប់ចោទបានដឹងបង្គាប់បញ្ជា ដែលគាត់ទទួលមកសម្លាប់អ្នកដែលជាប់ឃុំ ហើយទទួលបានការការពារពីអនុសញ្ញាទីក្រុងហ្សឺណែវនោះ គឺជាជនដែលត្រូវបានទទួលការការពារ។ សាលាដំបូងបានរកឃើញអំពីឆន្ទៈរបស់ជនជាប់ចោទ ចូលរួមនៅក្នុងការអនុវត្តគោលនយោបាយបំភិតបំភ័យ ហើយបានអនុវត្តមុខនាទីរបស់ខ្លួន ហើយគាត់ធ្វើការយ៉ាងមានប្រសិទ្ធភាព និងក្លៀវក្លា។

[១១:២៤:៤៨]

លោក លោកស្រីចៅក្រម អាចមើលកថាខណ្ឌលេខ៥៥៧ និង៥៥៧ (ស៊ីក) ជនជាប់ចោទជឿលើបក្សហើយនិងប្ដេជ្ញាក្នុងការអនុវត្ត ហើយមិនបានចាកចេញពីស-២១ ឡើយ។ គាត់ចាកចេញពី

ស-២១ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

សាលាដំបូងបានបង្ហាញក្នុងលក្ខណៈកម្រិតចំពោះបរិយាកាស ដែលគាបសង្កត់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយនិងការតតាំងរបស់ជនជាប់ចោទនៅក្នុងរបបនោះ។ ប៉ុន្តែ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាសូមលើកឡើងថា ទម្ងន់ដែលផ្តល់ទៅលើស្ថានសម្រាលទាំងអស់នេះ វាអាចមានចំណុចតិចតួចតែប៉ុណ្ណោះ ហើយមានអានុភាពតិចតួចតែប៉ុណ្ណោះនៅក្នុងការរកឃើញរបស់ខ្លួន ជាពិសេសលើការបង្ខិតបង្ខំ និងការទទួលបញ្ជាពីថ្នាក់លើ។ ឧទាហរណ៍ ប្រសិនបើ លោក លោកស្រីចៅក្រមមើលកថា៥៥៧ និង៥៥៨ គឺបានបង្ហាញអំពីការបង្ខិតបង្ខំ ក្នុងនោះជនជាប់ចោទមានឆន្ទៈ ហើយចូលរួមក្នុងការអនុវត្តគោលនយោបាយបំភិតបំភ័យក្នុងរបបនោះ។

[១១:៤៧:០៧]

ការសោកស្តាយ វិប្បដិសារី ដែលជាស្ថានសម្រាលទោសបានរកឃើញ។ សាលាដំបូងកត់សម្គាល់ឃើញថា មានការផ្តល់នូវការសម្តែងនូវវិប្បដិសារី ហើយវាហាក់ដូចជាមិនមែនជាការសម្តែងវិប្បដិសារីមួយស្មោះត្រង់ ហើយជនជាប់ចោទបែរជាធ្វើការសុំកាត់រួចខ្លួននៅក្នុងពេលកាត់ទោសជាលើកចុងក្រោយនៅក្នុងកថាខណ្ឌ នៅក្នុងសាលាដំបូងក៏បានបញ្ជាក់អំពីចំណុចទាំងអស់នេះ។

[១១:២៦:៤០]

កថាខណ្ឌមួយទៀតបង្ហាញអំពីស្ថានសម្រាលទោស។ សាលាដំបូងកត់សម្គាល់ឃើញថា តុលាការអន្តរជាតិបានគិតអំពីការស្តារនីតិសម្បទា ហើយសាលាដំបូងមិនបានបង្ហាញ និងផ្តល់ទម្ងន់គ្រប់គ្រាន់ទៅលើស្ថានសម្រាលនេះឲ្យបានត្រឹមត្រូវនោះទេ។

លោក លោកស្រីចៅក្រមអាចមើលកថាខណ្ឌ៦១១ នៃសេចក្តីសម្រេចរបស់សាលាដំបូង។

[១១:៤២:០៧]

ការសហការដែលជាស្ថានសម្រាលទោស។ ស្ថានសម្រាលនេះ គឺបានបង្ហាញដោយប្រៀបធៀបជាមួយស្ថានសម្រាលដទៃៗទៀត។ សាលាដំបូងហាក់ដូចជាធ្វើការពិចារណាដោយមិនមានការព្យួរនូវការគិតគូរមួយចំនួនផ្សេងទៀត។ ប៉ុន្តែ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញា សូមលើកឡើងថា សាលាដំបូងមានការភ័ន្តច្រឡំមិនបានផ្តល់ទម្ងន់ឲ្យបានគ្រប់គ្រាន់ទៅលើស្ថានសម្រាលទោសមួយនេះ ទោះបីជានៅចុងក្រោយមានការសុំឲ្យកាត់រួចខ្លួនពីជនជាប់ចោទក៏ដោយ។

ការតវ៉ាពីជនជាប់ចោទ ហើយនិងការតវ៉ាលើយុត្តាធិការរបស់បុគ្គលរបស់តុលាការនេះ ហើយប្រសិនបើយើងពិចារណាទៅលើការសហការជាស្ថានសម្រាលនោះ យើងមិនអាចធ្វើការសម្រាលទោសឲ្យគាត់ និងផ្តល់អានុភាពឲ្យបានគ្រប់គ្រាន់នោះឡើយ។ អ្វីដែលត្រូវអនុវត្តឲ្យបានពេញលេញទាក់ទងទៅនឹងកិច្ចសហការជាមួយនឹងអាជ្ញាធរ ធាតុសំខាន់មួយ គឺភាពអត្តនោម័តិ ឬអាត្មានិយមរបស់ជនជាប់ចោទនេះឯង។

[១១:២៨:២៨]

ច្បាប់ដែលខ្ញុំយកមកយោង គឺករណីរបស់ *ប្លាស៊ីវិច* នៅក្នុងតុលាការយូហ្គោស្លាវី តុលាការឧក្រិដ្ឋកម្មអន្តរជាតិ កថាខណ្ឌ៧៧៤ នៃសាលក្រមនោះ។ ដូចខ្ញុំបានលើកឡើងថា ការបកស្រាយលម្អិតបន្ថែមទៀតរបស់ជំហររបស់ជនជាប់ចោទនៅក្នុងបណ្តឹងសាទុក្ខ គឺបញ្ជាក់នៅខ្លឹមសារដែលមិនពាក់ព័ន្ធទៅនឹងស្ថានសម្រាលទោសនៅក្នុងរឿងក្តីនេះទេ។ ទាក់ទងទៅនឹងវិប្បដិសារីនេះ គឺផ្ទុយទៅវិញជនជាប់ចោទ គឺបែរជាស្នើសុំឲ្យមានការដោះលែងម្តងហើយម្តងទៀត ដែលជនជាប់ចោទ មិនមានការសុំទោស ឬវិប្បដិសារីដោយស្មោះត្រង់ និងសុទ្ធចិត្តនោះទេ។ ហើយប្រហាក់ប្រហែលនឹងគ្នានេះដែរ ជនជាប់ចោទបញ្ជាក់ថា គាត់មិនមែនជាអ្នកទទួលខុសត្រូវជាន់ខ្ពស់ចំពោះឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺមិនស្របទៅនឹងសញ្ញាណដែលថា គាត់បានសារភាពថាគាត់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ចំពោះរូបគាត់។

[១១:២៩:៤០]

លើសពីនេះទៅទៀត នៅក្នុងបណ្តឹងសាទុក្ខ គឺថាគាត់ចាត់ទុកថា គាត់ជាអ្នកទទួលខុសត្រូវតិចបំផុតចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងអំឡុងពេលនោះ។ ហើយអាចរកឃើញនៅក្នុងកថាខណ្ឌ៥៥នៃសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ។ ជនជាប់ចោទតវ៉ាគ្មានសំអាងទល់តែសោះ ហើយស្នើសុំឲ្យមានការដោះលែង ដោយលើកឡើងថា នៅក្នុងសារណារបស់ខ្ញុំ វាជាចរិតលក្ខណៈដែលយើងសហការជាមួយនឹងតុលាការនេះ។ ហើយកំហុសបន្ទាប់មកទៀត គឺអង្គជំនុំជម្រះសាលាដំបូង គឺថាបានដាក់ទម្ងន់មិនបានគ្រប់គ្រាន់ទៅលើស្ថានភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនេះ។

តុលាការព្រហ្មទណ្ឌអន្តរជាតិបានបញ្ជាក់ម្តងហើយម្តងទៀត ថាភាពធ្ងន់ធ្ងរនៃបទល្មើសមួយ គឺជាការព្រួយបារម្ភជាបឋមនៅក្នុងការដាក់ទោសក្នុងបទល្មើសអន្តរជាតិ។ មានករណីជាច្រើន ខ្ញុំសូមដកស្រង់តែពីរទេ គឺរឿងក្តី *ម៉ូហ៊ីម៉ាណា* ដែល អឹម-យូ-អេច-អាយ-អឹម-អេ-អ៊ិន-អេ *(Muhimana)*

សាលដីការបស់តុលាការរវ៉ាន់ដា កថាខណ្ឌ២៣២ ស្ថានទម្ងន់នៃបទល្មើសទាំងនេះ គឺជាការពិចារណាបឋមនៅពេលដែលគិតទៅដល់ការកំណត់ទោស ហើយឧក្រិដ្ឋកម្មនៅក្នុងសាលក្រម កថាខណ្ឌ៥៨៣ ដែលទាក់ទងទៅនឹងស្ថានទម្ងន់នៃបទល្មើស។

[១១:៣១:១៤]

នៅក្នុងសារណារបស់យើងខ្ញុំ គឺអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាទៅលើគោលការណ៍ជាមូលដ្ឋាន នៅពេលដែលពាក់ព័ន្ធទៅដល់ស្ថានទម្ងន់នៃបទល្មើសនេះ។ ក្រៅតែពីការដាក់ទោសស្រាលទៅលើជនជាប់ចោទនេះទៅវិញ។

នៅក្នុងសារណារបស់យើងខ្ញុំ ស្ថានទម្ងន់ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម គឺយើងអាចឃើញនៅក្នុងវិសាលភាព នៅក្នុងអំឡុងពេលនៃការប្រព្រឹត្តនោះ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ចុងចោទមានពិរុទ្ធភាពទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តអស់រយៈពេលជាងបីឆ្នាំ ដែលឈានទៅដល់ការសម្លាប់មនុស្សជាង១២.០០០នាក់ ដែលក្នុងនោះ គឺមានការធ្វើទារុណកម្មមុននឹងអ្នកទាំងនោះត្រូវបានយកទៅប្រហារជីវិតចោល។

[១១:៣២:០៧]

វិសាលភាពនៃគោលនយោបាយនេះ គឺគោលនយោបាយនៃភាពភ័យរន្ធត់ញាប់ញ័រ ដែលជនជាប់ចោទបានបង្កើតនូវវិសាលភាពដែលបានពង្រីករាលដាលនៅទូទាំងប្រទេសនៃប្រទេសកម្ពុជា។ បើសិនណាជាយើងមើលទៅលើប្រតិចារឹកនៅក្នុងទំព័រ៦៩ និង៦១ គឺថាសាក្សីជំនាញ ក្រេក អេតធេសាន់ បញ្ជាក់ថា ស-២១ គឺជាមន្ទីរសន្តិសុខមួយគត់ដែលអនុញ្ញាតឲ្យធ្វើទារុណកម្ម និងសម្លាប់អ្នកជាប់ឃុំឃាំងដែលត្រូវបានគេបញ្ជូនមកគ្រប់ទិសទីក្នុងប្រទេសកម្ពុជា។

[១១:៣២:៤៦]

កំហុសទីបី សាលាដំបូងគឺមិនបានដាក់ទម្ងន់គ្រប់គ្រាន់ទៅលើស្ថានទម្ងន់នោះទេ។ ស្ថានទម្ងន់នៅក្នុងរឿងក្តីនេះ គឺរួមមានជនជាប់ចោទគ្រប់គ្រង ហើយនិងបានរំលោភបំពានទៅលើអំណាចរបស់យើង ប្រព្រឹត្តយ៉ាងឃោរឃៅ មិនបានការពារទៅដល់ជនរងគ្រោះ ហើយខ្ញុំក៏បានលើកឡើងចំណុចទាំងអស់នេះហើយ។ ហើយលោក លោកស្រីចៅក្រម នឹងរកឃើញនៅក្នុងកថាខណ្ឌ៦៩២។

ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងពីខាងដើមរួចមកហើយ នៅក្នុងសារណាស្តីអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ យើងបានស្នើសុំឲ្យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ គឺដាក់នៅក្រោម

ការធ្វើទុក្ខបុកម្នេញ។ ទាក់ទងទៅនឹងការផ្តន្ទាទោសទៅលើបទល្មើសនីមួយៗដែលថា អង្គជំនុំជម្រះសាលាដំបូងគួរតែពិចារណាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងស្ថានទម្ងន់ទៅក្នុងបទល្មើសនីមួយៗ។ ប្រសិនបើអង្គជំនុំជម្រះដំបូងបានផ្តល់ស្ថានទម្ងន់គ្រប់គ្រាន់ នោះហេតុផលតែមួយគត់ គឺការដាក់ទោសអស់មួយជីវិត។

[១១:៣៤:១១]

កំហុសទីបួន គឺទោះបីជាស្ថានសម្រាលមាននៅក្នុងរឿងក្តីនោះក៏ដោយ ក៏សាលាដំបូង គឺថាបានរកឃើញការសម្រាលទោស។ ច្បាប់អន្តរជាតិបានចែងយ៉ាងច្បាស់ហើយថា តុលាការមិនត្រូវកាត់បន្ថយទោសដោយសំអាងទៅលើស្ថានសម្រាលទោសនេះទេ។ ក្នុងករណីដែលស្ថានទម្ងន់ គឺជាចំណុចមួយដែលពិសេស ដែលវាប៉ះពាល់ទៅដល់ស្ថានសម្រាល ឬក៏ថាវាមានកម្រិតបំផុតទាក់ទងទៅនឹងស្ថានសម្រាលទោសនេះ។

នៅក្នុងករណីរបស់ *ខេជេលីជេលី* ខ្ញុំសូមអានថា ខេ-អេច-ជេ-អ៊ី-អិល-អាយ-ជេ-អ៊ី-អិល-អាយ សាលដីកាតុលាការជាន់ខ្ពស់ ករណីនេះអាច គឺបានរកឃើញថាសាលាដំបូងមិនបានប្រព្រឹត្តកំហុសអ្វីទាក់ទងទៅនឹងស្ថានសម្រាលទោសមួយចំនួន ដែលស្ថានសម្រាលទោសនោះ គឺថាមិនបាន មិនមានអានុភាពទៅលើស្ថានទម្ងន់ ទាក់ទងទៅនឹងបទល្មើសដែលបានយកមកចោទប្រកាន់នោះទេ។

[១១:៣៥:២៦]

ករណីមួយទៀត មកពីតុលាការប្រទេស រវ៉ាន់ដា គឺរឿងក្តី *នីយ៉ែធីជីខេ* --អ៊ិន-អាយ-វ៉ាយ-អាយ-ធី-អ៊ី-ជី-អ៊ី-ខេ-អេ។ កថាខណ្ឌ២៦៧ សាលដីកាតុលាការជាន់ខ្ពស់ បានសម្រេចដាក់ពន្ធនាគារគាត់អស់មួយជីវិត ហើយបានកែប្រែសាលក្រមរបស់សាលាដំបូង បើទោះបីជាករណីហ្នឹងរកឃើញថាមានស្ថានសម្រាលទោសនៅក្នុងរឿងក្តីនេះក៏ដោយ។

សេចក្តីសម្រេចមួយទៀត មកពីតុលាការសម្រាប់ប្រទេសរវ៉ាន់ដា គឺ ស៊ីម៉ា សាលដីកាកថាខណ្ឌ៣៩៦ បានលើកឡើងថា ទោះបីជាសាលាដំបូងរកឃើញថាមានស្ថានសម្រាលទោសក៏ដោយ ក៏មិនត្រូវច្រានចោលនូវការដាក់ពន្ធនាគារអស់មួយ--ដាក់គុកអស់មួយជីវិតនៅក្នុងករណីដែលស្ថានទម្ងន់ គឺបង្ខំឲ្យត្រូវតែដាក់ទោសជននេះអស់មួយជីវិត។

[១១:៣៦:៣៧]

តុលាការព្រហ្មទណ្ឌអន្តរជាតិបានអនុវត្តចំពោះស្ថានទម្ងន់ទាំងអស់នេះ បើទោះបីជាជនជាប់

ចោទសហការជាមួយតុលាការក៏ដោយ ដូចជានៅក្នុងរឿងក្តីដែលខ្ញុំបានលើកឡើង គឺរឿងក្តីរបស់ *ស៊ីមី* សាលាដំបូងរកឃើញថា ជនជាប់ចោទសហការជាមួយតុលាការពេញដំណើរការនីតិវិធី បើទោះបីថាវាមានអំពើប្រល័យពូជសាសន៍កើតមាននៅក្នុងតំបន់នោះក៏ដោយ ហើយសារណានេះ គឺសម្រប សម្រួលទៅដល់ដំណើរការនីតិវិធីមួយ ដែលប្រព្រឹត្តទៅបានយ៉ាងឆាប់រហ័ស។ ប៉ុន្តែ នៅតែតុលាការដាក់ពន្ធនាគារជនជាប់ចោទនោះអស់មួយជីវិតដដែល។

[១១:៣៧:១៥]

ក្នុងករណីនេះ លោក លោកស្រីចៅក្រម គឺថាក្រៅពីកិច្ចសហការរបស់ជនជាប់ចោទ និងស្ថានសម្រាលទោសមួយចំនួននោះ សាលាដំបូងបានរកឃើញថា ស្ថានសម្រាលទោស គឺថាវាមានទម្ងន់ធ្ងន់ជាងនេះ ឬរឿងក្តីរបស់ ស៊ីម៉ា ហើយតុលាការជាន់ខ្ពស់ក៏បានកែប្រែសាលក្រមរបស់សាលាដំបូងនេះ។

[១១:៣៧:៤០]

កំហុសទីប្រាំ គឺសាលាដំបូងបានបង្កើតឲ្យមានកំហុស ដោយមិនបានពិចារណាទៅលើការកំណត់ទោសជាអន្តរជាតិ។ ខ្ញុំបានស្តាប់ឮសារណា បានឃើញសារណានេះពីសហភាតារបស់ខ្ញុំនៅទូទាំងពិភពលោក ដែលច្បាប់អន្តរជាតិមិនបាន-- ដូចជាវិធាន១១៧ នៃតុលាការយូហ្គោស្លាវី ដើម្បីជួយទៅដល់ទឡ្ហីករណ៍របស់ខ្លួននោះ។ គឺថា ប៉ុន្តែតុលាការនិយាយថា មិនអនុវត្តបាននោះទេ។ ប៉ុន្តែ តុលាការនេះសម្រាប់សារណារបស់យើងគឺយើងត្រូវពិនិត្យលើយុត្តិសាស្ត្រអន្តរជាតិ ពីព្រោះយុត្តិសាស្ត្រទាំងអស់នេះ ហើយដែលផ្តល់ការណែនាំ តុលាការនេះគឺបានកាត់បន្ថយស្ថានសម្រាល១៥ឆ្នាំនេះ គឺយុត្តិសាស្ត្រមួយចំនួនធំ គឺត្រូវតែសំអាង យកមកសំអាងនៅក្នុងការទាក់ទងទៅនឹងអង្គហេតុមួយចំនួន។ ទោះបីវាជាតុលាការកម្ពុជា តុលាការក្នុងស្រុកក៏ដោយ ប៉ុន្តែវាមានចរិតលក្ខណៈជាអន្តរជាតិ។

[១១:៣៨:៤៥]

សារណាដ៏ទូលំទូលាយរបស់យើង ដែលបានយោងទៅលើយុត្តិសាស្ត្រទាក់ទៅនឹងការកាត់ទោសនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ៗយើងខ្ញុំ។ សាលាដំបូងហាក់បីដូចជាមិនបានពិចារណាទៅលើទឡ្ហីករណ៍របស់យើងខ្ញុំនេះទេ។ មិនបានពិចារណាទៅលើករណីដែលយើងបានដាក់ជូនតុលាការ ដែលត្រូវយកមកពិចារណាទាក់ទងទៅនឹងការដាក់ទោសនេះ។

សាលាដំបូងមិនបានអនុវត្តឲ្យបានគ្រប់គ្រាន់ ដោយដាក់ពន្ធនាគារតែ៣៥ឆ្នាំ។ បើសិនណាជាតុលាការពិនិត្យមើលទៅលើតុលាការព្រហ្មទណ្ឌអន្តរជាតិដ៏ទៃទៀត ដែលការពិតនេះគឺថាការទទួលខុស

ត្រូវរបស់ជនជាប់ចោទ គឺបានបង្ហាញច្បាស់នៅក្នុងករណីនេះ ដែលថាតុលាការព្រហ្មទណ្ឌអន្តរជាតិ អាចនឹងដាក់ពន្ធនាគារអស់មួយជីវិត។

[១១:៣៩:៤២]

ដើម្បីលើកឡើងអង្គហេតុជាក់លាក់ទាំងអស់នេះ យើងបានពិនិត្យមើលទៅលើរឿងក្តីទាំងអស់នេះ ដែលមានការដាក់ពន្ធនាគារអស់មួយជីវិតឯណោះ។ យើងបានជ្រើសរើសករណីចំនួនប្រាំពីរ ពីករណីទាំងអស់ហ្នឹង គឺពីរ មកពីតុលាការយូហ្គោស្លាវី ប្រាំករណី ប្រាំមកពីតុលាការសម្រាប់ប្រទេសរវ៉ាន់ដា។ លោក លោកស្រីចៅក្រមអាចឃើញនៅចំពោះមុខហើយ គឺនៅតារាងមួយ ប្រសិនណាខ្ញុំអាចបង្ហាញជូនបាន។ លោកប្រធានសូមការអនុញ្ញាតទៅលើតារាង ដែលអ្វីដែលខ្ញុំនឹងត្រូវលើកឡើងនេះ។

[១១:៤០:២២]

សូមអរគុណលោកប្រធាន។ យើងបានជ្រើសរើសករណីចំនួនប្រាំពីរ ដោយយកករណីដែលថាជនជាប់ចោទ មានការទទួលខុសត្រូវនៅក្នុងរឿងទាំងអស់នេះ ហើយជនរងគ្រោះមួយចំនួនត្រូវបានសម្លាប់ ដែលជនជាប់ចោទ គឺថាគាត់ត្រូវតែទទួលខុសត្រូវ មិនអាចបដិសេធបានឡើយ។ រឿងក្តីនេះគឺថាមាននៅចំពោះមុខតុលាការអន្តរជាតិ ហើយចួនកាលពិបាកនឹងពិចារណាណាស់ ថាតើមានជនរងគ្រោះប៉ុន្មានដែលត្រូវគេសម្លាប់នោះ? ហេតុដូច្នេះឯង ទើបយើងខ្ញុំលើកយកករណីជាក់លាក់មួយចំនួននេះ។

[១១:៤១:០០]

យើងបានរកឃើញជាញឹកញាប់នៅតុលាការសម្រាប់ប្រទេសរវ៉ាន់ដា ដែលថាអ្នកដែលរកឃើញថាមានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មមួយចំនួននោះ នេះគឺត្រូវបានគេយល់យ៉ាងច្បាស់នៅតុលាការសម្រាប់ប្រទេសរវ៉ាន់ដា ដែលផ្តល់ប្រវត្តិសវតាមួយចំនួនសម្រាប់ធ្វើការផ្តន្ទាទោស មានទាំងពីការរំលោភហើយដែលគេបានជម្លៀសប្រជាជនចេញពីលំនៅដ្ឋានរបស់គេ នៅក្នុងរយៈពេលមួយដ៏ខ្លី ហើយក្នុងពេលនោះក៏មានអំពើប្រល័យពូជសាសន៍កើតឡើងនៅក្នុងប្រទេសរវ៉ាន់ដា នៅក្នុងរយៈពេលតែប៉ុន្មានខែ ដែលខុសពីរយៈពេលរហូតទៅដល់ជាងបីឆ្នាំនៅក្នុងរឿងក្តីនេះ។

យើងមិនអាចផ្តល់ជូនចំនួនជនរងគ្រោះពិតប្រាកដ ដែលបានសម្លាប់នៅក្នុងករណីទាំងអស់នេះទេ។ នេះគ្រាន់តែជាឧទាហរណ៍មួយ ពីព្រោះថាវាមិនមានយុត្តិធម៌ទេ បើសិនណាជាយើងយកចំនួនមិនជាក់លាក់ណាមួយយកមកបង្ហាញនោះ។

ខ្ញុំសូមបង្ហាញជាសង្ខេបទៅលើករណីនីមួយៗនេះ។

[១១:៤១:០៣]

នៅខាងឆ្វេង ជ្រុងខាងឆ្វេង គឺចុងចោទនៅក្នុងរឿងក្តី ហើយនៅខាងឆ្វេងបង្ហាញពីចំនួនអ្នកដែលស្លាប់ គឺមាន១២.៥០០នាក់ ហើយមានបង្ហាញរយៈពេលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ ហើយប្រសិនណាខ្ញុំយករឿងក្តីបន្ទាប់ពីរឿងក្តី *ហ្កាលីក* គឺជារឿងក្តីមកពីតុលាការសម្រាប់អតីតយូហ្គោស្លាវី គាត់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ២០ឆ្នាំ ហើយនិងនៅសាលាតុលាការជាន់ខ្ពស់សម្រេចដាក់ទោសអស់មួយជីវិត។ ហើយគាត់ត្រូវបានផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឃាតកម្ម អំពើអមនុស្សធម៌ ឧក្រិដ្ឋកម្មសង្គ្រាម និងការធ្វើទុក្ខបុកម្នេញទៅលើជនស៊ីវិល។

[១១:៤២:៥៨]

ជនជាប់ចោទទទួលខុសត្រូវក្នុងការសម្លាប់ជនរងគ្រោះ១០០នាក់ បង្ករបួសទៅដល់ជនរងគ្រោះ១.០០០នាក់ ហើយបានបង្ខំប្រជាជនចេញពីលំនៅដ្ឋាន៣០០.០០០នាក់ នៅក្នុងទីក្រុងសារ៉ាជីវ៉ូ ជនជាប់ទទួលខុសត្រូវចំពោះជនរងគ្រោះទាំង១០០នាក់ ដែលបាត់បង់ជីវិតនេះ។ ហើយរយៈពេលដែលប្រព្រឹត្តបទល្មើសនេះ គឺមានរយៈពេលតែបីខែប៉ុណ្ណោះ។

[១១:៤៣:៣៣]

ឥឡូវយើងមើលទៅលើរឿងក្តី អាយ.ស៊ី.ធី.វ៉ាយ ដែលខ្ញុំបានជ្រើសរើសឡើង ដែលត្រូវបានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ បណ្តឹងសាទុក្ខកំពុងតែរង់ចាំសេចក្តីសម្រេចពីតុលាការជាន់ខ្ពស់នៅក្នុងរឿងក្តីនេះ។ គឺមិនទាន់ឈានដល់ដំណាក់កាលចុងក្រោយនៃបណ្តឹងសាទុក្ខនៅឡើយទេ។ ប៉ុន្តែគិតឃើញថា រឿងក្តីនេះនឹងត្រូវដាក់គុកអស់មួយជិវិតដែរហើយ។

ជនជាប់ចោទនេះ គឺជាមេដឹកនាំនៃក្រុម *ស៊ើប* គាត់ប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការធ្វើទុក្ខបុកម្នេញឃាតកម្ម អំពើអមនុស្សធម៌ និងការសម្លាប់រង្គាល ក៏ដូចជាឧក្រិដ្ឋកម្មសង្គ្រាមនៃការប្រព្រឹត្តយ៉ាងឃោរឃៅ។

[១១:៤៤:១៤]

ជនជាប់ចោទរូបនេះទទួលខុសត្រូវចំពោះការសម្លាប់នោះ យ៉ាងហោចណាស់ក៏សម្លាប់មនុស្ស១៣២នាក់ដែរ គឺសម្លាប់ទាំងបុរសស្ត្រី និងកុមារ ជនជាតិ*មូសីរាល* ហើយក៏ដូចជាការធ្វើទារុណកម្មការវាយដំទៅលើអ្នកជាប់ឃុំឃាំងផងដែរ។ ការអំពើឃាតកម្ម គឺប្រព្រឹត្តឡើងតែក្នុងរយៈពេលមួយខែ

តែប៉ុណ្ណោះ ហើយការវាយដំ គឺមានរយៈពេលយ៉ាងយូរ។

[១១:៤៤:៤៦]

ឥឡូវនេះ ខ្ញុំសូមចូលទៅរឿងក្តីមួយទៀត គឺរឿងក្តីមកពីតុលាការ អាយ.ស៊ី.ធី.អាយ បុគ្គលនេះត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិត នេះបើតាមសាលដីការបស់តុលាការជាន់ខ្ពស់។ គាត់ជាចៅហ្វាយក្រុងរបស់ *ហ្គេមេ* គាត់ធ្វើការញុះញង់ឲ្យមានការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការសម្លាប់រង្គាល អំពើមនុស្សឃាត ទារុណកម្ម បទរំលោភសេពសន្ថវៈ និងអំពើអមនុស្សធម៌ដទៃទៀត។

ជនជាប់ចោទនេះផ្ទាល់ទទួលខុសត្រូវចំពោះមរណភាព ការសម្លាប់មនុស្ស២.០០០នាក់នៅពេលដែលគាត់ធ្វើជាចៅហ្វាយក្រុង ហើយគាត់ទទួលខុសត្រូវដោយផ្ទាល់ចំពោះការសម្លាប់ជនស៊ីវិលយ៉ាងហោចណាស់ ១៦នាក់ នៅចំពោះមុខវត្តមានរបស់គាត់ផ្ទាល់តែម្តង។ គាត់បានចូលរួម និងបានជំរុញឲ្យមានការរំលោភសេពសន្ថវៈទៅលើស្ត្រី។ ហើយរយៈពេលនៃការប្រព្រឹត្តនេះ គឺមានរយៈពេលតែបីខែប៉ុណ្ណោះ។

[១១:៤៦:០៨]

ករណីបន្ទាប់ គឺករណីទី៤ គឺករណី *ខ្លេវ៉ា* ករណីនេះ គឺជាករណីមកពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ផងដែរ។ ជនរូបនេះត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ជំហររបស់ជននេះគឺថា គាត់ជាឋានៈ នៅក្នុងមានឋានៈដឹកនាំឃុំមួយនៅក្នុងប្រទេសរវ៉ាន់ដា គាត់ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការធ្វើទុក្ខបុកម្នេញ គាត់ត្រូវបានរកឃើញថា ទទួលខុសត្រូវ ការចូលរួមក្នុងការញុះញង់ឲ្យមានការវាយប្រហារទៅលើវិហារសាសនា និងមានការបញ្ជាឲ្យសម្លាប់មនុស្ស។ គាត់ប្រព្រឹត្តបទល្មើសតែក្នុងរយៈពេលពីរខែប៉ុណ្ណោះ។

[១១:៤៦:៥៣]

រឿងក្តី *ខេលីខែស៊ីម៉ា* នៅក្នុងរឿងក្តីនេះ គាត់ត្រូវបានទទួលការផ្តន្ទាទោសនូវបទល្មើសបួនដោយដាក់ពន្ធនាគារអស់មួយជីវិត ក្រៅពីអំពើប្រល័យពូជសាសន៍។ គាត់ទទួលទោសស្រប គឺថាក្រៅអំពីអំពើប្រល័យពូជសាសន៍។ គាត់ត្រូវបានទទួលការផ្តន្ទាទោសបទចោទចំនួនបួន(៥) គាត់រកឃើញថាត្រូវបានទទួលខុសត្រូវក្នុងការញុះញង់ឲ្យមានការសម្លាប់រង្គាលបួនករណី។ ហើយចំនួនអ្នកស្លាប់ គឺថាមាន ៨.០០០នាក់ នៅក្នុងករណីទីមួយ ករណីទីពីរ ៤.០០០នាក់។ អ្នកខ្លះបានប៉ាន់ប្រមាណថា ចំនួនអ្នក

ស្លាប់នេះ គឺអាចច្រើនជាងនេះ ហើយការសម្លាប់រង្គាលទីបី គឺពី៤.០០០ ទៅ៥.០០០នាក់។ គឺរយៈពេលនៃការប្រព្រឹត្តបទល្មើស គឺប្រព្រឹត្តតែក្នុងរយៈពេលប្រហែលជាបីថ្ងៃ ទីមួយបីថ្ងៃ។ ហើយទីពីររាប់ពាន់នាក់ មនុស្សរាប់ពាន់នាក់ត្រូវបានប្រព្រឹត្តនៅក្នុងរយៈពេលតែបីខែ នេះរយៈពេលបន្ទាប់ពីបីថ្ងៃនេះ។

[១១:៤៨:១០]

ករណីបន្ទាប់មកទៀត គឺរឿងនៅពីតុលាការ អាយ. ស៊ី. ធី. អ័រ ផងដែរ គាត់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត គឺថាបណ្តឹងសាទុក្ខកំពុងតែរង់ចាំសេចក្តីសម្រេចនៅឡើយទេ។ គាត់គឺជាមេបញ្ជាការរបស់កងវរសេនាតូចមួយ គាត់ត្រូវបានផ្តន្ទាទោសអំពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត។ គាត់ទទួលខុសត្រូវចំពោះការស្លាប់មនុស្សជាង១២.០០០នាក់ ហើយការប្រព្រឹត្តគឺគាត់បានប្រព្រឹត្តតែក្នុងរយៈពេលមួយខែតែប៉ុណ្ណោះ។

[១១:៤៩:០១]

នៅក្នុងករណីចុងក្រោយ គឺករណីរបស់ជនជាប់ចោទឈ្មោះ *រ៉េនហ្សាហ៊ីរ*-- អា-អិន-អា-អ៊ី-អិនហ្សិត-- គឺរឿងមកពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា សាលាដំបូងបានសម្រេចដាក់ពន្ធនាគារអស់មួយជីវិត ហើយបណ្តឹងសាទុក្ខកំពុងតែរង់ចាំសេចក្តីសម្រេចរបស់តុលាការជាន់ខ្ពស់ គាត់ត្រូវបានផ្តន្ទាទោសពីបទប្រល័យពូជសាសន៍ គាត់ជាចៅហ្វាយខេត្ត ប្រព្រឹត្តអំពើមនុស្សឃាត ការរំលោភសេពសន្ថវៈ ឧក្រិដ្ឋកម្មសង្គ្រាម។ គាត់ត្រូវបានរកឃើញថា ទទួលខុសត្រូវក្នុងការសម្លាប់មនុស្សចំនួន១៤០នាក់ នៅក្នុងពេលបីដាច់ៗពីគ្នា ដែលក្នុងពេលនេះគឺថា គាត់ទទួលខុសត្រូវក្នុងការបញ្ជាឲ្យសម្លាប់អ្នកទាំងអស់នេះតែម្តង នៅចំពោះមុខវត្តមានរបស់គាត់។

ដូច្នេះ គាត់រកឃើញ ហើយគាត់រក ឃើញថា គាត់បានញុះញង់ឲ្យមានការរំលោភសេពសន្ថវៈស្ត្រីជាច្រើននៅក្នុងស្រុក-- ហើយគាត់មាន ការជំរុញលើកទឹកចិត្តឲ្យមានការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈនេះ។ អំពើនេះបានប្រព្រឹត្តតែក្នុងរយៈ ពេលបីខែតែប៉ុណ្ណោះ។

ប្រសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសូមបង្ហាញជូនក្រាហ្វិចចំនួនបីទៀត ដែលខ្ញុំគិតថាអាចបង្ហាញទៅដល់រូបភាពដែលខ្ញុំទើបពន្យល់អំម្បាញ់មិញនេះកាន់តែច្បាស់ជាងនេះទៅទៀត។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ! ប៉ុន្តែឲ្យខ្លីជាងនេះបន្តិច ជិតដល់ម៉ោងហើយ។

**លោក អាន់ឌ្រូ ខេលី៖**

បាទ សូមអរគុណលោកប្រធាន។

ក្រាហ្វិចពិសេសនេះ គឺបង្ហាញយ៉ាងច្បាស់នូវចំនួនមនុស្សដែលត្រូវគេបានសម្លាប់ បើប្រៀបធៀបពីរឿងក្តីដែលខ្ញុំទើបតែបានលើកជូនអម្បាញ់មិញ។ គឺថាចុងចោទបានសម្លាប់មនុស្សជាច្រើន ដែលបុគ្គលរូបនេះទទួលខុសត្រូវយ៉ាងខ្ពស់បំផុត។ ហើយចុងក្រោយប្រសិនណាខ្ញុំអាចបង្ហាញដ្យាក្រាមនេះបាន គឺរយៈពេលដែលបុគ្គលនេះប្រព្រឹត្ត គឺវាមានរយៈពេល វាមានទំហំលើសលប់ពីរឿងក្តីដែលបានលើកជូន។ ហើយសាលាដំបូង គឺបានទទួលស្គាល់ក្នុងការផ្តន្ទាទោសរយៈពេល៣៥ឆ្នាំនេះ គឺមិនពាក់ព័ន្ធទៅនឹងគោលការណ៍ទាំងពីរនៃការផ្តន្ទាទោសជាអន្តរជាតិនោះទេ។

[១១:៥១:២៦]

ទីមួយ គឺយើងអំពីកិត្តិយស ហើយនិងនិយាយអំពីការរៀងចាល។ ខ្ញុំមិននិយាយអំពីការសងសឹកទេ ខ្ញុំនិយាយអំពីការរំពឹងចង់បានរបស់ប្រជាជនកម្ពុជាពីតុលាការខ្មែរក្រហមនេះ។

តុលាការព្រហ្មទណ្ឌ អន្តរជាតិត្រូវតែធានាចំពោះនេះ-- ថាជនជាប់ចោទ ជនរងគ្រោះគឺមាន-- ចង់ឲ្យឃើញមានការផ្តន្ទាទោសទៅលើជនរូបនេះដើម្បីកុំឲ្យមានការប្រព្រឹត្តបទល្មើសម្តងទៀត។

[១១:៥២:០១]

តុលាការព្រហ្មទណ្ឌអន្តរជាតិក៏បានរកឃើញដូចគ្នានេះផងដែរ គឺថាទីមួយគឺធ្វើយ៉ាងណាឲ្យជននេះមានការរៀងចាល ហើយមូលហេតុគឺដើម្បីធានា-- ខ្ញុំសូមដកស្រង់ថា ជនល្មើសដែលបានផ្តន្ទាទោសនេះ គឺដើម្បីកុំឲ្យមានការជំរុញទឹកចិត្ត កុំឲ្យប្រព្រឹត្តបទល្មើសនេះតទៅទៀត។ ហើយសហគមន៍អន្តរជាតិនឹងមិនអនុវត្តទៅតាមការរំលោភដ៏ធ្ងន់ធ្ងរ បើគិតពិចារណាទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅក្នុងកថាខណ្ឌ៥០៦ នៃសាលក្រមរបស់ *ម៉ាស៊ី* ។

[១១:៥២:៤៤]

តុលាការព្រហ្មទណ្ឌអន្តរជាតិ បានពិចារណាស៊ីសង្វាក់គ្នាថា ស្ថានសម្រាលនេះ គឺមិនត្រូវផ្តល់ទៅដល់គោលបំណងដ៏ទៃទៀតនៅក្នុងការផ្តន្ទាទោសទេ។ ខ្ញុំជឿជាក់ជាក់ថា ហើយខ្ញុំបង្ហាញថា ការផ្តន្ទាទោសរយៈពេល៣៥ឆ្នាំនេះ គឺមិនគ្រប់គ្រាន់នោះទេ បើពិចារណាទៅលើវិសាលភាព និងអំឡុងពេលនៃការប្រព្រឹត្តបទល្មើសទាំងនេះ។

លោក លោកស្រីចៅក្រម ជាទីគោរព, ជាចុងក្រោយដូចដែលខ្ញុំបានលើកឡើងហើយថា អង្គជំនុំ

ជម្រះតុលាការកំពូលគួរតែដាក់ទោស ជននេះអស់មួយជីវិត ពីព្រោះ ដោយគិតពិចារណាចាប់ពីពេលឃុំខ្លួនជននេះនៅតុលាការយោធា។ ការកាត់បន្ថយមកដាក់ត្រឹមតែ៤៥ឆ្នាំ ប៉ុន្តែគោលបំណងនៃការចង់បានជាប្រវត្តិសាស្ត្រនេះ គឺស្នើសុំឲ្យដាក់ពន្ធនាគារអស់មួយជីវិតដោយសំអាងទៅលើសំអាងហេតុដែលខ្ញុំបានសំអាងជូនទាំងអម្បាលម៉ាននេះ។

[១១:៥៣:៤៥]

**ប្រធានអង្គជំនុំ៖**

មានពេលរហូតដល់ម៉ោងដប់ពីរ ប្រាំពីរនាទី បាទសូមអញ្ជើញបន្តទៅទៀត។

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាខ្ញុំអាចបញ្ចប់មុនពេលនេះ។ នៅក្នុងសេចក្តីសម្រេចរបស់រឿងក្តី *ខេលីលី* --ខេ-អ៊ី-ជេល-អ៊ី-អិល-អាយ *(Khjelijeli)* ការដាក់ពន្ធនាគារអស់មួយជីវិត ត្រូវបានកាត់មកត្រឹមតែ ៤៥ឆ្នាំ ដោយរកឃើញថាមានការរំលោភសិទ្ធិជនជាប់ចោទនៅក្នុងពេលឃុំខ្លួនបណ្តោះអាសន្ន។ មាននៅក្នុងកថាខណ្ឌ៣២៤ នៃសាលក្រមនៅក្នុងរឿងក្តីនេះ។

[១១:៥៤:៣៥]

នៅក្នុងកថាខណ្ឌ១១០៦, ១១០៩ នៃសាលដីកា។ ការដាក់កាត់បន្ថយមកដាក់គុក៤៥ឆ្នាំនោះ គឺដើម្បីសម្រួល-- ដើម្បីកាត់កងសងទៅលើ ការឃុំខ្លួនបណ្តោះអាសន្នជននេះ។ ហើយនៅក្នុង-- ដោយហើយខ្ញុំក៏ខ្ញុំលើកបង្ហាញជូនថា ការឃុំខ្លួន បណ្តោះអាសន្នដែលជាការរំលោភសិទ្ធិរបស់ជននេះ ដែលខ្ញុំបានលើកជូនលោក លោកស្រីចៅក្រម គឺមិនធ្ងន់ធ្ងរណាស់ណានោះទេ នៅក្នុងរឿងក្តីចំពោះមុខនេះ។ ដោយសារតែឃុំ-- នៅក្នុងរឿងក្តី *ខេលីលី* គឺមានការឃុំខ្លួនរហូតទៅដល់២១១ថ្ងៃឯណោះ។ ក៏ប៉ុន្តែម្យ៉ាងវិញទៀតករណីនេះ គឺជាករណី ដែលស្ថាប័នអន្តរជាតិផ្ទាល់បានពិចារណាទៅលើការដាក់ទោសហើយរកឃើញថាស្ថាប័នទាំងនេះបាន រំលោភទៅលើសិទ្ធិជនជាប់ចោទនៅក្នុងពេលឃុំបណ្តោះអាសន្ននៅតុលាការយោធា។ ហើយគឺថា មិនមែនស្ថាប័នតុលាការយើងនេះជាអ្នករំលោភសិទ្ធិនោះទេ។

[១១:៥៥:៥២]

លោក លោកស្រីចៅក្រមជាទីគោរព, នៅដើមដំបូងនៃដំណើរការនីតិវិធីនេះ កាលពីម្សិលមិញគឺលោកប្រធានបានចាប់ផ្តើមបើកសវនាការក្នុងនាមឲ្យអង្គការសហប្រជាជាតិ និងជនជាប់ចោទ ហើយជាពិសេស គឺខ្ញុំដែលតំណាងឲ្យអង្គការសហប្រជាជាតិដែលបំពេញការនៅទីនេះរួមគ្នា ជាមួយនឹងសហ

ការីរបស់ខ្ញុំ សហភាតារបស់ខ្ញុំ។ លោកចៅក្រមបានបើកដំណើរការនីតិវិធី ក្នុងនាម តាងនាមឲ្យប្រជាជនកម្ពុជា ហើយដែលយ៉ាងហោចណាស់ក៏ប្រជាជនកម្ពុជា ឬក៏យើងត្រូវឆ្លើយតបទៅនឹងប្រជាជនកម្ពុជា ដែលគាត់ស្រែកឃ្លាននូវយុត្តិធម៌នេះ គាត់ត្រូវការការផ្សះផ្សា សំខាន់បំផុតមិនមែនជា មិនមែនសហព្រះរាជអាជ្ញានោះទេ ដែលស្នើសុំនោះទេ គឺប្រជាជនកម្ពុជាដែលស្នើសុំឲ្យមាន ការផ្តន្ទាទោសនេះ ហើយដែលចៅក្រមនៅក្នុងតុលាការកំពូល ដោយសំអាងទៅលើការយល់ឃើញទៅលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្មទាំងអស់នេះ ហើយក៏ដូចជាស្ថានទម្ងន់ពាក់ព័ន្ធដទៃទៀត ជាពិសេសក្នុងនាម ជនជាប់ចោទជាមេ ជាថ្នាក់ដឹកនាំមួយរូប គឺត្រូវតែអនុវត្តការដាក់ពន្ធនាគារអស់មួយជីវិត ដែលអាចកាត់បន្ថយមកត្រឹមតែរយៈពេល៤៥ឆ្នាំ ដែលខ្ញុំគិតថាជាការសមស្រប។

ខ្ញុំសូមអរគុណលោកប្រធាន ក៏ដូចលោកស្រីចៅក្រមដទៃទៀតដែលបានយកចិត្តទុកដាក់ស្តាប់នូវទឡ្ហីករណ៍របស់ខ្ញុំយ៉ាងយកចិត្តទុកដាក់។ ហើយពេលនេះដល់ម៉ោងពិសាបាយថ្ងៃត្រង់ហើយ។

[១១:៥៧:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះតុលាការកំពូលសូមប្រកាសសម្រាកនាពេលនេះ ហើយនឹងបន្តនៅម៉ោងដប់បី និងសាមសិបនាទី ហើយបង្គាប់ឲ្យមន្ត្រីខាងពន្ធនាគារនាំជនជាប់ចោទទៅមន្ទីរឃុំឃាំងវិញ ហើយនិងនាំមកវិញនៅវេលាម៉ោងដប់បី និងសាមសិបនាទី។

*(សវនាការសម្រាកពីម៉ោង ១១ :៥៨ នាទី ដល់ម៉ោង ១៣:២៦នាទី)*

[១៣:២៦:១៣]

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ។ ជាបន្តទៅទៀតនេះ សូមអញ្ជើញចៅក្រម បើមានសំណួរសួរដល់សហព្រះរាជអាជ្ញា សូមអញ្ជើញ។

**ចៅក្រម ស៊ិន រិទ្ធ៖**

សំណួរខ្ញុំចំពោះសហព្រះរាជអាជ្ញា។ កាលពីព្រឹកមិញខាងសហព្រះរាជអាជ្ញានឹងបានពន្យល់ជាច្រើនទាក់ទងទៅនឹងការកំណត់ទោស ហើយនៅក្នុងបណ្តឹងសាទុក្ខត្រង់កថាខណ្ឌ១៣១ ក៏មានការកំណត់នៅក្នុងនុំង អំពីទោសដែរ។ ដូច្នេះខ្ញុំចង់ឲ្យសហព្រះរាជអាជ្ញាបញ្ជាក់បន្តិច តើសំអាងទៅលើច្បាប់អ្វី ឬក៏រូបមន្តអ្វី ដែលសហព្រះរាជអាជ្ញាទាមទារឲ្យកំណត់ទោសពី៤៥ឆ្នាំ ចុះមកដល់៤០?

បាទ, សូមអរគុណ។

[១៣:២៨:១៥]

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកចៅក្រម។ តួលេខ៤៥ឆ្នាំនេះ គឺផ្អែកទៅលើសេចក្តីសន្និដ្ឋានដើមរបស់យើង ដែលយើងបានដាក់ជូនចំពោះមុខសាលាដំបូង។ សេចក្តីសន្និដ្ឋាននោះ គឺមានបទដ្ឋានណែនាំមួយចំនួន ដូចជា ករណីយុត្តិសាស្ត្រអន្តរជាតិដែលគេបន្ថយទោសជាប់ពន្ធនាគារមួយជីវិត មកទោសជាប់ពន្ធនាគារជាក់លាក់។ វាបានបង្ហាញយ៉ាងច្បាស់ថា យុត្តិសាស្ត្រ និងករណីនេះបានកំណត់ដោយសាលាដំបូង ហើយកំណត់ រយៈកំណត់នេះមិនមែនយើងយកមកពីលើមេឃទេ គឺមានបទដ្ឋានអន្តរជាតិ យុត្តិសាស្ត្រអន្តរជាតិជាបទដ្ឋានណែនាំ ដូចដែលខ្ញុំបានលើកឡើង។

[១៣:២៩:០៨]

ខ្ញុំសូមនិយាយបទដ្ឋានយុត្តិសាស្ត្រនោះឡើងវិញ។ លោកចៅក្រម ប្រហែលជាចាំរឿងក្តីព្រឹកមិញហើយ។ រឿងក្តី *ខេលីលី* រួមទាំងរឿងក្តី *បារ៉ាយ៉ាហ្វីស្សា*។ ដូច្នេះហើយយើងបានកំណត់ថា វាទោសមួយសមរម្យ ដែលជនជាប់ចោទអាចទទួលដោយសារតែការឈឺចាប់របស់ជនរងគ្រោះ។ យើងដឹងថា យើងត្រូវតែកំណត់ទោសនោះ ជាប់ពន្ធនាគារមួយជីវិត ប៉ុន្តែយើងត្រូវដករយៈពេលនោះមកត្រឹមទោសរយៈពេលកំណត់ដោយសារតែមានការឃុំខ្លួនដោយខុសច្បាប់នៅតុលាការយោធា។

សូមអរគុណ។

[១៣:៣០:០៥]

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

ខ្ញុំមានសំណួរមួយ ចង់ចោទសួរទៅកាន់ខាងសហព្រះរាជអាជ្ញា។ សំណួរដំបូង ទីមួយ គឺកាលពីព្រឹកមិញលោកបានលើកឡើងរឿងក្តីមួយចំនួន ដែលគេធ្វើការជំនុំជម្រះនៅសាលាក្តីអន្តរជាតិនានា ដែល

រឿងក្តីទាំងនោះគេបានកំណត់ទោសជាប់ពន្ធនាគារអស់មួយជីវិត។ ដូច្នេះ តាមការយល់ដឹងរបស់លោក តើមានរឿងក្តីណាមួយផ្សេងទៀតដែរឬទេ ដែលមានភាពធ្ងន់ធ្ងរស្រដៀងគ្នា និងមានលក្ខណៈទំហំធំធេងស្រដៀងគ្នា ដូចរឿងក្តីយើង? ដែលរឿងក្តីស្រដៀងគ្នានោះ គេបានកំណត់ទោសជាប់ពន្ធនាគារមួយជីវិតនោះ។

[១៣:៣០:៥៨]

**លោក អាន់ទ្រូ ខេលី៖**

អ្វីដែលខ្ញុំចង់ស្នើឡើង ឆ្លើយតបទៅនឹងសំណួរនេះ គឺថាយើងបានធ្វើការដាក់ឯកសារជាលាយលក្ខណ៍អក្សរជូនលោកចៅក្រមរួមហើយ។ ខ្ញុំដឹងថា ខ្ញុំចាំរឿងក្តីជាច្រើននៅក្នុងចិត្តរបស់ខ្ញុំ ប៉ុន្តែមានរឿងក្តីជាក់លាក់មួយចំនួន ដែលវាមានលក្ខណៈធ្ងន់ធ្ងរស្រដៀងគ្នា ដែលនៅពេលនោះមានការផ្តល់ទោសស្រាលជាងទោសជាប់ពន្ធនាគារអស់មួយជីវិត។ ខ្ញុំគិតថា ខ្ញុំបានដាក់ជូនសារណាសេចក្តីសន្និដ្ឋានរបស់ខ្ញុំជាសង្ខេបៗទៅលើចំណុចទាំងអស់នេះហើយ។

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

សូមអរគុណ។ ដូច្នេះខ្ញុំនឹងធ្វើការពិគ្រោះយោបល់ជាមួយនឹងអង្គជំនុំជម្រះតុលាការកំពូល ថាតើតុលាការកំពូលនឹងធ្វើការអញ្ជើញឲ្យលោកដាក់ជាសារណាបន្ថែម ឬឯកសារបន្ថែមទៅលើបញ្ហានេះដែរឬទេ?

[១៣:៣១:៥៣]

ខ្ញុំចង់សូមសួរសំណួរទីពីរ។ សំណួរទីពីរ នោះគឺមានលក្ខណៈស្រដៀងគ្នា ដែលចៅក្រមអម្បាញ់មិញ ទើបតែសួរឡើងដែរ។ នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់លោក លោកបានស្នើសុំឲ្យមានការដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិត ហើយកាត់បន្ថយមកត្រឹម៤៥ឆ្នាំ ដោយសារតែការផ្តល់សំណងទៅការឃុំខ្លួនខុសច្បាប់។

ដូច្នេះយើងឃើញថា លោកបានបង្ហាញដោយប្រយោលថា ទោសអតិបរមា នៃការដាក់ពន្ធនាគារនោះគឺ៥០ឆ្នាំ ទោសអតិបរមា។ តើត្រឹមត្រូវដែរឬទេ? ប្រសិនបើត្រឹមត្រូវនោះ សូមឲ្យលោកធ្វើការបញ្ជាក់បំភ្លឺជាមួយនឹងមូលដ្ឋានផ្លូវច្បាប់ដែលលោកបានស្នើសុំលើចំណុចទោសអតិបរមានេះ។

សូមអរគុណ។

[១៣:៣២:៤៧]

**លោក អាន់ឌ្រូ ខេលី៖**

ឆ្លើយតបទៅសំណួររបស់លោកចៅក្រម យើងបានកំណត់រយៈពេលនេះដោយផ្អែកទៅតាមការគិតអំពីភាពធ្ងន់ធ្ងរនៃបទល្មើសជាក់លាក់ទាំងអស់នេះ។ គឺការតាមពិត យើងស្នើសុំរយៈពេល៤៥ឆ្នាំ ដោយយើងពិចារណាអំពីរយៈពេល ដែលមានការឃុំខ្លួនខុសច្បាប់។

ខ្ញុំគិតថា នៅក្នុងទិដ្ឋភាពមួយចំនួនតួលេខកំណត់នេះ គឺខ្ញុំគិតថា វាជាចំណុចមួយសំខាន់ ហើយដោយផ្អែកទៅលើការស្នើសុំដាក់ពន្ធនាគារនោះមួយជីវិត។ យើងស្នើសុំឲ្យមានការដាក់ពន្ធនាគារមួយជីវិតមែន។ ប៉ុន្តែ យើងត្រូវការបន្ថយរយៈនោះមកត្រឹមរយៈពេលកំណត់ ដោយសារតែមានការឃុំខ្លួនដោយខុសច្បាប់ពីតុលាការយោធា។ យើងមិនជំទាស់ទេ ប្រសិនបើអង្គជំនុំជម្រះមានកំណត់ មានការកំណត់រយៈពេលជាក់លាក់ណាមួយនោះ គឺគួរតែឲ្យវាស្របទៅតាមអ្វីដែលយើងស្នើសុំ៤៥ឆ្នាំ ឬក៏អាចលើសពីនេះ។ នេះជាចំណុចដែលខ្ញុំចង់បញ្ជាក់បំភ្លឺត្រង់ចំណុចនេះ។

[១៣:៣៣:៥៧]

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

សូមអរគុណ។ សំណួរទីបីដែលខ្ញុំចង់ចោទសួរនោះ គឺថាសេចក្តីសម្រេចសាលក្រមរបស់សាលាដំបូងបានរកឃើញថា ការឃុំខ្លួនរបស់ជនជាប់ចោទនៅចំពោះមុខតុលាការយោធា គឺមានលក្ខណៈខុសច្បាប់ដែលក្នុងនោះ គឺការឃុំខ្លួនខុសច្បាប់រយៈពេលប្រាំបីឆ្នាំ ប្រាំបីខែ ម្ភៃមួយថ្ងៃ ហើយដោយយើងកំណត់ថា យករយៈពេលនេះមកធ្វើជាការទូទាត់សំណង។

ដូចដែលលោកបានលើកឡើងកាលពីព្រឹកមិញ យើងឃើញមានយុត្តិសាស្ត្រមួយចំនួនតូចតែប៉ុណ្ណោះ នៅតុលាការអន្តរជាតិដែលក្នុងនុំងមានការផ្តល់សំណងទៅដល់ជនជាប់ចោទ ក្នុងករណីមានការឃុំខ្លួនខុសច្បាប់។ គឺការផ្តល់សំណងនោះ តាមរយៈការកាត់បន្ថយរយៈពេលជាប់ទោស។

[១៣:៣៤:៤៧]

នៅក្នុងរឿងក្តីទាំងអស់នោះបានបង្ហាញឲ្យយើងឃើញថា ការបន្ថយរយៈពេលជាប់ពន្ធនាគារជាសំណងនោះ គឺមានរយៈពេលវែងជាងរយៈដែលជាប់ឃុំដោយខុសច្បាប់។ ថាតើលោកផ្តល់ការសង្កេតទាក់ទងទៅនឹងចំណុចនេះយ៉ាងម៉េចដែរ ជូនតុលាការកំពូល?

**លោក អាន់ឌ្រូ ខេលី៖**

សូមឲ្យលោកចៅក្រម ធ្វើការលើកឡើងប្រយោគចុងក្រោយអម្បាញ់មិញនេះ ដោយសារតែខ្ញុំ

លែងមើលក្រដាស ខ្ញុំស្តាប់អត់ទាន់។

[១៣:៣៥:២៤]

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

ដូចដែលលោកបានលើកឡើងដោយសង្ខេបកាលពីព្រឹកមិញ។ មានករណីយុត្តិសាស្ត្រមួយចំនួនតូចតែប៉ុណ្ណោះនៅក្របខ័ណ្ឌអន្តរជាតិ ដែលយុត្តិសាស្ត្រទាំងអស់នោះមានការផ្តល់សំណងចំពោះការឃុំខ្លួនដោយខុសច្បាប់។ ការផ្តល់សំណងនោះ គឺគេធ្វើឡើងតាមរយៈការកាត់បន្ថយរយៈពេលជាប់ពន្ធនាគារ។ នៅក្នុងរឿងក្តីទាំងអស់នោះ បានបង្ហាញឲ្យយើងឃើញថា រយៈពេលដែលគេយកមកកាត់បន្ថយជាសំណងនោះ រយៈពេលហ្នឹងគេគិតគូរយូរជាងរយៈពេលដែលជាប់ឃុំខុសច្បាប់។ ថាតើលោកមានការសង្កេតយ៉ាងម៉េចដែរត្រង់ចំណុចនេះ?

[១៣:៣៦:០១]

**លោក អាន់ត្រូ ខេលី៖**

វាមិនចាំបាច់បន្ថយរយៈពេលនេះ យូរជាងរយៈពេលជាប់ឃុំដោយខុសច្បាប់ទេ វាអាស្រ័យទៅលើឆន្ទានុសិទ្ធិរបស់ចៅក្រម។ យើងគ្រាន់តែទទួលស្គាល់ថា វាមានការឃុំខ្លួនខុសច្បាប់ចំពោះរយៈពេលហ្នឹង។ ប៉ុន្តែ ចៅក្រមនៅទីនោះគេអនុវត្តឆន្ទានុសិទ្ធិរបស់គេ។ ដូច្នេះ តុលាការកំពូលក៏មានសិទ្ធិអនុវត្តឆន្ទានុសិទ្ធិក្នុងការកាត់បន្ថយដូចគ្នាដែរ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីចៅក្រម មីឡាត។

[១៣:៣៦:៣៧]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណ។ ខ្ញុំមិនមានបំណងចង់ពិភាក្សាទៅលើចន្លោះនៃការដាក់ទោសនេះ នៅក្នុងលក្ខណៈជាក់ស្តែង។ ប៉ុន្តែខ្ញុំចង់លើកឡើងអំពីក្របខ័ណ្ឌផ្លូវច្បាប់វិញ។ យើងបានយល់ហើយថា ទឡ្ហីករណ៍ដែលដាក់នៅចំពោះមុខយើងនេះ មានលក្ខណៈពិសេស។ ជាពិសេសពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាងក្រមព្រហ្មទណ្ឌ និងច្បាប់ អ.វ.ត.ក។ ការិយាល័យសហព្រះរាជអាជ្ញាហាក់ដូចជាបានលើកឡើងជំហរអំពីច្បាប់ អ.វ.ត.ក ជាមួយនឹងក្របខ័ណ្ឌច្បាប់ប្រទេសកម្ពុជាជារួម។ ខ្ញុំដឹងថា ពេលខ្លះទៅវាហាក់ជាមិនមានភាពសមស្រប។ យើងដឹងច្បាប់ អ.វ.ត.ក គឺចម្លងចេញពីច្បាប់កម្ពុជាទាក់ទងទៅនឹងការកាត់ទោស

ផងដែរនៅក្នុងសំណុំរឿង០០១។ ច្បាប់ អ.វ.ត.ក យើងដឹងថា យើងយកច្បាប់កម្ពុជាជាច្បាប់មួយយោង។

[១៣:៣៧:៤៦]

ដូច្នេះហើយវាបានបង្ហាញថា ច្បាប់ អ.វ.ត.ក មិនមែនជាបទប្បញ្ញត្តិមួយដាច់ដោយឡែកយកមកអនុវត្តទេ។ ប៉ុន្តែវាជាច្បាប់មួយដែលពិចារណាជាមួយនឹងក្របខ័ណ្ឌច្បាប់ជាតិ។ ដូច្នេះហើយ នៅពេលដែលយើងពិចារណាទៅលើលក្ខណៈពិសេសនៃតុលាការនេះ កាលពីព្រឹកមិញសហព្រះរាជអាជ្ញារួមទាំងសារណាររបស់ខ្លួនបានលើកឡើងឲ្យយើងជឿថា តើគោលការណ៍នៃលក្ខណៈពិសេសនេះគួរតែប្រើប្រាស់តាមរបៀបណា? និងជាពិសេសនៅពេលដែលយើងពិនិត្យ និងធ្វើការប្រៀបធៀបទៅលើបទប្បញ្ញត្តិព្រហ្មទណ្ឌ។

នៅក្នុងរឿងក្តីនេះយើងដឹងហើយ យើងធ្វើការប្រៀបធៀបនិយមន័យនៃបទល្មើស ប៉ុន្តែវិធានដូចគ្នាក៏យើងអនុវត្តអំពីនិយាម ឬវិធានបទដ្ឋាននៃក្រមព្រហ្មទណ្ឌ និងច្បាប់ព្រហ្មទណ្ឌផងដែរ។

[១៣:៣៨:៣៤]

ខ្ញុំមានការយល់ទៅលើចំណុចនេះ នៅពេលដែលយើងនិយាយអំពីការកំណត់ទណ្ឌកម្ម។ សហព្រះរាជអាជ្ញាបដិសេធមិនពិចារណាបទប្បញ្ញត្តិមួយចំនួនដែលវាមានលក្ខណៈ-- មានអានុភាពទៅលើច្បាប់ និងវិធានរបស់ អ.វ.ត.ក។ ហើយយើងដឹងថា ច្បាប់ អ.វ.ត.ក គឺកំណត់ទោសពីប្រាំឆ្នាំ រហូតទៅដល់អស់មួយជីវិត ជាពិសេសមាត្រា៣៩(ថ្មី)។ ក្រមព្រហ្មទណ្ឌ គឺនិយាយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលគេកំណត់ឲ្យដាក់ទណ្ឌកម្មជាប់ពន្ធនាគារអស់មួយជីវិត ហើយវាមានអានុភាពត្រូវពិចារណាទៅលើមាត្រា៩៥។ ខ្ញុំឃើញអំពីលក្ខណៈពិសេសនៅទីនេះ ហើយដូច្នេះហើយវាជាច្បាប់មួយដែលមាននៅពេលក្រោយ។

[១៣:៣៩:២៧]

ដូច្នេះថាតើលោកយោងយ៉ាងម៉េច ដែលថា វាជាច្បាប់មួយពិសេសនៅពេលដែលប្រៀបធៀបហើយនៅពេលដែលមានលក្ខណៈ-- មានច្បាប់ពិសេសជាក់លាក់ចែងនោះ យើងគួរតែអនុវត្តតាមច្បាប់ជាក់លាក់។

ដូច្នេះនៅពេលដែលយើងពិចារណាទៅលើអំពីទឡ្ហីករណ៍ ដែលលើកឡើងមុនអំពីគោលបំណងនៃច្បាប់ ហើយថាតើគោលបំណងនោះវាមានអានុភាពប៉ះពាល់យ៉ាងម៉េច? ហើយថាតើយើងគួរអនុវត្តច្បាប់ជាតិ ឬក៏យ៉ាងណា? ខ្ញុំចង់ចោទសួរ ថាតើបណ្តឹងសាទុក្ខនេះនិយាយក្នុងនាមប្រជាពលរដ្ឋ ឬ

ក៏យ៉ាងណា? នៅពេលដែលដើមបណ្តឹងសាទុក្ខលើកឡើងអំពីការខ្ទាស់គ្នារវាងបទប្បញ្ញត្តិនេះ ហើយយើងដឹងហើយថា ប្រសិនបើប្រជាពលរដ្ឋលើកឡើងថា វាមានផលប៉ះពាល់ និងអានុភាពដោយសារតែនៅក្នុងក្រមព្រហ្មទណ្ឌមានចែងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលកំណត់ទោសជាប់ពន្ធនាគារអស់មួយជីវិត។

[១៣:៤០:២៣]

ចំពោះសំណួរដដែល ថាតើវាជាលទ្ធផលអាចឲ្យយើងទទួលយកបានតាមរបៀបណាទាក់ទងទៅនឹងចំនួនចន្លោះរយៈពេលដែលជាប់ទោស ដូចដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា? យើងដឹងហើយ នៅក្នុងក្រមព្រហ្មទណ្ឌ គឺវាហាក់ដូចជាមានចែងដូចគ្នាទៅនឹងលក្ខន្តិកៈរបស់តុលាការព្រហ្ម-ទណ្ឌអន្តរជាតិ។ ប៉ុន្តែ មានការលើកឡើងមួយចំនួន ថាតើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិគឺយ៉ាងណា? ចំពោះគោលបំណងនៃច្បាប់ អ.វ.ត.ក ហើយទស្សីករណ៍ដែលថា ច្បាប់ទាំងអស់នេះវាមានការខ្ទាស់ជាមួយនឹងច្បាប់ជាតិនោះ ប្រហែលជាខាងសហព្រះរាជអាជ្ញាអាចធ្វើការពន្យល់លម្អិត ថាតើវាមានការខ្ទាស់គ្នាយ៉ាងម៉េចរវាងច្បាប់ជាតិនិងបទដ្ឋានអន្តរជាតិ? ហើយថាតើវាអាចទទួលយកបានស្របតាមក្របខ័ណ្ឌលក្ខន្តិកៈនៃច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិដែរឬទេ?

ហើយថាតើច្បាប់ជាក់លាក់គួរតែយកមកអនុវត្តហើយវាមានលក្ខណៈពិសេសចំពោះ អ.វ.ត.ក នោះគឺយ៉ាងណា?

[១៣:៤១:៣៨]

**លោក អាន់ឌ្រូ ខេលី៖**

សូមអរគុណលោកស្រីចៅក្រម មីឡាត។ សហព្រះរាជអាជ្ញាជាតិនឹងលើកឡើងទាក់ទងទៅនឹងចំណុចនេះផងដែរ។

ពាក់ព័ន្ធទៅនឹងច្បាប់ជាក់លាក់ដែលត្រូវយកមកអនុវត្តនោះ យើងបានដាក់ជូនអង្គជំនុំជម្រះរួចហើយថា អ.វ.ត.ក ជាប្រព័ន្ធតុលាការអនុវត្តច្បាប់ពិសេស ដែលបង្កើតយ៉ាងជាក់លាក់ហើយក្នុងនេះគឺមានការត្រូវតម្រូវឲ្យមានការចោទប្រកាន់ឧក្រិដ្ឋកម្មបទល្មើសអន្តរជាតិនិងជាតិ ដែលប្រព្រឹត្តឡើងក្នុងប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ១៩៧៩។ ជំហររបស់ខាងសហព្រះរាជអាជ្ញាទាក់ទងទៅនឹងគោលការណ៍ច្បាប់ពិសេសជាក់លាក់នេះ គឺដូច្នេះ។

ខ្ញុំដឹងហើយថា តើយើងខ្ញុំចង់មានន័យយ៉ាងម៉េច។ ខ្ញុំដឹងថាលោក លោកស្រីយល់ទៅលើចំណុច

នេះ បានន័យថាច្បាប់ជាក់លាក់ត្រូវយកមកអនុវត្តចំពោះច្បាប់ទូទៅ-- ច្បាប់ជាក់លាក់មានអានុភាពលើច្បាប់បទប្បញ្ញត្តិទូទៅ។

[១៣:៤២:៣៧]

យើងខ្ញុំសូមលើកឡើងគោលការណ៍នេះ គឺមិនអាចយកមកអនុវត្តបានទេនៅក្នុងករណីនេះ។ គោលការណ៍ច្បាប់អនុវត្តច្បាប់ជាក់លាក់នេះ វាពាក់ព័ន្ធទៅនឹងគោលការណ៍ចំនួនពីរ។ ទីមួយ គឺចងកាតព្វកិច្ចទៅដល់តុលាការ ហើយគោលការណ៍នេះគឺត្រូវអនុវត្តច្បាប់ជាក់លាក់ទៅលើបទប្បញ្ញត្តិទូទៅ។ ដូចដែលខ្ញុំបានលើកឡើងកាលពីព្រឹកមិញ យើងបានពន្យល់រួចហើយទាក់ទងទៅនឹងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មិនចងកាតព្វកិច្ចដល់អង្គជំនុំជម្រះនេះទេ។ ដូច្នេះហើយ មាត្រា៩៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាមិនអាចជាច្បាប់ពិសេស ឬជាក់លាក់នោះឡើយ។

[១៣:៤៣:២៣]

សហសេវិករបស់ខ្ញុំនឹងលើកឡើងបញ្ជាក់ទៅលើបញ្ហាហ្នឹង។ ខ្ញុំគ្រាន់តែចង់លើកឡើងទៅលើច្បាប់របស់តុលាការ អាយ.ស៊ី.ស៊ី ដែលមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។ បទប្បញ្ញត្តិនៅទីនោះ គឺគេមិនបានអនុវត្តនៅក្នុងតុលាការពិសេសៗនោះទេ។ ខ្ញុំមិនមែនថា វាមិនត្រឹមត្រូវទេបើសិនជាគេមិនអនុវត្ត។ ប៉ុន្តែ តុលាការអន្តរជាតិមួយចំនួន គេមិនអនុវត្តច្បាប់ដូចដែលខ្ញុំលើកឡើង។

ខ្ញុំសូមគ្រាន់តែបញ្ជាក់ថា តុលាការនេះមិនមានកាតព្វកិច្ចគោរពតាមបទប្បញ្ញត្តិ និងជាពិសេសមាត្រាដូចដែលខ្ញុំបានលើកឡើងនៅក្រមព្រហ្មទណ្ឌកម្ពុជានោះទេ។ ហើយខ្ញុំសូមអនុញ្ញាតឱ្យសហសេវិករបស់ខ្ញុំលើកឡើងបន្តបកស្រាយទៅលើចំណុចនេះ។ សូមអរគុណ។

[១៣:៤៤:២៦]

**លោកស្រី ជា លាង៖**

សូមអរគុណលោកចៅក្រមដែលបានលើកឡើងនូវសំណួរទាក់ទងនឹងមាត្រា៦៦៨ ដែលនៅមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌខាងកម្ពុជានេះ ហើយនិងវាមានពាក់ព័ន្ធនឹងការកំណត់ទោស ក្នុងការដាក់ទោសទៅលើជនជាប់ចោទ ក្នុងករណីដែលយើងរកឃើញថា ជនជាប់ចោទនោះបានប្រព្រឹត្តបទល្មើសក្នុងយុត្តាធិការរបស់ អ.វ.ត.ក។

ដូច្នេះមុនឈានទៅដល់ក្នុងការកំណត់ទោស ឬក៏ការអនុវត្តនូវមាត្រានេះ យើងត្រូវយល់អំពីគោលបំណងៗ ការរៀបចំក្នុងការក្រមព្រហ្មទណ្ឌឆ្នាំ-- នីតិវិធីព្រហ្មទណ្ឌដែលបានចេញជារូបរាងនៅ

ឆ្នាំ២០០៩នេះ វាមិនមែនជាការមួយដែលចងកាតព្វកិច្ចជាមួយនឹងច្បាប់ អ.វ.ត.ក ទេ។ នេះជាគោលបំណងក្នុងនាមខ្ញុំជាសមាជិកម្នាក់នៅក្នុងការរៀបចំចងក្រងក្នុងច្បាប់នេះដែរ។

ដោយសារហេតុអី? នៅក្នុងនេះ បើលើកឡើងអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ មិនមែនតែមានច្បាប់ និងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ទេ ដែលមានចែងហ្នឹង គឺថាច្បាប់ហ្នឹងមានចែងយូរហើយ។

[១៣:៤៥:៣០]

ហើយទីពីរ ច្បាប់នៅក្នុងមាត្រា១៨៨ ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ គឺជាមាត្រាមួយដែលស្ថិតនៅក្នុងហៅថាគន្ថីទីពីរៗនេះគឺមិនបានអនុវត្តភ្លាមទេ ក្រោយពីច្បាប់ហ្នឹងបានប្រកាសនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ហ្នឹង បានន័យថា នៅពេលដែលព្រះមហាក្សត្របានឡាយព្រះហស្ថហើយបានន័យថា មានតែគន្ថីទីមួយប៉ុណ្ណោះដែលអនុវត្តបាន។ ហេតុដូច្នេះហើយ ដែលវាមានការពាក់ព័ន្ធនឹងមាត្រា៦៨៨ ក្នុងការអនុវត្តដែលមានពាក់ព័ន្ធក្នុងនឹងបីចំណុចនៅក្នុង៦៨៨ នេះ។

[១៣:៤៦:០៥]

ខ្ញុំសូមទាញការចាប់អារម្មណ៍ទីមួយ ដោយសារនៅក្នុងមាត្រាហ្នឹង គឺយើងចង់និយាយថា មាត្រា៦៦៨ គឺមានចែងជាបីចំណុចផ្សេងៗគ្នា។ ទោះបីមិនមានចែងជាលេខរៀងលេខមួយ លេខពីរ លេខបី ប៉ុន្តែចែងខុសប្លែកពីគ្នាទាំងអស់។ ដូច្នេះ យើងពិនិត្យមើលទៅលើកថាខណ្ឌទីមួយ កថាខណ្ឌទីពីរ និងកថាខណ្ឌទីបី។ អ៊ីចឹងពេលនេះខ្ញុំលើកតែកថាខណ្ឌទីពីរ និងទីបីមកបញ្ជាក់ ដោយសារតែវាមានតែកថាខណ្ឌពីរនេះទេដែលពាក់ព័ន្ធនៅក្នុងការសម្រេច និងការស្នើសុំរបស់សហព្រះរាជអាជ្ញា ហើយនិងការ តើកាតព្វកិច្ចហ្នឹងត្រូវតែចងកាតព្វកិច្ចជាមួយនឹងច្បាប់ អ.វ.ត.ក ដែរឬអត់?

[១៣:៤៦:៤៥]

ក្នុងករណីកថាខណ្ឌទីពីរៗនេះគេនិយាយច្បាស់ណាស់អំពីបញ្ហាទំនាស់រវាងច្បាប់ ហើយនិងបទប្បញ្ញត្តិ។ អាហ្នឹងបានគេឲ្យយកគន្ថីទីមួយហ្នឹងអនុវត្ត។ គន្ថីទីមួយនេះគឺមានចែងនៅក្នុងមាត្រា១ និងមាត្រា១៨២-- ដល់១៨២ ក្នុងគន្ថីទីមួយហ្នឹង។ ដូច្នេះ យើងអាចយកអាហ្នឹងបាន។ ហើយមាត្រា៩៥វាស្ថិតនៅក្នុងគន្ថីទីមួយហ្នឹង។ អានេះក្នុងករណីដែលច្បាប់ដោយឡែក និងច្បាប់ដែលវាមានការទំនាស់គ្នា។

[១៣:៤៧:១៧]

ផ្ទុយទៅវិញ នៅក្នុងកថាខណ្ឌទីបីៗថាអាទីពីរហ្នឹងមិនអាចយកមកអនុវត្តបានទេ ចំពោះច្បាប់ដែលមានចរិតលក្ខណៈពិសេស ថាចរិតពិសេស។ អ៊ីចឹងគេប្រើពាក្យថា ចរិតពិសេស។ អ៊ីចឹងសំណួរសួរថាតើ ច្បាប់ អ.វ.ត.ក ហ្នឹងជាច្បាប់ដែលមានចរិតពិសេសដែរឬអត់? នេះជាសំណួរដែលយើងត្រូវតែពិចារណា អង្គជំនុំជម្រះត្រូវតែពិចារណាថា អ.វ.ត.ក មានលក្ខណៈពិសេសដែរឬអត់? ចរិតពិសេស។

[១៣:៤៧:៤០]

ប៉ុន្តែ ការយល់ឃើញរបស់សហព្រះរាជអាជ្ញា ដោយពិនិត្យទៅលើច្បាប់របស់ អ.វ.ត.ក ក៏ដូចជាច្បាប់ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ហ្នឹងដែរ ដែលយើងគិតថា ច្បាប់នេះវាមានលក្ខណៈពិសេស ច្បាប់ អ.វ.ត.ក ហ្នឹង។ ដោយសារហេតុអី? យើងពិនិត្យទីមួយទៅលើរចនាសម្ព័ន្ធនៃតុលាការ អ.វ.ត.ក តើ អ.វ.ត.ក ប្រៀបនឹងតុលាការជាតិត្រូវគ្នាទេ? វាអត់មានលក្ខណៈត្រូវគ្នាទេ សូម្បីតែសាលាឧទ្ធរណ៍យើងអត់មានផងនៅ អ.វ.ត.ក យើងនេះ។ នេះហើយជារចនាសម្ព័ន្ធមួយខុសគ្នា។

[១៣:៤៨:១០]

ទីពីរ តើវាខុសគ្នាដូចម្តេច? តាំងពីរបៀបរបបនៃការធ្វើការងារគ្នា យើងសុទ្ធតែមានភាគីជាតិនិងអន្តរជាតិត្រូវការសម្រេចឯកភាពគ្នាទាំងអស់។ ដូច្នេះ ការសម្រេច នីតិវិធី ក៏ដូចជារចនាសម្ព័ន្ធហ្នឹងវាមិនដូចទៅនឹងជាតិទេ បានគេចាត់ទុកថា ច្បាប់នេះជាច្បាប់មួយដែលមានចរិតពិសេស។ អ៊ីចឹងហើយដែលថា យើងចាត់ទុកថាចរិតពិសេសហើយ យើងត្រូវតែមិនយកអនុវត្តនូវគន្លឹទីមួយហ្នឹងមកអនុវត្តទេ។ អ៊ីចឹងហើយមើលកថាខណ្ឌទីបី ខ្ញុំ ចំពោះខ្ញុំយល់ថា វាមានលក្ខណៈច្បាស់លាស់ គឺថាមិនត្រូវយកមកអនុវត្តចំពោះច្បាប់ដែលមានចរិតពិសេសទេ។ ហើយខ្ញុំ សហព្រះរាជអាជ្ញាយល់ថា នឹងច្បាប់ អ.វ.ត.ក នៅតែមានលក្ខណៈចរិតពិសេសដដែល។ អ៊ីចឹងហើយបានជាមានការសម្រេច ហើយនៅក្នុងមាត្រា៣៩នេះ (ថ្មី) នៅក្នុងច្បាប់ អ.វ.ត.ក វាមានចែងច្បាស់ទៀត។ វាមានចែងច្បាស់មួយគឺថា មានមាត្រាមួយនេះគឺចែងអំពីការផ្តន្ទាទោស។

[១៣:៤៩:០៥]

ការផ្តន្ទាទោសហ្នឹងក្នុងមាត្រានេះ គឺថាចំពោះសហព្រះរាជអាជ្ញាអត់គិតថា ការសម្រេចទោសហ្នឹងខុស ឬត្រូវ មិនចោទថាចៅក្រមស៊ើប-- ចៅក្រមជំនុំជម្រះថាកាត់ទោសហ្នឹងខុស ឬត្រូវទេ ប៉ុន្តែគ្រាន់តែជាសំណើសូមឲ្យមានការដំឡើងទោសទេ។ តែត្រង់ថាអង្គជំនុំជម្រះសម្រេច៣៥ឆ្នាំ ដោយផ្អែកលើច្បាប់អី គឺសហព្រះរាជអាជ្ញាអត់មានចម្ងល់លើបញ្ហាហ្នឹងទេ។ ដោយសារគាត់យល់ឃើញ ដូចដែល

សហព្រះរាជអាជ្ញាយល់ឃើញថា គាត់បានយកច្បាប់ពិសេសហ្នឹងមកអនុវត្ត។ ដូច្នេះ គាត់មិនមានកំហុសទេ។ គាត់ឲ្យតែគាត់ដាក់ក្នុងកម្រិតមួយពីប្រាំឆ្នាំដល់អស់មួយជីវិត ដូច្នេះគាត់អត់មានខុសដូចអ្វីដែលបានចែងក្នុងមាត្រា៣៩(ថ្មី) អ៊ីចឹង។

[១៣:៤៩:៤៥]

អានេះដែលយើងគិតថា ដោយឡែកអ្វីដែលយើងទាមទារនៅក្នុងបណ្តឹងឧទ្ធរណ៍របស់យើងនេះ គឺការដំឡើងទោសក្នុងការផ្តន្ទាទោសជនជាប់ចោទឲ្យបានឡើងជាងហ្នឹង ដែលយើងគិតថា មិនសមនឹងបទឧក្រិដ្ឋដែលគាត់បានប្រព្រឹត្ត។ អានេះអ្វីពីរផ្សេងខុសគ្នា ហើយនិងការភ្ជាប់កាតព្វកិច្ច ខ្ញុំគិតថាវាអត់មានបញ្ហាដែលឆ្នាំ២០០៩ហ្នឹង មានកាតព្វកិច្ចត្រូវតែអនុវត្តតាមក្នុងគន្លីទីមួយ គឺថាអត់ត្រឹមត្រូវទេ ដោយសារច្បាប់នេះ គន្លីទីមួយអនុវត្តបានភ្លាមនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។ ដោយឡែក ក្រោយគន្លីនេះ គឺយើងអនុវត្តចូលជាធរមានក្រោយមួយឆ្នាំឯណោះ ក្រោយមួយឆ្នាំ។ ដូច្នេះ សូមពិនិត្យមើលច្បាប់២០០៩ ហ្នឹងឲ្យម្តងទៀត ដើម្បីដឹងថា តើភាគណាដែលយើងអនុវត្តបាន ភាគណាដែលយើងមិនទាន់អនុវត្តបាន។ សូមអរគុណ។

[១៣:៥០:៤៤]

**លោក អាន់ទ្រូ ខេលី៖**

ចុងក្រោយ សូមគោរពលោក លោកស្រីចៅក្រម។ ចៅក្រម មីឡាត បានពន្យល់ថា វាមានការយោងមួយចំនួននៅក្នុងច្បាប់កម្ពុជា ដែល ហើយនិងច្បាប់ការបង្កើតតុលាការនេះ។ ចំណុចដែលខ្ញុំសូមលើកឡើងឆ្លើយតបទៅនឹងចៅក្រមមានដូចតទៅ៖

ជាការពិត យើងឃើញមានការចែងយោងចំនួនពីរទៅច្បាប់កម្ពុជា ដែលជាច្បាប់សារធាតុ គឺមាត្រា២(ថ្មី) និងមាត្រា៣(ថ្មី) ជាពិសេសពាក់ព័ន្ធទៅនឹងនៅពេលដែលលោកចៅក្រមលើកឡើងអំពីការដាក់ទោស និងរបបនៃការដាក់ទោស។ សូមឲ្យលោក លោកស្រីចៅក្រមមើលមាត្រា៣(ថ្មី) ដែលក្នុងនោះគឺមានការបញ្ជាក់បទប្បញ្ញត្តិយ៉ាងច្បាប់លាស់នៃច្បាប់ អ.វ.ត.ក ដែលមាត្រានោះ ចែងអំពីចន្លោះទោសរហូតដល់ជាប់ពន្ធនាគារមួយជីវិត។

[១៣:៥១:៤៤]

ហើយប្រសិនបើយើងមើលមាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់ អ.វ.ត.ក ជាពិសេសមាត្រា៣៩ នោះ គឺនៅក្នុងនោះមានការកំណត់ របបនៃការដាក់ទោសពីចន្លោះប្រាំឆ្នាំទៅដល់អស់មួយជីវិត ដោយ

មិនមានការចែងយោងថា ត្រូវពិចារណាទៅលើក្រម ឬក៏ច្បាប់ព្រហ្មទណ្ឌកម្ពុជានោះទេ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ថា សភាជាតិដែលបង្កើតតុលាការនេះ ហើយនិងច្បាប់នេះ គឺជាការបង្កើតរបបដាក់ទោសមួយពិសេស និងជាក់លាក់សម្រាប់តុលាការនេះឯង។ សូមអរគុណ។

[១៣:៥២:៣០]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាតះ**

លោកប្រធានហាក់ដូចជាអនុញ្ញាតឲ្យខ្ញុំសួរស៊ីជម្រៅបន្ថែមទៀតពាក់ព័ន្ធទៅនឹងការកំណត់ទោសនេះ។ ខ្ញុំមានការចាប់អារម្មណ៍ក្នុងការលើកឡើងថា ហេតុអ្វីបានជាសហព្រះរាជអាជ្ញាលើកឡើងថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អនុវត្តបាន ហើយមិនអនុវត្តបានទេ ហើយក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មិនអាចអនុវត្តបាន។

យើងដឹងហើយថា តុលាការនេះបង្កើតឡើងដោយច្បាប់របស់សភាដែលបានអនុម័តហើយបង្កើតក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា។ ចំពោះការយោងទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលយើងតម្រូវឲ្យអនុវត្តនោះ ដោយសារតែយើងគិតគូរអំពីគោលការណ៍គ្មានបទល្មើស-- គ្មានច្បាប់ ប្រសិនបើគ្មាន-- គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង។ ដូច្នេះទើបយើងបញ្ចូលក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

[១៣:៥៣:៣២]

ប៉ុន្តែ វាបានបង្ហាញថា ប្រព័ន្ធច្បាប់ជាតិ មិនមែនថាយើងមិនត្រូវយកមកពិចារណាទាំងស្រុងនោះទេ នៅក្នុងប្រតិបត្តិការរបស់តុលាការនេះ។ ខ្ញុំមានការមិនឯកភាពជាមួយនឹងលោកស្រីសហព្រះរាជអាជ្ញា ជា លាង ដែលលើកឡើងអំពីលក្ខណៈចរិតពិសេសរបស់តុលាការនេះ ដែលគេមានការគិតទុកថា តុលាការនេះជាតុលការមានចរិតពិសេស ហើយត្រូវយកច្បាប់ពិសេសមកអនុវត្ត។ បទប្បញ្ញត្តិដែលបង្កើតតុលាការនេះ បានបង្កើតជាស្ថាប័នមួយពិសេសជាក់លាក់ ហើយដោយមានបទប្បញ្ញត្តិមួយជាក់លាក់ផ្អែកទៅតាមតុលាការនៅក្នុងប្រទេសកម្ពុជា។

[១៣:៥៤:២២]

ដូច្នេះហើយ វាមិនមែនថា ត្រូវចែងនៅក្នុងច្បាប់នៅក្នុងតុលាការនេះតម្រូវឲ្យបង្កើតតុលាការពិសេសនោះឡើយ។ ដូច្នេះហើយ ខ្ញុំគិតថា ខ្ញុំមិនចង់លើកឡើងទឡ្ហីករណ៍ ដែលខ្ញុំបានលើកឡើងរួចហើយនោះទេ ពាក់ព័ន្ធទៅនឹងការអនុវត្តបានចំពោះចន្លោះនៃទោស។

ចំពោះការលើកឡើងមាត្រា៦៨៨ វិញ មាត្រា៦៦៨ ចែងអំពីការខ្វាស់គ្នា ទំនាស់គ្នារវាងច្បាប់ គឺ

ចែងអំពីទំនាស់រវាងច្បាប់ និងបទប្បញ្ញត្តិ។ ដូច្នេះហើយ ខ្ញុំចង់សួរថា តើមានទំនាស់ត្រង់ណារវាងច្បាប់នេះ?

យើងបានឃើញថា ចន្លោះនៃទោសនោះ គឺត្រូវកំណត់ពីប្រាំឆ្នាំរហូតអស់មួយជីវិត ហើយបទប្បញ្ញត្តិមួយទៀតចែងថា ប្រសិនបើទោសជាប់ពន្ធនាគារនោះអាចមានស្ថានសម្រាលនោះត្រូវបន្ថយមកចន្លោះ១៥ ទៅ៣០ឆ្នាំ។ ដូច្នេះ ខ្ញុំគិតថាវាហាក់ដូចជាមិនមានការប៉ះទង្គិចរវាងទោសនេះទេ គ្រាន់តែទោសចែងនៅក្នុងចំណុចទីមួយ វាមានលក្ខណៈជាក់លាក់ ហើយគ្រាន់តែមួយទៀតតម្រូវឲ្យមានការផ្តល់ទៅលើផលប្រយោជន៍។

[១៣:៥៥:៥០]

ការទំនាស់រវាងច្បាប់នោះ នៅក្នុងការអនុវត្តនោះ យើងហាក់ដូចជាមិនមានទេ។ ទំនាស់នោះគឺទាល់តែយើងមិនអាចអនុវត្តច្បាប់ទៅបាន ទើបវាមានទំនាស់។ ប៉ុន្តែ បទប្បញ្ញត្តិទាំងពីរ វាហាក់ដូចជាវាមានចែងស្របគ្នា ដោយសារតែបទប្បញ្ញត្តិមួយវាចែងក្តោបរួមនៅក្នុងបទប្បញ្ញត្តិមួយទៀត។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រី។

**លោកស្រី ជា លាង៖**

ខ្ញុំសូមឆ្លើយនឹងសំណួររបស់ចៅក្រម មីឡាត ដោយខ្លីទេ។ ខ្ញុំសូមជម្រាបអ៊ីចេះ ខ្ញុំអត់បានលើកឡើងអំពីថា ច្បាប់ដែលសភាអនុម័តនោះមិនអាចអនុវត្តបានទេ គឺច្បាប់ជាតិ ចង់និយាយថាច្បាប់ជាតិដែលសភាអនុម័ត មិនអនុវត្តបានទេ។ ប៉ុន្តែ ត្រូវពិចារណាថា មូលហេតុអីដែលក្រមនីតិវិធីព្រហ្មទណ្ឌដែលបានចែងអំពីមាត្រា៦៦៨ នេះដើម្បីអី ដើម្បីការពារទៅច្បាប់មុននោះដែលបានធ្វើ គឺថាច្បាប់សាលាក្តីខ្មែរក្រហម ច្បាប់ពិសេសយើងនេះ យើងបានធ្វើតាំងពីឆ្នាំ២០០៤ ហើយក្រមនីតិវិធីព្រហ្មទណ្ឌយើងនេះធ្វើនៅឆ្នាំ២០០៩ ទេ ដូច្នេះអ្វីដែលគេធ្វើហ្នឹង ធ្វើ៦៦៨ ដើម្បីការពារនូវច្បាប់ពិសេសដែលបានចេញកន្លងមក ដូច្នេះវាតែងតែមាន--

[១៣:៥៧:២០]

**ប្រធានអង្គជំនុំ៖**

លោកស្រីបញ្ជាក់ឲ្យច្បាស់ក្រមព្រហ្មទណ្ឌ ឬក៏ក្រមនីតិវិធីព្រហ្មទណ្ឌ?

**លោកស្រី ជា លាង៖**

អូ! ក្រមព្រហ្មទណ្ឌ (សុំទោស) ក្រមព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ៦៦៨។ អ៊ីចឹងហើយគេមានហៅថា មានឆ្នាំខុសគ្នាទីមួយ ហើយមិនមែនថាច្បាប់ស្អីក៏ដោយ សូម្បីអ្វីដែលចៅក្រមលើកឡើងគឺថាខ្ញុំឯកភាពទាំងស្រុង។ ប្រព័ន្ធស៊ីវិលឡ សភាជាតិបានអនុម័តច្បាប់ គឺយើងយកមកអនុវត្តទាំងអស់ៗ យើងមិនមែនចោលច្បាប់ណាមួយទុកច្បាប់ណាមួយនោះទេ ប៉ុន្តែគ្រាន់គិតថា ធ្វើអ្វីដើម្បីការពារអាមុនកើតមកហើយ ថាអាហ្នឹងអាចកើតឡើង តើយើងយកអ្វីដើម្បីទប់? កុំឲ្យមានការផ្តន្ទាទោសហ្នឹង វាគ្មានកន្លែងកំណត់មួយដែលច្បាស់លាស់។ ហើយខ្ញុំគិតថានៅក្នុងកថាខណ្ឌទីបី ខ្ញុំគិតថាចំពោះខ្ញុំគិតថាវាច្បាស់សម្រាប់ការយកមកអនុវត្តចំពោះច្បាប់នៅ អ៊ី.ស៊ី.ស៊ី.ស៊ី នេះហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីការពារជនជាប់ចោទ ធ្វើសន្និដ្ឋានតប។

**លោក កង ឫទ្ធារី៖**

បាទ, ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធានតុលាការកំពូល និងអង្គជំនុំជម្រះទាំងមូល។

ខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាអំពីមាត្រា៦៦៨ ហើយយើងសូមរំឭកឡើងវិញថាមាត្រា៦៦៨នេះ ដូចជាការរំឭករបស់លោកប្រធានតុលាការកំពូលដែរ គឺមិនមែនក្រមនីតិវិធីទេ គឺជាក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ដើម្បីចៀសវាងកុំឲ្យមានការភ័ន្តច្រឡំ។

[១៣:៥៩:០១]

ខ្ញុំសូមអានបញ្ញត្តិនេះមាត្រានេះតែម្តង មុននឹងការបកស្រាយបាទ។ អ៊ីចឹងហើយបានព្រឹកមិញខ្ញុំបើកសៀវភៅពីរបីដង វាចេះតែច្រឡំពេកទៅ ទៅរកនីតិវិធីអត់ឃើញមាន ហើយតាមការសួររបស់តុលាការកំពូលនោះ ដាក់ថាក្រមព្រហ្មទណ្ឌ។

អន្តរបញ្ញត្តិជំពូកទោល អង្គបញ្ញត្តិមាត្រា៦៦៨ ការអនុវត្តបញ្ញត្តិព្រហ្មទណ្ឌដោយឡែក។ ចំពោះបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសដោយច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកផ្សេងទៀត ដែលកំពុងនៅជាធរមានត្រូវអនុវត្តដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះ។ នៅត្រង់ចំណុចនេះ មានន័យថាច្បាប់ព្រហ្មទណ្ឌនេះចេញមកហើយ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ នេះចេញមក នឹងមិននិរាករណ៍ច្បាប់ព្រហ្មទណ្ឌផ្សេងៗទៀតដោយឡែកណាមួយទេ។ បាទមានន័យថាអ៊ីចឹង នេះជាការបកស្រាយដ៏ត្រឹមត្រូវមួយ។ គឺថាកថាខណ្ឌទីមួយនៃមាត្រា៦៦៨នេះ បាន

ប្រាប់យើងយ៉ាងច្បាស់ថា នឹងមិននិរាករណ៍ច្បាប់ព្រហ្មទណ្ឌដោយឡែកណាមួយផ្សេងទៀតទេ ព្រោះច្បាប់ព្រហ្មទណ្ឌផ្សេងៗទៀតក៏មានដែរ ដូចជាច្បាប់បទល្មើសព្រៃឈើ ឬក៏នៅច្បាប់នៅ អ៊ី.ស៊ី.ស៊ី.ស៊ី យើងនេះ-- ច្បាប់អ.វ.ត.ក យើងនេះ ក៏ច្បាប់ដោយឡែកមួយដែរ ហើយច្បាប់ហ្នឹងអត់បាននិរាករណ៍ច្បាប់ព្រហ្មទណ្ឌផ្សេងទៀតហ្នឹងទេ។ នៅក្នុងករណីដែលមានទំនាស់រវាងច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក និងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវអនុវត្តដោយអនុលោមតាមវិធានដែលមានចែងក្នុងគន្ថីទីមួយបញ្ញត្តិទូទៅ។

[១៤:00:៤0]

នៅក្នុងគន្ថីទីមួយ យើងបានឃើញអំពីមាត្រាជាច្រើន បាទ ដូចជាមាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ ដែលមាត្រា៥ ស្តីអំពីការបកស្រាយច្បាប់ ចែងអំពីការបកស្រាយច្បាប់។ ដូច្នេះ មាត្រា៥ ហ្នឹង ត្រឹមត្រូវណាស់ដែលបង្គាប់មក អ៊ី.ស៊ី.ស៊ី.ស៊ី នេះ គឺ អ.វ.ត.ក នេះ ហាមមិនឱ្យបកស្រាយច្បាប់ចេញក្រៅយុត្តាធិការរបស់ខ្លួន ឬក៏ប្រើប្រាស់ប្រព័ន្ធតាមសទិសភាព ឬករណីយុត្តិសាស្ត្រហ្នឹងតែម្តង។ ដែលព្រឹកមិញលោកខាងសហព្រះរាជអាជ្ញាច្រើនហួសហេតុអំពីករណីយុត្តិសាស្ត្រ ហើយខ្ញុំសូមអំណរគុណ ចំពោះលោកចៅក្រម ម៉ូតូ ណូហ្គូជិ ដែលលោកបានឆ្លើយ វាហាក់ដូចជាឆ្លើយសំណួររបស់គាត់ហ្នឹង ហាក់ដូចជាឆ្លើយ-- សួរជំនួសសហមេធាវីទៅលើចៅក្រម-- លើសហព្រះរាជអាជ្ញាលោកសហព្រះរាជអាជ្ញាអន្តរជាតិ។ គឺថាករណីយុត្តិសាស្ត្រខ្លះវាមិនអាចផ្ទឹមនិងស៊ីគ្នា ហើយមិនត្រូវបានទាន់គេស្វាគមន៍ជាអន្តរជាតិផង គួរតែគប្បីពិចារណាថានៅ យូហ្គោស្លាវី និង រវ៉ាន់ដា សៀរ៉ាឡេអូនសាលាជម្រះក្តីហ្នឹងមិនទាន់បិទនៅឡើយទេ វាមានសកម្មភាពដូចនៅ អ.វ.ត.ក យើងដែរ។ តើគេអាចយកសេចក្តីសម្រេចចិត្តរបស់សាលាជម្រះក្តី អ.វ.ត.ក សាលាដំបូងធ្វើជាករណីយុត្តិសាស្ត្រនៅ អាចថានៅ លីប៊ី នៅថ្ងៃអនាគតបានទេ? បើសិនជា លីប៊ី ដូចជាការទម្លាក់គ្រាប់បែកលើជនស៊ីវិល។ល។ អ៊ីចឹងឬក៏យកត្រឡប់ទៅវិញ ទៅប្រើប្រាស់នៅ យូហ្គោស្លាវី បានទេ?

[១៤:0២:២៤]

ដូច្នេះ វាមិនអាចចេះតែយកបានតាមតែអំពើចិត្តទេ គឺគេត្រូវតែប្រើប្រាស់ច្បាប់ដែលមានសំណេរតាមប្រព័ន្ធស៊ីវិលឡូ ដែលកម្ពុជារដ្ឋអធិបតេយ្យមួយ ហើយជារដ្ឋដែលទទួលយកនូវប្រព័ន្ធច្បាប់ស៊ីវិលឡូនេះមកប្រើប្រាស់។

ក្នុងគន្លឹទីមួយនោះ ក៏មានមាត្រា៩ផងដែរ ដែលការអនុវត្តច្បាប់លុបចោលបទល្មើស។ បានន័យថា បទល្មើសខ្លះត្រូវបានលុបចោលដោយក្រមព្រហ្មទណ្ឌ២០០៩ ត្រូវតែលុបចោល ក្នុងតាមមាត្រា៩ និងមាត្រា១០ អនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាល ឬធ្ងន់ជាង ដែលត្រង់នេះឯង ដែលសហមេធាវីបានទាញការចាប់អារម្មណ៍ចំពោះអង្គជំនុំជម្រះថា មាត្រា១០ បានផ្ដល់អត្ថប្រយោជន៍យ៉ាងច្រើនដល់លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ចំពោះស្ថានសម្រាលរបស់គាត់ ក្នុងពេលដែលវត្តមាននៃច្បាប់ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានលេចខ្លួនឡើងមក បានមានសុពភាព។

[១៤:០៣:២២]

មាត្រា៣១ នៃកិច្ចព្រមព្រៀងរវាង យូ.អិន និងរដ្ឋាភិបាលកម្ពុជា ចាត់ទុកដូចជាច្បាប់កម្ពុជា។ បើយើងយោងតាមមាត្រា៣១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើត អ.វ.ត.ក នេះ គឺចាត់ទុកថាច្បាប់នៃកិច្ចព្រមព្រៀងដូចជាច្បាប់កម្ពុជា។ ហេតុដូច្នេះ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ អត់មានមាត្រាណាមួយមកជំទាស់ ឬខ្ទាស់ ឬធ្វើនិរាករណ៍ជាមួយនឹងមាត្រា-- ជាមួយនឹងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ទេ។

[១៤:០៣:៥៤]

ផ្ទុយទៅវិញ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានបញ្ចូលនូវមាត្រាខ្លះនៃច្បាប់ អ.វ.ត.ក ដូចជា មាត្រា៣ មាត្រា៤ មាត្រា៥ និងមាត្រា៦ ស្ដីអំពីបទឧក្រិដ្ឋដែលបំពារបំពានធ្ងន់យ៉ាងធ្ងន់ធ្ងរទៅលើសន្ធិសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាដើម។ ហើយស្ថានទម្ងន់ទោសដែលកំណត់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក៏ប្រហែលជានឹងធ្ងន់ជាងផង បើធៀបទៅ ឬក៏ស្មើគ្នា ធៀបទៅនឹងច្បាប់ អ.វ.ត.ក។ ហេតុនេះ ច្បាប់អ.វ.ត.ក និងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ គឺមិនខុសគ្នាទេ ដោយយោងតាមកិច្ចព្រមព្រៀងរបស់រវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិក្នុងការបង្កើត អ.វ.ត.ក នេះឡើង។ មាត្រាទី១២ ស្ដីអំពីនីតិវិធី និងមាត្រា៣១ គឺថាយើង-- ដោយជឿជាក់ដោយអត់សង្ស័យថា ច្បាប់ព្រហ្មទណ្ឌឆ្នាំ២០០៩ គ្របដណ្ដប់លើ អ៊ី.ស៊ី.ស៊ី.ស៊ី នេះ ឬ អ.វ.ត.ក។

ដូច្នេះ វាគ្មានអ្វីមកជំនាស់ទៅនឹងគន្លឹទីមួយ តាមការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអំពីមាត្រា ៦៦៨ ទេ។

[១៤:០៥:០២៧]

អង្គជំនុំជម្រះគួរគម្បីពិចារណាផងដែរ ទៅនឹងមាត្រា១០ មាត្រា៩៣ មាត្រា៩៤, ៩៥ មាត្រា១៣៧ ដែលត្រូវលើកយកមកពិចារណាជាមូលដ្ឋានច្បាប់កម្ពុជាសម្រាប់បង្គ្រប់ឲ្យចន្លោះប្រហោងរបស់ច្បាប់ អ.វ.ត.ក ស្របតាមមាត្រា១២ មាត្រា១៣ នៃកិច្ចព្រមព្រៀងរវាង យូ.អិន និងរដ្ឋាភិបាលកម្ពុជា ដែលទាញចេញពីមាត្រា១៣ នៃសន្ធិសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៤៩ ស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកំណត់ថាជនគ្រប់មានសិទ្ធិទទួលបាននូវការកាត់ក្តីបានត្រឹមត្រូវដោយឥតរើសអើង ដោយឥតលម្អៀង។

បានន័យថា បើច្បាប់ក្រោយនេះចេញមកហើយ មានផលប្រយោជន៍ដល់គាត់ វាគ្មានច្បាប់ណាមួយមករារាំងមិនឲ្យគាត់ទទួលផលប្រយោជន៍បានអំពីច្បាប់ថ្មីនោះទេ។ ហេតុនេះ ការលើកយកទម្លាក្ករណ៍ពីសាលាជម្រះក្តីផ្សេងៗ ថាត្រូវតែដាក់គុកគាត់អស់មួយជីវិត ដូចជានៅ យូហ្គោស្លាវី ឬសៀវ៉ាឡេអូនឬក៏ រវ៉ាន់ដា ជារឿងអត់សមហេតុផលទាល់តែសោះ។

[១៤:០៦:២០]

ខ្ញុំសូមបញ្ចប់ការឆ្លើយតបចំពោះមាត្រា៦៦៨ ហើយធ្វើសេចក្តីសន្និដ្ឋានតបចំពោះ-- អំពីការកំណត់ទោស។ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាស្ថានសម្រាលដ៏សំខាន់ គឺពិតជាត្រឹមត្រូវ ពីព្រោះថា តបតាមចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីសហព្រះរាជអាជ្ញាបាននិយាយហើយថា សាលាដំបូង អ.វ.ត.ក ផ្តល់ស្ថានសម្រាលហួសហេតុពេកទៅលើជនជាប់ចោទ។

[១៤:០៧:០២]

ហេតុនេះ ខ្ញុំបានទាញចេញថា បើសិនជាសាលាដំបូងយល់ឃើញថា ជនជាប់ចោទត្រូវទទួលបានស្ថានសម្រាលនោះ គឺដោយសារមានមូលហេតុសំអាងដូចតទៅនេះ៖

ទីមួយ ជនជាប់ចោទបានចេញមុខប្រឆាំងនឹងពាក្យសម្តីភូតកុហករបស់ ប៉ុល ពត និងថ្លែងប្រាប់ទៅអ្នកកាសែត នេត ថាយ័រ ថា ស-២១ គឺជារឿងប្រឌិតរបស់ស្ត្រីចាស់វៀតណាម ឯ ឌុច ធ្វើសក្ខីកម្មនិយាយថា ស-២១ ពិតជាមានអត្ថិភាពក្រោមរបបកម្ពុជាប្រជាធិបតេយ្យប្រាកដមែន ហើយ ប៉ុល ពត សុន សេន និង នួន ជា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត។

២) ជនជាប់ចោទសហការយ៉ាងល្អដល់សាលាជម្រះក្តី សាលាដំបូង អ.វ.ត.ក និងសម្តែងវិប្បដិសារីចំពោះឧក្រិដ្ឋកម្មកើតឡើងនៅ ស-២១។

៣) ជនជាប់ចោទបំពេញការងារស្ថិតនៅក្រោមការបង្ខិតបង្ខំពី សុន សេន ពីអចិន្ត្រៃយ៍ និងពី តាម៉ុក។

៤) ជនជាប់ចោទប្រព្រឹត្តនៅ ស-២១ ស្ថិតនៅក្រៅឆន្ទៈរបស់ខ្លួន និងអស់សង្ឃឹម។

៥) អ្នកចិត្តសាស្ត្រវាយតម្លៃថា ឌុច អាចធ្វើសមាហរណ៍កម្មចូលក្នុងសង្គមវិញ។

៦) ជនជាប់ចោទធ្វើសកម្មភាពដោយអត់ជម្រើស ក្នុងលក្ខខណ្ឌដែលខ្លួនក៏អាចក្លាយខ្លួនជាអ្នកទោសប្រហារជីវិតទាំងគ្រួសារ នៅស-២១ ដូចជា ណាត និងកម្មាភិបាលខ្មែរក្រហមដទៃទៀត ដូចជា វន វ៉េត និង កុយ ធួន។

៧) ប្រវត្តិកាលនៃជនជាប់ចោទជាមនុស្សល្អ និងមានការអប់រំល្អ។

៨) ជនជាប់ចោទព្យាយាមរារាំងបទល្មើសរំលោភនារីនៅស-២១ មានមួយករណីដោយរាយដោយការណ៍ទៅ សុន សេន ដែលជាអ្នកធ្វើការសម្រេចចិត្ត តែបរាជ័យ ហើយខ្លួនសម្រេចចិត្តប្តូរអ្នកទោសស្រីឲ្យអ្នកសួរចម្លើយស្រីសួរវិញ។

[១៤:០៨:៤៦]

នេះជាការព្យាយាមបញ្ចៀសឲ្យបានជាអតិប្បរមានទៅតាមដែលអាចធ្វើបាននូវអ្វីដែលគាត់ចង់បញ្ឈប់ឧក្រិដ្ឋកម្មដែលកើតនៅ ស-២១។

៩) ជនជាប់ចោទព្យាយាមដោះលែងអ្នកទោសនៅស-២១ តែបរាជ័យ ហើយក៏ធ្លាប់ជោគជ័យក្នុងការដោះលែងអ្នកទោសនៅស-២១ ដែរ គឺក្រុមជនជាតិភាគតិចវៀតណាម ហ្សូលរ៉ូ ដោយមានការអនុញ្ញាតពី ប៉ុល ពត តាមរយៈ ប៉ង់ ហៅ ឈឹម សំអោក។

១០) ជនជាប់ចោទមានចេតនាជួយជ្រោមជ្រែង អ.វ.ត.ក ដោយស្មោះស្ម័គ្រ និងកិរិយាល្អ ដល់គ្រប់សម្បទានទាំងអស់ជាមួយភាគីបណ្តឹងរដ្ឋបណ្តឹងប្បវេណី ភាគដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាចៅក្រម និងសហគមន៍កម្ពុជា។

១១) សកម្មភាពឧក្រិដ្ឋកម្មកើតនៅស-២១ គឺកើតឡើងដោសារបញ្ជាថ្នាក់លើរបស់គាត់ គឺ សុន សេន, នួន ជា, ប៉ុល ពត និងក្រុមអចិន្ត្រៃយ៍។ ហើយជនជាប់ចោទក៏ព្យាយាមសុំចេញពីស-២១ ទៅកាន់ការងារឧស្សាហកម្មដែលជាផ្នែកស៊ីវិល មិនពាក់ព័ន្ធផ្នែកសន្តិសុខ និងបទឧក្រិដ្ឋកម្មដែលខ្លួនស្អប់ខ្ពើម តែត្រូវបានថ្នាក់លើគាបសង្កត់ឲ្យអនុវត្ត។

[១៤:០៩:៤០]

១២) ជនជាប់ចោទជាថ្នាក់ទាបបំផុតនៃសាខាបក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជារចនាសម្ព័ន្ធរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។

១៣) ជនជាប់ចោទធ្លាប់រងការរិះគន់ ពីបំណងបញ្ឈប់សកម្មភាពសួរចម្លើយនៅគុក ស-២១ តាមសេចក្តីប្រកាសជាទូទៅរបស់ ប៉ុល ពត តែ នួន ជា ប្រឆាំងនិងគំរាមកំហែងឲ្យបន្ត។ ជាលទ្ធផល អស់សង្ឃឹម និងបោះបង់ការងារចោល ដោយដេករងចាំថ្ងៃស្លាប់។

[១៤:១០:១៦]

១៤) ជនជាប់ចោទត្រូវបានបោះបង់ចោល ដោយរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលកងទ័ពវៀតណាមវាយលុកចូលមកដល់ទីក្រុងភ្នំពេញ និងបន្តការស្តីបន្ទោសជាបន្តទៀតនៅពេលដែលភៀសខ្លួនដល់សំឡូត។ នេះជាការបង្ហាញឲ្យឃើញថា ឋានៈ និងតួនាទីរបស់គាត់ ឬការងាររបស់គាត់ប្រព្រឹត្តទៅដោយក្រៅឆន្ទៈរបស់គាត់ និងដោយការព្រងើយកន្តើយពីថ្នាក់លើ និងមិនផ្តល់តម្លៃដល់គាត់ទេ។ ប៉ុន្តែវាជាជម្រើសរវាងកាតព្វកិច្ច ហើយនិងជីវិត វាគ្មានទាល់តែសោះនូវការជម្រើសមួយឲ្យ ឌុច នៅក្នុងពេលដែលគាត់កំពុងតែអនុវត្តបទឧក្រិដ្ឋដែលកើតនៅគុកទួលស្លែង។ បើពុំនោះទេ ប្រសិនបើសិនជាយើងជាចៅក្រម ឬក៏ជាព្រះរាជអាជ្ញា ជាមេធាវី ជាអស់លោកទាំងអស់ដែលមានវត្តមាននៅថ្ងៃនេះ ជាឌុច នៅក្នុងសភាពការណ៍ឆ្នាំ១៩៧៥ ហើយដែលត្រូវ សុន សេន បញ្ជាឲ្យធ្វើតើយើងនឹងសម្រេចចិត្តយ៉ាងដូចម្តេច? ទំនងជាប្រហែលជាដូចៗតែគេហ្នឹង។ វាមិនលើសពីនេះទេ ជាពិសេស ឌុច គឺជាប្រធានកងវរសេនាធំ ដែលជាផ្នែកមួយនៃកងទ័ព ត្រូវតែស្តាប់បទបញ្ជាមេបញ្ជាការជាន់ខ្ពស់របស់ខ្លួន ហើយបទបញ្ជា និងអង្គការវិន័យរបស់របបកម្ពុជាប្រជាធិបតេយ្យ ដែលចេញពីបក្សកុម្មុយនីស្តកម្ពុជា គឺជាវិន័យដែលមិនអាចបំពានបាន។ ការបំពានវិន័យរបស់របបកម្ពុជាប្រជាធិបតេយ្យមានទោសស្មើនឹងស្លាប់ខ្លួនឯងព្រមទាំងគ្រួសារ ដូចជាកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមផ្សេងៗទៀតដទៃទៀតដែរ។

[១៤:១១:៤១]

ហេតុនេះ សរុបសេចក្តីទៅ ជនជាប់ចោទប្រព្រឹត្តសកម្មភាពនៅស-២១ ក្រោមការបង្ខិតបង្ខំខ្លាំងហួសហេតុ គ្មានជម្រើសរវាងសីលធម៌ និងកាតព្វកិច្ច និងថាការងារត្រូវបានកំហិតជាចារី ក្នុងការទទួលបញ្ជាពីថ្នាក់លើមកផ្សព្វផ្សាយដល់ថ្នាក់ក្រោម និងធ្វើរបាយការណ៍សំយោគលើចម្លើយសារភាព ដល់ថ្នាក់លើវិញតែប៉ុណ្ណោះ។

ជនជាប់ចោទមិនបានសម្តែងសកម្មភាពឧក្រិដ្ឋ កាចសាហាវ យង់ឃ្នងដោយផ្ទាល់ដល់ជនរងគ្រោះនោះទេ ហើយក៏មិនមែនជាអ្នកដាក់បញ្ជាឲ្យសម្លាប់មនុស្សតាមសេចក្តីសម្រេចចិត្តរបស់ខ្លួននោះទេ។ រាល់បញ្ជាសម្លាប់មនុស្ស និងធ្វើទារុណកម្មនៅគុកទួលស្លែង គឺជាសិទ្ធិប្រទានរបស់ សុន សេន និង នួន ជា តែប៉ុណ្ណោះ។ ជនរងគ្រោះក៏ធ្លាប់ទទួលការគំរាមកំហែងពី តាម៉ុក ជាឃាតកល្បីឈ្មោះថា មិនចេះប្រើ ឌុច ព្រោះ ឌុច តែងតែតវ៉ាសុំឲ្យដោះលែងអ្នកទោសនៅ ម-១៣ អមលាំង។

[១៤:១២:៣៧]

ហេតុនេះ យើងអាចធ្វើសេចក្តីសន្និដ្ឋានខ្លីថា ជនជាប់ចោទរងការគាបសង្កត់ឲ្យប្រព្រឹត្តសកម្មភាពនេះខ្លាំងហួសហេតុពេក គឺគំរាមកំហែងដល់អាយុជីវិតខ្លួននិងក្រុមគ្រួសារ។ ជនជាប់ចោទប្រព្រឹត្តសកម្មភាពក្រៅឆន្ទៈរបស់ខ្លួនឯងសុទ្ធសាធ ដោយគ្មានជម្រើស។ ជនជាប់ចោទសម្តែងនូវវិប្បដិសារី និងមានអាកប្បកិរិយាកែប្រែអាចធ្វើសមាហរណកម្មចូលក្នុងសង្គមវិញបាន។

ជនជាប់ចោទមិនដែលទទួលអត្ថប្រយោជន៍ពីសកម្មភាពរបស់ខ្លួន រួមទាំងបុណ្យស័ក្តិនិងលាភការក្រៅពីការគំរាមកំហែងគ្រោះថ្នាក់ដល់ជីវិតនិងគ្រួសារឡើយ។ ជនជាប់ចោទផ្តល់សក្ខីកម្មបំភ្លឺដល់ភស្តុតាងនានាដោយស្មោះត្រង់ ផ្ចិតផ្ចង់ ជួយដល់អង្គជំនុំជម្រះ និងប្រវត្តិសាស្ត្រពិតនៃរបបកម្ពុជាប្រជាធិបតេយ្យ ធ្វើឲ្យសង្គមជាតិ និងអន្តរជាតិលែងភ័ន្តច្រឡំ និងជួយទប់ស្កាត់កុំឲ្យមានការកាត់ក្តីច្រឡំ និងរារាំងកុំឲ្យរបបព្រៃផ្សៃនេះកើតសាជាថ្មីឡើងវិញបាន។

[១៤:១៣:៣៧]

ទោះបីជាទទួលស្ថានសម្រាលយ៉ាងនេះក្តី ក៏អង្គជំនុំជម្រះសាលាដំបូងនៅតែកាត់ក្តីប្រឆាំងនឹងជនជាប់ចោទដ៏អយុត្តិធម៌ ប្រឆាំងនឹងមាត្រា៩៥ នៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ដែលកំណត់ថា កាលបើជនជាប់ចោទត្រូវទទួលទោស គុកអស់មួយជីវិត ហើយទទួលស្ថានសម្រាលទោសនោះ ទោសត្រូវកំណត់ពី១៥ឆ្នាំទៅ៣០ឆ្នាំ។ តែអង្គជំនុំជម្រះសាលាដំបូងបានដាក់ទោស ឌុច ដល់ទៅ៣៥ឆ្នាំ ថាលើសកាលកំណត់ដល់ទៅ៥ឆ្នាំ។ តាមពិតទៅទោសនេះ កំណត់ត្រឹមអប្បបរមានៃស្ថានសម្រាលទោសដែលផ្តល់ដោយអង្គជំនុំជម្រះ ស្របតាមមាត្រា៩៥ នៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ត្រឹមតែ១៥ឆ្នាំ គឺគ្រប់គ្រាន់ណាស់ទៅហើយ។ ហើយវាផ្តល់យុត្តិធម៌ដល់ជនជាប់ចោទ ដែលជាជនរងគ្រោះទ្វេពីការគំរាមកំហែងបង្ខិតបង្ខំនៃបក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ និងថែមទាំងការផ្តន្ទាទោសលើសចំនួនកំណត់តាមមាត្រា៥ នៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ស្តីពីស្ថានសម្រាលដល់ទៅ៥ឆ្នាំ ថែមទៀត។

[១៤:១៤:៤០]

ការផ្តន្ទាទោសបែបនេះ នឹងបង្កការស្អប់និងការភ័យខ្លាចពីជនជាប់ចោទដទៃទៀត លែងអាចសហការជាមួយអង្គជំនុំជម្រះជាបន្តទៅទៀតបាន។ ការកាត់ក្តីបែបនេះ ក៏ប្រឆាំងនឹងគោលការណ៍ជាសាកល ស្តីពីការទទួលបាននូវការកាត់ក្តីត្រឹមត្រូវសម្រាប់ជនគ្រប់រូប ហើយអាចបង្ហាញដល់សហគមន៍ជាតិ និងអន្តរជាតិថា ការកាត់ក្តីនេះ គឺជាវេទិកានៃការសងសឹកគ្នា ឬជាយុត្តិធម៌របស់អ្នកឈ្នះផ្តល់ដល់អ្នកចាញ់។

[១៤:១៥:១៤]

ករណីទទួលបានស្ថានសម្រាលកំណត់ទោសលើសពី-- កំណត់ទោសពី ១៥ ទៅ ៣០ឆ្នាំ អង្គជំនុំជម្រះទទួលនូវការគាបសង្កត់ពីសម្ពាធបរិយាកាសសង្គម និងសហព្រះរាជអាជ្ញាបានផ្តន្ទាទោសលើសកំណត់ស្ថានសម្រាលដល់ទៅ៥ឆ្នាំ នេះគឺជាការកាត់ក្តីតាមទំនើងចិត្ត។

សហព្រះរាជអាជ្ញានិងប្រព័ន្ធផ្សព្វផ្សាយ បានធ្វើការគាបសង្កត់តាមរយៈការបង្ហាញរូបភាពកាចសាហាវ ដល់អង្គជំនុំជម្រះដែលជះឥទ្ធិពលមិនល្អដល់ទឹកចិត្តរបស់ចៅក្រម។

[១៤:១៥:៥១]

ការណ៍ដែលសហព្រះរាជអាជ្ញាលើកឡើងពីការខកខានផ្តន្ទាទោសច្រើនមុខ គឺពឹងផ្អែកលើយុត្តាធិការបទល្មើសថ្នាក់ជាតិធម្មតា និងមិនពឹងផ្អែកលើយុត្តាធិការបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្របតាមមាត្រា១៨៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាទេ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានឃាតកម្ម ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ឬការជម្លៀសដោយបង្ខំ ការដាក់ពន្ធនាគារ ឬគ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសិទ្ធិសេរីភាពដោយបំពានទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិតអន្តរជាតិ។ ការធ្វើទារុណកម្ម ការចាប់បង្ខំសេពសន្ថវៈ ការធ្វើទាសកម្មខាងផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយបង្ខំ វណ្ណៀកម្មដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហិង្សាខាងផ្លូវភេទដែលមានទម្ងន់ប្រហាក់ប្រហែលគ្នា។

[១៤:១៦:៣៧]

ការធ្វើទុក្ខបុកម្នេញលើក្រុម ឬសហមូហភាពដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិជាតិពន្ធ វប្បធម៌ សាសនា ឬភេទ។ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ជាប្រព័ន្ធតាមបែបអាប៉ាថេត គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កឲ្យមានការឈឺចាប់យ៉ាងខ្លាំង

ឬរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ។

[១៤:១៧:០៥]

តាមមាត្រា១៨៨នេះបានន័យថា ទោះបីជាយ៉ាងណាក៏ដោយ ទោសទាំងអស់ដែលបានរៀបរាប់ត្រូវបានផ្តន្ទាទោសជាប្រភេទទោសស្រួបយក គឺកំណត់ត្រឹមតែ-- បើសិនជាប្រព្រឹត្តចំឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ គឺទោសដល់ទៅមួយជីវិត នេះបើតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ ប៉ុន្តែ នៅក្នុងក្រម-- នៅក្នុងច្បាប់ អ.វ.ត.ក ត្រូវជាប់ពន្ធនាគារពី៥ឆ្នាំ ដល់អស់មួយជីវិត។ ហេតុនេះតុលាការត្រូវថ្លឹងថ្លែងពិចារណាអំពីស្ថានសម្រាល ដែលច្បាប់ថ្មីគួរបានផ្តល់ ហើយដែលគួរនឹងផ្តល់ដល់ជនជាប់ចោទ ដែលមានលក្ខខណ្ឌដូចបានរៀបរាប់ខាងលើ។

[១៤:១៧:៥០]

មិនមែនមានន័យថា ទោសនីមួយៗនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះត្រូវគេយកមកលម្អិតក្នុងយុត្តាធិការច្បាប់ជាតិ ហើយធ្វើជាទោសបូកដើម្បីបង្ហាញឲ្យទោសនេះកាន់តែធំឡើងទេ ពីព្រោះវាអស់ហើយត្រឹមទោសមួយជីវិត។ ហេតុដូច្នេះ ការដាក់ទោសបើសិនជាបានស្ថានសម្រាល ត្រូវតែគោរពតាមវិធាននៃស្ថានសម្រាល ដោយមិនត្រូវលើសពី៣០ឆ្នាំទេ យ៉ាងច្រើនបំផុត៣០ឆ្នាំ គឺកំណត់ទោសពី ១៥ ទៅ ៣០ឆ្នាំ។ ការទទួលស្ថានសម្រាលហើយ បែរជាផ្តន្ទាទោសលើស៥ឆ្នាំវិញ នេះហើយជាការរំលោភបទដ្ឋាន។ បាទ, សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោក ការ សាវុត្ថ មានអ្វីបន្ថែម ឬក៏អត់ទេ?

**លោក ការ សាវុត្ថ៖**

សូមគោរពតុលាការ។ ខ្ញុំអត់មានអីបន្ថែមទៀតទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អ៊ីចឹងសូមលោកចៅក្រមមានសំណួរ សូមអញ្ជើញសួរដល់មេធាវីការពារក្តី។

**ចៅក្រម ម៉ូតូ ណូហ្គូជិ៖**

ខ្ញុំមានសំណួរសួរទៅមេធាវីការពារក្តី ទាក់ទងទៅនឹងមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ តាមរយៈសារណាផ្ទាល់មាត់របស់លោកដែលទើបលើកឡើងអម្បាញ់មិញនេះ គឺលោកបានស្នើសុំថា ស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលថា ត្រូវតែផ្តន្ទាទោសជនជាប់ចោទ ចន្លោះពី១៥ឆ្នាំ ទៅ៣០ឆ្នាំ

ដោយសំអាងទៅលើបទប្បញ្ញត្តិនៃមាត្រានេះឯង។ បទប្បញ្ញត្តិនេះហាក់ចង់ចែងថា ប្រសិនណាបើកាលណាបទល្មើសត្រូវបានផ្តន្ទាទោសអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារក្នុងចន្លោះរវាង ១៥ឆ្នាំ និង ៣០ឆ្នាំ។

[១៤:២០:២២]

តាមធម្មតាពាក្យថា “អាច” ត្រូវបានបកស្រាយថា ជាការផ្តល់ឆន្ទានុសិទ្ធិ ថាតើអាចសំអាងទៅលើមូលដ្ឋាននេះ ឬក៏យ៉ាងណានោះ? ប្រសិនបើដូច្នេះមែន មាត្រា៩៥ នៃក្រមព្រហ្មទណ្ឌនេះ ហាក់ដូចជាផ្តល់លទ្ធភាពឲ្យអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តីនេះ ថាតើត្រូវប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីពិចារណាទៅស្ថានសម្រាលទោសទាំងឡាយ ឬក៏យ៉ាងណានោះ និងការដាក់ពន្ធនាគារចន្លោះពី ១៥ឆ្នាំទៅ ៣០ឆ្នាំ ឬក៏យ៉ាងណានោះ? ថាតើលោកមេធាវីការពារក្តីកំណត់ទម្ងន់ពាក្យពេចន៍នេះដូចម្តេចដែរ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី។

**លោក កង ឫទ្ធារី៖**

បាទ, សូមអរគុណ ចំពោះសំណួររបស់លោកចៅក្រម ណូហ្គជិ។

គឺថា អ្វីដែលខ្ញុំបានលើកឡើង វាគួបផ្សំដោយមាត្រា៩៣ ៩៤ និង ៩៥ ជាមាត្រាចុងក្រោយ។ ដូច្នេះ បើសិនជាតាមការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានោះ គាត់សន្និដ្ឋានមានពីរផ្លូវ។ ទីមួយ ដំបូងឡើយគាត់សន្និដ្ឋានថា-- អ៊ូ! គាត់ប្តឹងសុំឲ្យដាក់គុកអស់មួយជីវិត។ បើដាក់គុកអស់មួយជីវិត ខ្ញុំបានសន្និដ្ឋានថា សាលាដំបូងបានផ្តល់ស្ថានសម្រាលរួចទៅហើយ តាមការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា។ បើសិនជាផ្តល់ស្ថានសម្រាល តាមមាត្រា-- យើងមានតែពិនិត្យមើលមាត្រា៩៣, ៩៤ និង៩៥ ហើយបើសិនជាគេនិយាយថា ផ្តល់ស្ថានសម្រាល បានន័យថា ដាក់គុកអស់មួយជីវិត ស្ថានសម្រាលគឺវានៅចន្លោះពី១៥ ទៅ ៣០ឆ្នាំ គឺអាចនៅចន្លោះហ្នឹងឯង។

[១៤:២២:១៧]

វាពិតណាស់ ដូចតែសំណួររបស់លោកចៅក្រម ណូហ្គជិ ដែរបាទ។ គឺថាជាឆន្ទានុសិទ្ធិរបស់លោកចៅក្រម។ ប៉ុន្តែ ខ្ញុំបានបង្ហាញទឡ្ហីករណ៍ពីអ្វីគ្រប់យ៉ាង ដែលជាមូលដ្ឋាននៃការពិចារណាសម្រាប់ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលក្នុងការកំណត់ទោសដែលថា គួរតែកំណត់អប្បបរមាត្រឹម១៥ឆ្នាំបានហើយ។ ពីព្រោះថា មូលហេតុដែលលើកឡើងនោះ វាសមល្មមនឹងឲ្យគាត់ទទួលបានទោសត្រឹម

អប្បបរមាបានហើយ។ បាទ, តែប៉ុណ្ណឹងឯង។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកស្រីចៅក្រម មីឡាត។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ខ្ញុំមិនចង់រំឭកឡើងវិញ ដែលថាអង្គជំនុំជម្រះតុលាការកំពូល អ្វីដែលតុលាការកំពូលបានលើកឡើងរួចមកហើយ ទាក់ទងទៅនឹងស្ថានសម្រាលទោសដែលត្រូវបានទទួលយកនោះ ពាក់ព័ន្ធទៅនឹងការផ្តន្ទាទោស។ ប៉ុន្តែយើងបានដឹងថា សាលាដំបូងបានរកឃើញថាមានស្ថានសម្រាលទោសនេះ។ នេះខ្ញុំគ្រាន់តែឆ្លើយទៅមេធាវីការពារក្តី។ ក៏ប៉ុន្តែខ្ញុំឆ្ងល់ថា ទាំងភាគីក្តីគឺថា មិនបានលើកឡើងថាតើយើងអាចប្រើប្រាស់នូវវេទិកាណាមួយទាក់ទងទៅនឹងការផ្តន្ទាទោសដាច់ដោយឡែក ទៅលើបទល្មើសដែលបានកំណត់ឡើងពាក់ព័ន្ធទៅនឹងបទល្មើសនៃការធ្វើទុក្ខបុកម្នេញ។

[១៤:២៤:១៦]

ខ្ញុំដឹងថា មេធាវីការពារក្តីមិនបានជំទាស់តវ៉ាទៅលើចំណុចនេះទេ ក៏ប៉ុន្តែសំណួរគឺត្រូវតែសម្រេចថាតើប្រសិនណាបើយើងសម្រេចទៅតាមសំណើសុំរបស់សហព្រះរាជអាជ្ញា ដើម្បីផ្តល់ធ្វើការផ្តន្ទាទោសជាក់លាក់ណាមួយ។ ដូច្នេះ ថាតើការផ្តន្ទាទោស យើងដើម្បីកំណត់ថាតើការផ្តន្ទាទោសត្រូវគណនាជាតួលេខដោយរបៀបណានេះ? ប្រហែលជាអ្នកចូលរួមក៏ប្រហែលជាអាចមានការឆ្លើយតបទៅនឹងចំណុចនេះ។

**លោក កង ឫទ្ធារី៖**

សូមអរគុណ។ សូមឆ្លើយតបសំណួររបស់ចៅក្រម។ ខ្ញុំមិនឆ្លើយវែងទេ ពីព្រោះថា វាមិនមែនជាគោលជំហររបស់សហមេធាវីទេ ដែលតាមកូនក្តីរបស់ខ្ញុំគឺគាត់មិនចង់ឆ្លើយតបទៅនឹងការដេញដោលអំពីទោសទាល់តែសោះ ពីព្រោះថាអ្វីដែលគាត់បានសារភាព គាត់បានសារភាពរួចអស់ទៅហើយ។ ប៉ុន្តែ វាជាជម្រើសមួយដែលថា យើងគួរឆ្លើយវាល្អជាងមិនឆ្លើយតប។ ខ្ញុំក៏អរគុណចំពោះចៅក្រមដែលបានផ្តល់ឱកាសឲ្យខ្ញុំឆ្លើយតប។

[១៤:២៥:២៣]

បាទ, ថាវាជាឆន្ទានុសិទ្ធិរបស់ចៅក្រមជាការពិតមែនក្នុងការជ្រើសរើស យកចំណុចណាមួយនៃការគណនាទោសដែលស្ថិតនៅចម្លោះពី១៥ឆ្នាំ ទៅ៣៥ឆ្នាំ ពីព្រោះថាវាទទួលបាននូវស្ថានសម្រាល។

នៅក្នុងច្បាប់ អ.វ.ត.ក អត់មាននិយាយពីស្ថានសម្រាលទោសទេ ថាតើវាស្ថិតនៅក្នុងចម្លោះពីប៉ុន្មានឆ្នាំដល់ប៉ុន្មានឆ្នាំ? ក៏ប៉ុន្តែ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ មាត្រា៩៥ បាននិយាយច្បាស់អំពីមាត្រា៩៣, ៩៤ និង៩៥ បាននិយាយយ៉ាងច្បាស់អំពីស្ថានសម្រាលទោស។

[១៤:២៥:៥៧]

បើទោះបីជាក្នុងការកំណត់ទោសដោយតុលាការសាលាដំបូងដាក់ទោស៣៥ឆ្នាំ ប្រសិនបើទទួលបានស្ថានសម្រាលនៅចម្លោះទោសពី១០ ទៅ៣៥ឆ្នាំបែបនេះ ស្ថានសម្រាលទោសដែលបានទទួលរួចហើយត្រូវផ្តន្ទាទោសអំឡុងប្រហែលជាពីរឆ្នាំតែប៉ុណ្ណោះ។ ហេតុនេះហើយខ្ញុំមិនដឹងថា តើការកាត់ក្តីរបស់សាលាដំបូងដាក់ទោស ៣៥ឆ្នាំនេះ គិតស្ថានសម្រាលហើយឬនៅទេ? បើសិនជាថាទទួលបានស្ថានសម្រាលគឺគេពឹងផ្អែកលើមាត្រាទីប៉ុន្មានដែលយកការកំណត់ទោស៣៥ឆ្នាំ ដោយពឹងផ្អែកលើមាត្រាទីប៉ុន្មាន? បើពឹងផ្អែកតាមមាត្រាទី៩៥ គឺថាដាក់ទោសនេះធ្ងន់ធ្ងរលើសស្ថានសម្រាលដែលគេផ្តល់ឲ្យហើយ គឺលើសដល់ទៅប្រាំឆ្នាំឯណោះ។ ពីព្រោះមាត្រា៩៥ និយាយថាការផ្តល់ស្ថានសម្រាល បើសិនជាជាប់គុកអស់មួយជីវិតត្រូវបានទទួលស្ថានសម្រាល គឺទោសតែពី១៥ ទៅ៣០ឆ្នាំទេ។

ដូច្នេះខ្ញុំបានសន្និដ្ឋានថា ប្រសិនជាចៅក្រមមានឆន្ទានុសិទ្ធិក្នុងការកំណត់ទោសអតិបរមានៃស្ថានសម្រាលគួរគប្បីតែត្រឹម៣០ឆ្នាំ។ តែប្រសិនបើយល់ឃើញថា គាត់ប្រព្រឹត្តអំពើល្អនោះ-- ប្រសិនបើជាចៅក្រមជឿជាក់តាមការពោលអះអាង និងការផ្តល់សក្ខីកម្មដោយជនជាប់ចោទព្រមទាំងមេធាវីការពារជនជាប់ចោទ ហើយផ្តល់ស្ថានសម្រាលដល់គាត់មែននោះ វាគួរតែនៅចន្លោះត្រឹមតែ១៥ឆ្នាំ អប្បបរមា។ ពីព្រោះថាគាត់ជាអ្នករងគ្រោះពីសាលាជម្រះក្តីនេះផងដែរ។ មិនមែនពីអង្គជំនុំជម្រះទេ គឺពីក្រុមអយ្យការដែលប្រើប្រាស់ស្តង់ដារទ្វេ។

[១៤:២៧:៣៨]

ដូចដែលយើងបានលើកឡើងពីម្សិលមិញអ៊ីចឹង គឺស្តង់ដារទ្វេ គឺពួកអ្នកគុក១៩៥ទៀត អត់កាត់ទោសទេ គឺគាត់កាត់ទោសតែគាត់ម្នាក់ឯង។ ដូច្នេះ គាត់រងគ្រោះទ្វេក្នុងរបបកម្ពុជាប្រជាធិបតេយ្យគាត់ក៏រងគ្រោះមួយផ្នែកដែរហើយ ទាំងផ្នែកស្មារតី ហើយក្រោយមកយើងរងគ្រោះដោយសារការកាត់ក្តីនៅទីនេះ ប្រើប្រាស់ស្តង់ដារទ្វេទៀតផង។ នេះហើយជាចំណុចចម្បងដែលខ្ញុំទាញការចាប់អារម្មណ៍របស់អង្គជំនុំជម្រះ មេត្តាផ្តល់នូវយុត្តិធម៌ ដែលយើងជឿតែទៅលើមនសិការវិជ្ជាជីវៈ ទៅលើចំណេះដឹងច្បាប់ ការអប់រំ និងសណ្តានចិត្តរបស់អស់លោកដែលមិនប្រើប្រាស់បេះដូងក្នុងជំនុំជម្រះក្តីនៅទីនេះ និង

ផ្តល់ស្ថានសម្រាលដ៏សមរម្យដល់គាត់ ដែលមិនលើសពីស្ថានសម្រាលដូចដែលគេប្រើប្រាស់នៅសាលាដំបូង អ.វ.ត.ក ទេ។

បាទ សូមអរគុណ ចំពោះសំណួររបស់អ្នកស្រីចៅក្រមបាទ។

[១៤:២៨:៤០]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមមានសំណួរមួយទាក់ទងលោកសហមេធាវី សូមលោកសហមេធាវីការពារជនជាប់ចោទបំភ្លឺបន្តិចទាក់ទងបញ្ហាអំមិញនេះ គឺខាងសហព្រះរាជអាជ្ញាក៏បានលើកឡើងអំពីមាត្រា៦៦៨ នៃក្រមព្រហ្មទណ្ឌដែលថាក្នុងកថាខណ្ឌ៣ នេះគឺគាត់យល់ថាជាច្បាប់ អ៊ី.ស៊ី.ស៊ី.ស៊ី នេះគឺជាច្បាប់ដែលមានចរិតពិសេស។ ដូច្នេះហើយគាត់យល់ថា មិនត្រូវបានយកមកប្រើប្រាស់នៅច្បាប់ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ទេ។ ដូច្នេះ តាមទស្សនៈរបស់លោក លោកយល់ថាយ៉ាងម៉េចដែរទាក់ទងនឹងបញ្ហាចរិតពិសេសនេះ?

**លោក កង ឫទ្ធារី៖**

សូមអរគុណលោកប្រធានបាទ។ ខ្ញុំសូមឆ្លើយតបទៅនឹងសំណួរនេះ តាមពិតខ្ញុំឆ្លើយជាទូទៅរួចហើយ។ គឺថាតាមមាត្រា៦៦៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ កថាខណ្ឌទី៣ និយាយអំពីករណីច្បាប់ព្រហ្មទណ្ឌពិសេសចរិត ដែលមានចរិតពិសេសណាមួយនោះបានន័យថា ប្រសិនបើច្បាប់នុ៎ងវាភ្ជាប់ដោយកថាខណ្ឌទី១។ បានន័យថា ច្បាប់ព្រហ្មទណ្ឌពិសេសនុ៎ងមានលក្ខណៈផ្ទុយពីក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ទើបបានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ នេះមិនក្របដណ្តប់ទៅលើវា។

[១៤:២៩:៥៧]

ផ្ទុយទៅវិញច្បាប់ អ.វ.ត.ក ដែលមានចរិតពិសេស ចរិតលក្ខណៈដោយឡែកនិយាយ និយាយដោយឡែកនិងពិសេស មិនបានមានភាពផ្តល់ភាពចម្រូងចម្រាសដល់ច្បាប់ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ទេ។ ផ្ទុយទៅវិញក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានស្រង់យកចំណែកខ្លះនៃច្បាប់ អ.វ.ត.ក នេះដាក់បញ្ចូលផង។ ដូចដែលខ្ញុំបានលើកឡើងហើយគឺមាត្រា៣ មាត្រា៤ មាត្រា៥ និងមាត្រា៦។

[១៤:៣០:២៧]

សូមអរគុណ។ អ៊ីចឹងបានន័យថា វាអត់មានទាស់គ្នាទេ ទាល់តែទាស់គ្នាបានគេមិនឲ្យប្រើ បើច្បាប់ អ.វ.ត.ក នេះមិនទាស់គ្នាឯណាជាមួយនឹងក្រមព្រហ្មទណ្ឌ២០០៩ ហើយកិច្ចព្រមព្រៀងកម្ពុជា

និងអង្គការសហប្រជាជាតិ មាត្រាទី១២ ស្តីអំពីនីតិវិធី។ មាត្រា៣៦ ស្តីពីការអនុវត្តច្បាប់បានចែងយ៉ាងច្បាស់ថា ឲ្យអនុវត្តដូចច្បាប់កម្ពុជា។

ដូច្នេះ រាល់បទដ្ឋានច្បាប់កម្ពុជាទាំងអស់ត្រូវតែយកមកប្រើប្រាស់នៅ អ.វ.ត.ក នេះឲ្យអស់លទ្ធភាពមុននឹងឈានទៅរកច្បាប់អន្តរជាតិផ្សេងៗដើម្បីមកបង្គ្រប់ ហើយប្រភពនៃច្បាប់អន្តរជាតិនោះទៀតសោតតាមមាត្រា១២ នៃកិច្ចព្រមព្រៀងរវាងកម្ពុជានិងអង្គការសហប្រជាជាតិ និងមាត្រា៣១ គឺបានកំណត់ថា ប្រភពច្បាប់អន្តរជាតិ ហើយបើយើងបូកន័យទាំងពីរប្រភពច្បាប់អន្តរជាតិ ប្រភពច្បាប់ជាតិ ដែលជាច្បាប់កម្ពុជា ជាច្បាប់ស៊ីវិលឡ នោះគឺថាគេត្រូវឲ្យអនុវត្តតែទៅលើសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងទេ គឺមិនអនុវត្តទៅលើច្បាប់ដែលកើតឡើងដោយករណីយុត្តិសាស្ត្រដូចជានៅយកការសម្រេចចិត្តនៅយូហ្គោស្លាវី ឬសៀរ៉ាឡេអូន ឬរវ៉ាន់ដា មកពិភាក្សាឡើយ។ បាទ, សូមអរគុណ។

[១៤:៣១:៣៤]

**ប្រធានអង្គជំនុំៈ**

ខ្ញុំសូមបន្តសំណួរមួយទៀតដែលទាក់ទងនឹងបញ្ហាការកំណត់ទោសនឹងដែរ។ គឺសំខាន់ គឺចំណុចមួយដែលថានៅក្នុងច្បាប់ អ.វ.ត.ក ហ្នឹង គឺយើងមានមាត្រា៣៩(ថ្មី) ហ្នឹងគឺចែងអំពីការកំណត់ទោសពី៥ឆ្នាំរហូតទៅដល់អស់មួយជីវិត។

ហើយនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ នេះគឺមានទាក់ទងនឹងគន្លឹ៦ អវសានប្បញ្ញត្តិហ្នឹង គឺយើងនិយាយនៅក្នុងមាត្រា៦៧១ លោកអាចបើកមើលនៅក្នុងក្រមនៅក្នុងហ្នឹងលោកពិនិត្យមើលនៅក្នុងនេះ គឺគេដាក់ថានិរាករណ៍ និងការអនុភាព និងអានុភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន។ ហើយនៅក្នុងនេះយើងឃើញថា មាត្រា៦៧១ នេះអត់បានដាក់ឲ្យច្បាប់ អ.វ.ត.ក នឹងចូលជានិរាករណ៍ទេ។

[១៤:៣២:៣០]

ហើយលើសពីនេះទៀតនៅក្នុងមាត្រាហ្នឹងក៏បានចែងថា បទប្បញ្ញត្តិនេះគេអាចអនុវត្តរហូតបាន។ អ៊ីចឹងទាក់ទងបញ្ហាការកំណត់ទោសហ្នឹងលោកអាចយល់យ៉ាងម៉េចថាយើងតុលាការ គឺមានឆន្ទានុសិទ្ធិក្នុងការប្រើប្រាស់មាត្រា៣៩(ថ្មី) និង\ឬ ក៏ត្រូវតែប្រើប្រាស់នូវមាត្រា៩៥ ដូចជាយោបល់របស់លោកអំមិញនេះ។

**លោក កង ឫទ្ធារីៈ**

តាមពិតទៅមាត្រា៦៧១ និរាករណ៍តែច្បាប់ព្រហ្មទណ្ឌណាដែលត្រូវនិរាករណ៍ទេ។ ឧទាហរណ៍

ដូចជាច្បាប់ អ៊ុនតាក់ ដែលយើងបានដឹងទាំងអស់គ្នា ដូចជាច្បាប់ដែលបន្សល់ទុកដោយអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា និងច្បាប់ព្រហ្មទណ្ឌនានាដែលមានចរិតផ្ទុយពីក្រមព្រហ្មទណ្ឌ២០០៩។ ប៉ុន្តែច្បាប់ អ.វ.ត.ក វាមិនបានមានលក្ខណៈចរិតផ្ទុយទេ ហើយវាបានកំណត់ដូចនៅក្នុងមាត្រា៦៦៨ អ៊ីចឹង។

បានន័យថា បើមានការអីខុសប្លែកគ្នាគេឲ្យទៅមើលគន្លឹទី១។ គន្លឹទី១ គឺក្រសោបទៅដល់ធាតុផ្សំនៃបទល្មើស ហើយនិងការទទួលខុសត្រូវនៃព្រហ្មទណ្ឌ។ ហើយគន្លឹទី១ ហ្នឹងគឺស្រប ផ្ទុយទៅវិញគន្លឹ១ ហ្នឹងស្រូបយកមាត្រាជាច្រើននៃច្បាប់ អ.វ.ត.ក បញ្ចូលធ្វើជាច្បាប់ដែលមានសុពលភាពផងដែរ។

[១៤:៣៣:៥៤]

ដូច្នេះ តុលាការគួរពិចារណាលើមាត្រា១០ ផងដែរ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ពីព្រោះថាតុលាការអាចនឹងពិចារណាទាំងច្បាប់ អ.វ.ត.ក និងក្រមព្រហ្មទណ្ឌកម្ពុជាដើម្បីបំពេញបន្ថែមចន្លោះប្រហោងនៃច្បាប់ដែលថា តុលាការអាចនឹងមានការសង្ស័យ ឬក៏មានការពិបាកពិចារណាជាជាងការប្រើប្រាស់ច្បាប់ដែលបង្កើតឡើងយដោយករណីយុត្តិសាស្ត្រ ដូចដែលក្រុមអយ្យការបានលើកឡើង។ នេះអ្វីដែលខ្ញុំចង់ឆ្លើយទៅលោកប្រធាន។

បាទ, អរគុណ។

**ប្រធានអង្គជំនុំ៖**

អស់សំណួរហើយ។ អ៊ីចឹងអត់មានសំណួរបន្តទៅទៀតទេ សូមអញ្ជើញសហព្រះរាជអាជ្ញាធ្វើការឆ្លើយតបនឹងសេចក្ដីសន្និដ្ឋានតបរបស់ខាងមេធាវីការពារជនជាប់ចោទ។

បាទ, សូមអញ្ជើញ!

[១៤:៣៤:៤៧]

**លោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំមិនមែនជាការឆ្លើយតបទេពេលនេះ គឺថាមានបំណងក្នុងការចង់ឲ្យអង្គជំនុំជម្រះតុលាការកំពូលហ្នឹងមានការផ្ដោតអារម្មណ៍ទៅលើមាត្រា១២ នៃកិច្ចព្រមព្រៀង ហើយខ្ញុំនឹងទុកឲ្យសហការីរបស់ខ្ញុំ នឹងការឆ្លើយតបទៅខាងសហមេធាវីការពារក្ដី។

ដូច្នេះ នេះជាការមួយដែលខ្ញុំគិតថា ទីមួយ ខ្ញុំគិតថានៅក្នុងមាត្រា១២ នៃចំណុច២ហ្នឹង គឺមានចែងច្បាស់ណាស់ អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន។ ដូច្នេះយុត្តាធិការរបស់យើងខ្ញុំគិតថាវាមាន ហើយនៅក្នុងនុំងមានចែងអំពីមាត្រា១៤ និង១៥ ស្ដីពីអនុសញ្ញាអន្តរជាតិផងដែរ។

[១៤:៣៥:៤៣]

ទីពីរ យើងបកមក មាត្រា១២ ហ្នឹងដដែល ប៉ុន្តែនៅក្នុងកថាខណ្ឌទី១។ ក្នុងកថាខណ្ឌទី១ នេះ ជាសំណួរមួយដែលលោកចៅក្រម មីឡាត លើកឡើងអំមិញហើយ គឺថាមានបញ្ហារវាងច្បាប់ជាតិ ច្បាប់២០០៩ អំមិញនេះ ហើយនិងជាមួយច្បាប់ពិសេស។

អ៊ីចឹងថានៅក្នុងនេះនិយាយច្បាស់ហើយ ថាបើសិនពុំអាចដោះស្រាយបញ្ហាណាមួយបាននោះ គឺគេសរសេរថាត្រូវស្វែងរក១ដំណោះស្រាយយ៉ាងដូចម្ដេច? ស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ។ អានេះ ឃ្លានេះខ្ញុំជឿថាមានការច្បាស់អាចជាការពិចារណាក្នុងការសម្រេចក្ដីនេះ។ នេះជាការគ្រាន់តែជាការរំឭកនៅក្នុងមាត្រា១២ នៃកិច្ចព្រមព្រៀង ហើយបន្ទាប់ទៀតនេះ ខ្ញុំនឹងឲ្យសហការីនឹងឆ្លើយតបនូវចំណុចមួយចំនួនដែលខាងសហមេធាវីការពារក្ដីលើកឡើងអំមិញ។

[១៤:៣៦:៤៩]

**លោក អាន់គ្រូ ខេលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងធ្វើការឆ្លើយតបដោយសង្ខេប។ សហមេធាវីការពារក្ដីបានលើកឡើងថា កូនក្ដីរបស់គាត់គឺវាមានលក្ខណៈផ្ទុយអំពីអ្វីដែលយើងលើកឡើង។ ខ្ញុំនឹងមិនលើកឡើងទឡ្ហីករណ៍របស់ខ្ញុំឡើងវិញទេ ហើយកូនក្ដីរបស់គាត់តាមសហមេធាវី គឺបានសារភាពនិងបានសហការជាមួយនឹងតុលាការ ហើយដូចដែលខ្ញុំបានលើកឡើងក្នុងកថាខណ្ឌ៦៦ ទៅដល់៧០ ដែលបានបង្ហាញយ៉ាងច្បាស់អំពីសារណា និងទឡ្ហីករណ៍របស់ខ្ញុំ។

[១៤:៣៧:៣២]

សហមេធាវីការពារក្ដីបានលើកឡើងថា កូនក្ដីរបស់គាត់គឺមានការភ័យខ្លាច។ ប៉ុន្តែ ប្រសិនបើយើងមើលលើកថាខណ្ឌ៥៥៥ នៃសេចក្ដីសម្រេចរបស់សាលាដំបូង គឺគាត់មានការភ័យខ្លាចនៅដំណាក់ចុងក្រោយតែប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងចន្លោះពេលនៃរបបនោះគឺគាត់បានអនុវត្តតួនាទី និងប្រតិបត្តិការងាររបស់គាត់ដោយភាពក្លៀវក្លា និងដោយប្រសិទ្ធភាព។

សហមេធាវីការពារក្ដីលើកឡើងយ៉ាងច្បាស់ថាជនជាប់ចោទគាត់បានធ្វើការងាររបស់គាត់ ប៉ុន្តែយើងដឹងហើយថាគាត់ធ្វើការងារហ្នឹងពីព្រឹក ភ្ញាក់ពីព្រឹក ហើយបំពេញការងារហ្នឹងរហូតដល់មានការកាប់សម្លាប់រហូតដល់១២ពាន់-- ជាង១២ពាន់នាក់។ ចៅក្រម មីឡាត បានលើកឡើងអំពីការកាត់ទោសធ្ងន់ ហើយចៅក្រមក៏បានយល់ដែរ។ លោកស្រីចៅក្រមបានបង្ហាញអំពីក្រមឆ្នាំ២០០៩ ខ្ញុំមិនលើក

ឡើងបញ្ហានឹងទេ។ ប៉ុន្តែ ខ្ញុំលើកឡើងអំពីចំណុចផ្សេងដែលការកំណត់ទោសហ្នឹង ជាឆន្ទានុសិទ្ធិរបស់លោកចៅក្រមក្នុងកំណត់ទោសទៅតាមច្បាប់អន្តរជាតិ។

[១៤:៣៨:៥៣]

វាជាឆន្ទានុសិទ្ធិមួយយ៉ាងធំធេង ហើយសុំឲ្យលោកចៅក្រមធ្វើការពិនិត្យលើករណី *ផែលរ័របឺឈី* ហើយខ្ញុំមិនអាចមើល-- លើកឡើងលើចំណុចនេះទេដែលយុត្តិសាស្ត្រនេះទាក់ទងទៅនឹងកថាខណ្ឌ៤២៨ និង៤៣២។ លោក លោកស្រីចៅក្រម ត្រូវពិចារណាឲ្យបានហ្មត់ចត់ទៅលើស្ថានសម្រាល និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងបទល្មើស ហើយត្រូវពិចារណាទៅលើតួលេខដែលកំណត់ទោសដោយសាលាដំបូង។ ខ្ញុំដឹងថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការកំណត់ទោស ដែលមានលក្ខណៈស្រដៀងគ្នា ហើយប្រៀបធៀបជាមួយនឹងបទល្មើសដទៃៗទៀតទៅតាមច្បាប់។

[១៤:៣៩:៣៧]

ចំពោះការកាត់ទោសត្រួតដូចដែលខ្ញុំបានលើកឡើងកាលពីមុន ការធ្វើទុក្ខបុកម្នេញវាមានធាតុខុសគ្នាពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមួយចំនួនដទៃៗទៀត។ ដូច្នេះ ប្រសិនបើលោកចៅក្រមធ្វើការកំណត់ទោសនោះគួរតែពិចារណាអំពីចេតនានៃការរើសអើងដែលជាធាតុមួយនៃការធ្វើទុក្ខបុកម្នេញ ហើយវាជាស្ថានទម្ងន់មួយផងដែរ ទៅលើបទល្មើសនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅពេលដែលលោក លោកស្រីចៅក្រមកំណត់ទោស។ ដូច្នេះ នៅពេលដែលកែប្រែទៅលើការទូទាត់ទោសនោះ លោក លោកស្រីចៅក្រម គួរតែពិចារណាទៅលើស្ថានភាពទាំងអស់នេះ និងអង្គហេតុ ឬក៏ចំណុចមួយចំនួនដែលលោកចៅក្រមបានរកឃើញផ្អែកទៅលើស្ថានភាពទាំងអស់នេះ។

សូមអរគុណ។

[១៤:៤១:១០]

**ប្រធានអង្គជំនុំ៖**

ជាបន្តទៅទៀតនេះ លោកសហមេធាវីការពារឲ្យជនជាប់ចោទបើធ្វើការឆ្លើយតប សូមអញ្ជើញ បើគ្មានទេក៏អត់អីដែរ។

**លោក កង ឫទ្ធារី៖**

សូមជម្រាបលោកប្រធាន គឺអត់មានទេ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងបើអត់មានទេ គឺថ្ងៃនេះ គឺយើងបញ្ចប់សវនាការយើង គឺតុលាការប្រកាសផ្អាកសវនាការនាថ្ងៃនេះនៅពេលនេះ ហើយស្អែកនឹងបន្តសវនាការទៅទៀតនៅវេលាម៉ោងប្រាំបួន ទាក់ទងនឹងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ហើយបង្គាប់ឲ្យមន្ត្រីពន្ធនាគារនាំជនជាប់ចោទទៅមន្ទីរឃុំឃាំងវិញហើយស្អែកវេលាម៉ោងប្រាំបួន សូមអញ្ជើញនាំមកសាលសវនាការដើម្បីយើងបន្តសវនាការបន្តទៀត៕

**លោក ផន ធឿន៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:៤២ នាទី)*